
ឱ! ផ្សែងមរណៈ
ដោយ : ហាក់ សៃមុង

# ឱ ! ... ផ្សែងមរណៈ

## អ្នកនិពន្ធ
## ហាក់ ឆៃហុក

~១~

### បុណ្យខ្មោចមិត្តខ្ញុំ

ជាតិនេះកម្មក្រាស់ខ្វាសស្នេហា  ក្ស័យជន្មជីវាដោយសារស្រី
នាងចិត្តវៀចវេរបែរមានថ្មី  ហៅចំអប្រិយ៍ស្រីអប្បលក្ខណ៍ ។
សពមិត្តខ្ញុំស្លាំងហើយស្គមស្គាំង  ហត្ថទ្វេដាក់តាំងលើទ្រូងជាក់
ថ្ងៃនេះត្រូវគេបូជាអ្នក  យើងខានឃើញភ័ក្ត្រអ្នកទៀតហើយ ។

**ម៉ោង ១ អធ្រាត្រស្ងាត់ ...**

ខ្យល់បក់ត្រជាក់ពេលយប់ជ្រៅ បក់រសៀកៗមិនដាច់រយៈ មនុស្សម្នាកំពុងលង់លក់ក្នុងដំណេករបស់ខ្លួនយ៉ាងសែនសុខ ។ ហ្វូងសត្វរត្តិចរហិចហើរឆ្វាត់ឆ្វែល ពីដើមឈើមួយទៅដើមឈើមួយ បោះពួយល្បឿនស្លុងក្នុងលំហអាកាសវេហាស៍ ហាក់ដូចជាគ្មានភិតភ័យ ឬញញើតញញើម នឹងស្រមោលអន្ធការដែលគ្របដណ្ដប់គ្រប់ទិសទី ក្នុងពេលរាត្រីរនោចនេះសោះ ។

នៅចុងភូមិឯណោះ សំឡេងសូត្រអភិធម្មឮសូរគ្រលួចកណ្ដាលរាត្រីស្ងាត់ បណ្ដាលឱ្យអ្នកដែលបានឮព្រឺក្បាលខ្វាក ហើយទាញភួយមកគ្រលំក្បាលជិតមួយរំពេច ។

សំឡេងអាចារ្យសូត្រធម៌ លាយឡំនិងសំឡេងយំសោករបស់ក្រុមញាតិមិត្ត បងប្អូនឪពុកម្ដាយសព កំពុងក្រៀមក្រំសង្វេគក្នុងដួងចិត្តឥតឧបមា តើអ្នកណាស្លាប់ ? សពនោះជាអ្នកណាទៅ ? ដើម្បីបំបាត់អាការងឿងឆ្ងល់ទាំងនេះ អ្នកនិពន្ធសូមអញ្ជើញអស់មិត្តអ្នកអានទៅជួប ទិដ្ឋភាពដ៏សែនខ្លោច

ផ្សារមួយក្រោមដំបូលផ្ទះប្រក់ក្បឿងសង់នៅជិតចុងស្ពានថ្មផ្លូវសៀមរាបមកភ្នំពេញ ដែលមានសភាពបូរាណ និងចាស់ទ្រុឌទ្រោមបន្តិចទៅហើយ ។

ខាងក្នុងផ្ទះ គេឃើញក្ដារម្ឈូសដំកល់នៅចំកណ្ដាលល្វែងនៃគេហដ្ឋាន ។ ក្លិនធូប ទៀនក្រអូបផ្សព្វផ្សាយជះចេញមកខាងក្រៅ ។ នៅជុំវិញសពបងប្អូនញាតិមិត្តជិតឆ្ងាយដែលមកកំដរនាំគ្នាអង្គុយបត់ជើងដោយសភាពស្ងប់ស្ងាត់ និងមានទឹកមុខស្ងួតក្រៀមស្រពោន បញ្ជាក់ឱ្យដឹងថា គេរាល់គ្នាកំពុងតែហែលឆ្លងកាត់នឹងសមុទ្រទុក្ខមួយដ៏ធំធេង ។ យូរៗសំឡេងយំសោកអណ្ដឺតអណ្ដកដែលបាត់ទៅមួយខណៈក៏ឮឡើយវិញ ភ្នែកគេរាល់គ្នាផ្ដោតជាប់ទៅលើរូបថតមួយផ្ទាំង ដាក់ក្នុងស៊ុមកញ្ចក់រចនា ព័ទ្ធព័ន្ធទៅដោយភួងផ្កាម្លិះតាំងនៅមុខក្ដារម្ឈូស ។ សពនេះជាយុវជនមួយរូប តាមយើងស្មានមើលទៅប្រហែលជាអាយុ ២៥ ឬ ២៦ ឆ្នាំ ប៉ុណ្ណោះ ពិតមែនតែរូបថតមិនអាចឱ្យយើងឃើញសម្រុងខ្លួនរបស់អ្នកស្លាប់ តែក៏អាចឱ្យយើងឃើញនូវទឹកមុខដ៏មុតមាំ ញញឹមយ៉ាងមានស្នេហ៍ រាងដ៏សង្ហារបស់គេ បញ្ជាក់ច្បាស់លាស់ថា គេជាយុវជនមួយរូបប្រកបដោយរូបសម្បត្តិ និងមានសុខភាពបរិបូណ៌ ។

អនិច្ចា ... ! សង្ខារអ្នកស្លាប់បញ្ចូលក្នុងក្ដារម្ឈូសបាត់ទៅហើយ តែរូបថតរបស់អ្នកនៅតែញញឹមមករកគេឯង ហាក់ដូចជាមានជីវិតរស់នៅឡើយ ។ នត្ថិ សន្តិ បរំ សុខំ គ្មានសេចក្ដីសុខឯណាស្មើនឹងសេចក្ដីស្ងប់ឡើយ ពិតណាស់អ្នកស្លាប់ គឺអ្នកដែលបានទទួលសេចក្ដីស្ងប់ ផុតទុក្ខ កង្វល់ ... លែងជំពាក់នឹងចំណងកម្មលើវាលវដ្ដសង្សារតទៅទៀត ។ វិញ្ញាណក្ខន្ធគេហោះហើរទៅកាន់សុគតិភព ហើយទុកចោលតែរូបអសុភស្ដូមស្ដាំង ឱ្យអ្នកនៅរស់សោកសង្រេងអាឡោះអាល័យគ្មានពេលភ្លេច ។

អ្នកមីងមឿន ទ្រាំមើលរូបថតកូនប្រុសសម្លាញ់តែមួយរបស់គាត់តទៅទៀតលែងកើត ។ គាត់ស្ទុះរំកែតរំកែងឯង ទៅអោបក្ដារម្ឈូស ហើយបោកក្បាលគាត់ទៅនឹងក្ដារ ប៉ុង ... ! ប៉ុង ...! ព្រមទាំងស្រែកយំទួញដង្ហោយហៅកូនដូចជាមនុស្សវិកលចរិត ។

ណាស៊ីកូន ... ម្ដេចក៏អាយុកូនខ្លីម្ល៉េះ ទេវតាព្រះឥន្ទ្រ ព្រះព្រហ្មអើយ សូមព្រះអង្គមកជួយខ្ញុំផង ខ្ញុំមានកូនតែមួយគត់ ឥឡូវកូនខ្ញុំស្លាប់បាត់ទៅហើយ ... ម្ដេចក៏លោកទុកឱ្យខ្ញុំរស់ធ្វើអ្វីទៀត សូមលោកជួយឱ្យកូនខ្ញុំរស់វិញផង បើមិនដូច្នោះទេ ខ្ញុំនឹងអត់ដង្ហើមឱ្យស្លាប់នៅពេលឥឡូវនេះហើយ ... ណាស៊ីកូន ... ម្ដាយខំចិញ្ចឹមឯងតាំងពីតូចរហូតដល់ធំខំឱ្យឯងរៀនសូត្រចេះដឹងនឹងគេ ទោះជាក្ររហេមរហាមយ៉ាងណា ក៏ម្ដាយមិនដែលឱ្យកូនពិបាកចិត្តដែរ ទាំងនេះគឺដើម្បីឱ្យកូនបានថ្កុំថ្កើង គ្រាន់ម្ដាយស៊ីពោះលោះកម្លាំងនៅពេលចាស់ ចុះ

ឥឡូវបើកូនស្លាប់ចោលម្ដាយទៅ ហើយ តើឱ្យម្ដាយនៅរំពឹងអ្វីទៀត ... ស្អែកនេះគេយកកូនទៅដុតហើយ ... ។

មីងមឿន យំសោកបោកខ្លួនទាល់តែសន្លប់បាត់ស្មារតីក្បែរក្ដារម្ឈូសកូនក្នុងគ្រានោះ ។ អ្នកនៅកំដរទាំងប៉ុន្មាន នឹកអាណិតអ្នកមីងខ្លោចថ្លើមប្រម៉ាត់ ហើយក៏យំហ៊ូរចេញមកគ្រប់គ្នា មានតែយុវជនម្នាក់ទេ ដែលចេះអត់សង្កត់ចិត្តនឹងភាពសែនរន្ធត់ ទៅលើកគ្រាហ៍អ្នកមីងមឿនយកមកដាក់លើគ្រែ ហើយជួយកោសរិតចាប់ខ្យល់គាត់ជាបន្ទាន់ មួយស្របក់ក្រោយមកគាត់ក៏ដឹងខ្លួនឡើងវិញ ។

យុវជននេះមានឈ្មោះថាសំណាង គេជាមិត្តជិតដិតស្និទ្ធស្នាល ជាងគេបំផុតរបស់អ្នកស្លាប់ ។ សំណាងបានមកដេកកំដរជួយព្យាបាលមិត្តរបស់គេតាំងពីជំងឺនៅស្រាលរហូតដល់ធ្ងន់ ហើយនៅពេលដែលណាស៊ី ស្លាប់ ក៏ផុតដង្ហើមស្លាប់នៅក្នុងរង្វង់ដៃគេនេះឯង ។ សំណាងនឹកអាណិត និងសោកស្ដាយចំពោះមិត្តគេណាស់ រឿងអាថ៌កំបាំងរបស់ណាស៊ី សំណាង បានដឹងអស់គ្មានសល់ ។ ណាស៊ីប្រឡងមធ្យមសិក្សាប័ត្រធ្លាក់ ហើយឈឺរ៉ាំរ៉ៃរាប់ខែទាល់តែស្លាប់ខ្លួន ក៏គ្មាននរណាដឹងថាណាស៊ីស្លាប់មកពីអ្វីដែរ មានតែរូបសំណាងម្នាក់គត់ប៉ុណ្ណោះ អាចដឹងថាមិត្តរបស់គេស្លាប់ដោយសារអ្វី ។ ជនកម្លោះក្រឡេកមើលទៅធូបមុខរូបថត ឃើញឆេះជិតអស់ ។ អ្នកក៏ហូតយកបីសរសៃទៅដុតបន្តទៀត ។

ភ្លឺច្បាស់ហើយ បន្ទាប់មក ព្រះអារុណនៃថ្ងៃថ្មីក៏រះឡើង ។ ទង់មរណសញ្ញាដោតមុខផ្ទះបក់រវិចៗ ត្រូវនឹងកម្លាំងខ្យល់ ជួនកាលផែលចុះ ផែលឡើងមានរាងដូចជាសត្វក្អែបកំពុងវារ ។

ភ្ញៀវជិតខាងនាំគ្នាមកកាន់ផ្ទះសពជាបន្ទាប់បន្ទ ពេលនោះព្រះសង្ឃដប់អង្គក៏និមន្តមកដល់ដែរ ។ សំណាងមានភារៈជាអ្នកទទួលភ្ញៀវ ប្រញាប់ចុះពីលើផ្ទះមកអញ្ជើញភ្ញៀវ និងនិមន្តព្រះសង្ឃឡើងទៅគង់លើផ្ទះយ៉ាងរូសរាន់ ក្រោយពីនោះបន្តិច រថយន្តមែរសឺដែស (Mercede’s) ពណ៌ខ្មៅមួយចូលមកឈប់មុខផ្ទះ អ្នកនៅក្នុងរថយន្តជាយុវជនស្អាត សម្លៀកបំពាក់របស់គេ កាត់ពីក្រណាត់ធុនថ្លៃ បញ្ជាក់ឱ្យដឹងថាគេជាអ្នកទីក្រុង ហើយជាអ្នកមានធនធានគ្រាន់បើដែរ ។ នៅដៃគេមានកាន់ភួងផ្កាមរណៈ ស្រោបក្រដាសកែវមួយផ្ទាំងធំ ។ យុវជនបើកទ្វាររថយន្តចុះមក ដើរឡើងជណ្ដើរទៅលើផ្ទះដោយមិនចាំបាច់ឱ្យគេអញ្ជើញឡើយ ។ ពេលនោះទទួលសំណាងក្រឡេកមើលឃើញក៏ស្រែកហៅដោយត្រេកអរថា :

-វង្សរិទ្ធិ ... ! យីខ្ញុំស្មានថាតែមិត្តមកមិនទាន់ពេលវេលាទេតើ ម៉ោងពីរថ្ងៃនេះគេនឹងយកសពទៅបូជាហើយ មក ... ឡើងមក ។

យុវជនឈ្មោះវង្សរិទ្ធិ ញញឹមស្ងួតទៅកាន់សំណាង ហើយក៏ដើរឡើងលើផ្ទះបាត់ទៅ ។

-ខ្ញុំគ្រាន់តែបានទទួលទូរលេខពីសំណាងឯងភ្លាម ខ្ញុំក៏ប្រញាប់រៀបចំខ្លួនធ្វើដំណើរមកសៀមរាបទាំងយប់មិនហ៊ានបង្អង់ឱ្យយូរដែរ ។

វង្សរិទ្ធ និយាយទៅកាន់សំណាង ក្រោយពីបានទៅជំរាបសួរអ្នកមីងមឿនរួចហើយ ។

បន្ទាប់ពីព្រះសង្ឃសូត្រមន្ត និងវេចង្ហាន់ដល់ព្រះសង្ឃរួចស្រេចបាច់តាមប្រពៃណីហើយ សំណាងក៏បានទៅបើកក្តារម្ឈូសបង្ហាញឱ្យវង្សរិទ្ធិមើលជាគ្រាចុងក្រោយបង្អស់ ដែលនិងត្រូវយកទៅធ្វើឈាបនកិច្ច ។ វង្សរិទ្ធិគ្រាន់តែឃើញសពមិត្តគេ អ្នកអួលណែនក្នុងបំពង់កចង់ស្រែកយំក្តែង១ឱ្យអស់ចិត្ត តែហើយអ្នកក៏ខំរម្ងាប់ទៅវិញ ដោយគ្រាន់តែធ្វើភ្នែករលីងរលោងនិយាយក្រងូរ១ស្ទើរបាត់ស្ទើរឮទៅកាន់សំណាងថា :

-ខ្ញុំអាណិតណាស៊ីណាស់ ... ស្លាប់បាត់ទៅហើយមុខនៅតែញញឹមប៉ប្រឹម តែ ... ឈឺប៉ុន្មានថ្ងៃហើយសំណាងបានជាស្គាំងស្គមអីខ្លាំងម្ល៉េះ ? ហើយម្តេចក៏មិត្តមិនឱ្យដំណឹងទៅខ្ញុំឱ្យបានដឹងផង ?

សំណាងមិនទាន់ឆ្លើយមកវង្សរិទ្ធិវិញភ្លាមទេ យុវជនយកខ្នងដៃមកជូតទឹកភ្នែកដែលកំពុងហូរច្រោក១ ដោយចុកណែនក្នុងឱរាស្ទើរប្រេះធ្លាយ ។ ទើបតែពេលនេះទេ ដែលអ្នកចេះយំ អ្នកយំព្រោះសោកស្តាយមិត្ត ដែលនឹងត្រូវគេសែងយកទៅបូជាឯប៉ាឆាក្នុងពេលខាងមុខនេះ ។ មួយសន្ទុះក្រោយមកទើបគេឮសំណាងឆ្លើយតបទៅវង្សរិទ្ធិខ្សាវ១ថា :

-ណាស៊ីដេកឈឺត្រាំត្រែងបីខែមកហើយវង្សរិទ្ធិ ទោះជាខ្ញុំ និង មីងខំរកគ្រូហ្មមកមើលយ៉ាងណា ក៏មិនបានជាដែរ ទីបំផុតមច្ចុរាជក៏មកផ្តាច់ជីវិតណាស៊ីទាល់តែបាន ... មិត្តខ្ញុំស្លាប់នេះ ខ្ញុំតូចចិត្តណាស់ បើស្លាប់ដោយមុខរបួស ... ឬរោគដូចគេឯងទាំងពួង ខ្ញុំមិនសូវជាសោកស្តាយប៉ុន្មានទេ តែនេះមិត្តខ្ញុំស្លាប់ព្រោះតែខូចចិត្ត ព្រោះអស់សង្ឃឹមក្នុងរឿងស្នេហា ។

-យី ! ខ្ញុំដូចជាមិនយល់ពាក្យសំណាងឯងនិយាយមកនេះសោះ (វង្សរិទ្ធិនិយាយចងចិញ្ចើមដោយងឿងឆ្ងល់) តើមានរឿងអីអាថិកំបាំង ចំពោះរឿងស្លាប់របស់ណាស៊ី ឬ ?

-ពិតហើយវង្សរិទ្ធិ ការដែលបណ្តាលឱ្យណាស៊ីស្លាប់នេះ វាមានរឿងហេតុទាក់ទងឆ្ងាយណាស់ ។

-បើមិនយល់ទាស់ទេ សំណាងឯងជួយនិយាយរឿងរ៉ាវទាំងនេះឱ្យខ្ញុំបានដឹងផង ។

សំណាងយកដៃញីថ្ងាសទ្រង់គិត ហើយគេក៏សម្រេចចិត្តថាត្រូវតែនិយាយរឿងពិតប្រាប់វង្សរិទ្ធិឱ្យបានដឹង ។

-វង្សរិទ្ធិឯងចង់ដឹងរឿងណាស៊ីស្លាប់ឬ ?

-ត្រូវហើយសំណាង ខ្ញុំចង់ដឹងរឿងនេះណាស់ ។ វង្សរិទ្ធប្រញាប់ឆ្លើយឡើងយ៉ាងរហ័ស ។

-បើឥចឹង មិត្តមកតាមខ្ញុំមក (សំណាងក្រោកឈរ) យើងទៅអង្គុយនិយាយគ្នាឯផ្ទះបាយវិញ ពីព្រោះវាមានរឿងរ៉ាវវែងឆ្ងាយណាស់ ។

ថាហើយ សំណាងក៏នាំវង្សរិទ្ធិទៅអង្គុយសន្ទនាគ្នាពីរនាក់ស្ងាត់ៗនៅផ្ទះបាយឆ្ងាយពីគេឯង ។

វង្សរិទ្ធិឯងចាំស្តាប់ណ៎ា ... រឿងរបស់ណាស៊ីវាមានដើមទងដូចតទៅ :

សំណាង ចាប់ផ្ដើមបើកឆាកនិយាយរឿងរ៉ាវរបស់ណាស៊ីប្រាប់ទៅវង្សរិទ្ធដោយទឹកមុខស្រពាប់ស្រពោន ដែលអ្នកនិពន្ធសូមដកស្រង់ជាសណ្ដាប់នៅវគ្គខាងមុខនេះ ។

~២~

## ស្គាល់គ្នាគ្រាដំបូង

**បានស្គាល់អូនភ្លាមរៀមស្ទើរភ្លឹក ដេកដើរស៊ីផឹកនឹកមមៃ**
**គយគន់លួចលបតាមមើលស្រី ចារក្នុងហឫទ័យឥតបីភ្លេច ។**
**សំឡេងអូនស្រួយដូចសារិកា ភ្នែកអូនខ្មៅថ្លាដូចដំពេជ្រ**
**សុដន់ឡើងស្រួចគួរចង់ច្បិច នឹកហើយចង់ក្ដិចតែថ្ពាល់ស្រី ។**

នៅឱកាសចូលឆ្នាំខ្មែរ ទីក្រុងសៀមរាបទាំងមូលក្លាយទៅជាកន្លែងរមណីយដ្ឋានរបស់ពពួកអ្នកទេសចរគ្រប់សញ្ជាតិ ។ អ្នកទីក្រុង និង អ្នកនៅតាមខេត្តនានា បានមកប្រជុំគ្នាកកកុញ ខ្លះក៏ជួលសណ្ឋាគារនៅ ខ្លះមានបងប្អូនឬញាតិមិត្ត ក៏នាំគ្នាទៅសំណាក់ផ្ទះបងប្អូនទៅ ខ្លះទៀតក៏គ្មានបងប្អូនហើយជួលផ្ទះសំណាក់មិនបាន ក៏នាំគ្នាទៅឈប់សម្រាកក្រោមដើមពោធិ៍មុខអង្គរ ។ ពេល

យប់គេនាំគ្នាចងមុងខ្វាត់ខ្វែង ខ្លះក៏ត្បុលចូលទៅដេកក្នុងឡាន គេសើច, គេច្រៀង, គេនាំគ្នាទៅរាំ៧វង់នៅមុខនាគ ។

ពេលនេះ ក្រមុំកម្លោះមិនសូវប្រកែប្រកាន់គ្នាទេ គេញញឹមដាក់គ្នាហើយងក់ក្បាលឡើងរាំ ។ យុវជន យុវនារីខ្លះដែលមិនបានឡើងរាំ ក៏នាំគ្នាច្រៀងឆ្លេះឆ្លងពាក្យសម្ដី ឆ្លើយឆ្លងគ្នាទៅវិញទៅមកតាមទំនុកបទចម្រៀង នេះជាប្រពៃណីរបស់អ្នកស្រុកសៀមរាប ដែលតែងតែធ្វើឡើងជារៀងរាល់ឆ្នាំ ។

លុះព្រឹកឡើង ទាំងអ្នកនៅក្នុងខេត្ត និងអ្នកនៅក្រៅខេត្ត គេនាំគ្នាឡើងទៅលេងអង្គរតូច, ភ្នំបាក់ខែង , ប្រាសាទបាយ័ន, ស្រះស្រង់, ប្រាសាទតាកែវ ។ ល ។ ដល់ពេលថ្ងៃរសៀលត្រជាក់ ទើបគេទៅប្រមូលផ្ដុំគ្នានៅបឹងបារាយណ៍ទឹកថ្លា ដើម្បីងូតទឹកជំរះរាងកាយឱ្យបានត្រជាក់ ហើយគេក៏ទិញមាន់អាំងមកហែកញ៉ាំលេងវាលខ្សាច់ ដេញប្រឡែកគ្នាដូចជានៅមាត់សមុទ្រកែបដែរ ។

ក្នុងចំណោមមហាជនទាំងនេះ ណាស៊ី និងខ្ញុំក៏បានចូលមករួមសប្បាយនឹងគេដែរ (សំណាងឈប់ស្ងៀមបន្តិចទើបនិយាយតទៅទៀត) ណាស៊ីនិង ខ្ញុំថ្ងៃនេះ យើងទាំងពីរនាក់សប្បាយណាស់ ។ នៅលើផ្ទៃបឹង បារាយណ៍ទឹកថ្លាកូនទូកតូច១ ប្រហែលជាដប់កំពុងអុំប្រណាំងគ្នាបែកទឹកសំពោង អ្នកនៅលើជលយានភាគច្រើន សុទ្ធសឹងតែនារីស្ទើរតែទាំងអស់ ណាស៊ីក្រឡេកឃើញក៏កេះប្រាប់ខ្ញុំ ហើយយើងទាំងពីរនាក់ក៏សម្រេចចិត្តទៅជួលកូនទូកមួយអុំចេញទៅប្រណាំងលេងនឹងហ្វូងនារីទាំងនោះដែរ ។

ខណៈដែលការប្រណាំងទូក កំពុងប្រព្រឹត្តទៅក្នុងបរិយាកាសដ៏សែនសប្បាយនោះ គ្រោះអាក្រក់មួយក៏កើតឡើង ។ កូនទូកតូចផ្ទុកនារីបីនាក់នៅក្រោយគេ ត្រូវរលកបោកខ្លាំង ក៏បណ្ដាលឱ្យផ្ទៀងទឹកចូល ហើយក្រឡាប់លិចមួយរំពេច ។ នារីពីរនាក់ចេះហែលទឹកស្ទាត់ក៏ខំទធាក់ដៃជើងហែលមករកច្រាំង តែមាននារីម្នាក់ទៀត ប្រហែលជានាងមិនចេះហែលទឹកទេមើលទៅកំពុងកញ្ជ្រោលលើកដៃឱ្យគេឯងជួយ បន្ទាប់មកក៏លិចស្រឹមបាត់ទៅក្នុងទឹក ណាស៊ីឃើញដូច្នេះលោតប្រូងទៅក្នុងទឹកស្ទុះហែលទៅជួយស្រង់ជាបន្ទាន់ ។ នៅពេលដែលណាស៊ីលើកស្ទួយនាងផុត ពីជលធា នារីកម្សត់ក៏ផឹកទឹកឆ្អែតហើយសន្លប់បាត់ស្មារតីទៅ ។ ប្រុសកម្លោះដៃម្ខាងឱបប្រាណនារីជាប់ ដៃម្ខាងទៀតប្រឹងហែលសំដៅទៅរកទូក ។

ក្រោយពីបានជួយសង្គ្រោះនាងមកដល់ច្រាំង ឪពុកម្ដាយនាងក៏ស្ទុះមកឱបរឹតកូន ហើយប្រញាប់ប្រញាល់ដាក់ឡានទៅកាន់ពេទ្យសៀមរាបមួយរំពេច ។ ដោយអំណាចភ័យខ្លាំង និងបារម្ភខ្លាចកូនស្លាប់ឪពុកម្ដាយនារីលង់ទឹក

ក៏ភ្លេចអរគុណនឹងណាស៊ី ប្រុសកម្លោះឈរតាម មើលឡានដែលដាក់នារីលង់ទឹកទាល់តែបាត់ស្រមោល ទើបអ្នកដើរមកផ្លាស់សម្លៀកបំពាក់ទទឹក ។

-ម៉េចណាស៊ី អម្បាញ់មិញបែបចំណេញច្រើនមើលទៅ តែគួរឱ្យអាណិតឯងដែរ ដែលឪពុកម្ដាយគេមិនបានមកអរគុណនឹងឯងបន្តិច សោះ។

ខ្ញុំនិយាយចំអន់ណាស៊ី កាលបើឃើញគេមានទឹកមុខបែបមិនសូវស្រស់ ។

ពេលនោះណាស៊ីក៏និយាយទ្រង់មួម៉ៅមកខ្ញុំវិញថា :

-កុំមានមាត់ចេះតែនិយាយផ្ដេសផ្ដាសសំណាង ខ្ញុំចំណេញអ្វីខ្លះ? ឃើញខ្ញុំគ្រាហ៍នាងឡើងពីទឹក សំណាងឯងច្រណែនឬ ? ខ្ញុំជួយនារីគឺជួយដោយស្មោះត្រង់ទេ ! ត្រង់ឪពុកម្ដាយគេអរគុណ ឬមិនអរគុណខ្ញុំក៏គ្មានទោមនស្សអ្វីដែរ !

-ល្អហើយប្រុសចិត្តបុណ្យ ! (ខ្ញុំនិយាយចំអន់ទៅគេទៀត) បំណាច់នឹងយើងជួយសង្គ្រោះគេ គួរណាតែយើងបានសងគុណខ្លះ យ៉ាងហោចក៏គួរតែស្គាល់ឈ្មោះនាងដែរ ។

-មែនសំណាងនិយាយត្រូវ ខ្ញុំភ្លេចសួរឱ្យឈឹង តែ ... មិនដឹងជាសួរយ៉ាងម៉េចកើតផង បើឪពុកម្ដាយគេកំពុងខ្វាយខ្វល់ដូច្នេះ សំណាង... ! (ណាស៊ីទះស្មាខ្ញុំតិចៗ) នារីអម្បាញ់មិញនេះស្អាតណាស់ តាំងពីខ្ញុំចេះដើរលេងមក មិនដែលជួបប្រទះនឹងស្ត្រីរូបស្អាតឥចឹងទេ ប្រហែលជាកូនអ្នកធំ ឬអ្នកមានស្ដុកស្ដម្ភហើយមើលទៅ ...

ខ្ញុំងក់ក្បាលយល់ស្របនឹងគំនិតរបស់ណាស៊ី ។

-ខ្ញុំក៏យល់ដូចណាស៊ីឯងដែរ តើផ្ទះគេនៅឯណាទៅអេះ ? ឬមួយក៏អ្នកមកពីខេត្តក្រៅ ? ណាស់ហើយ យើងកុំគិតពីគេទៀត មកទៅផ្ទះយើងវិញល្ងាចហើយ ។

ថារួច ខ្ញុំក៏បញ្ជិះវេស្ប៉ាណាស៊ីត្រឡប់មកកាន់សៀមរាបវិញ យើងមកដល់ផ្ទះនៅពេលព្រលប់ល្មម ។

ស្អែកឡើង ណាស៊ី និងខ្ញុំខំស្ពាត់ដើររកក្រែងជួបនឹងនារីនោះទៀត តែអត់ប្រយោជន៍សោះ ទោះជាណាស៊ីខំដើររកគ្រប់ទីកន្លែងយ៉ាង ណា ក៏មិនបានជួប ឬយល់ស្រមោលនាងដែរ ។ ទីបំផុតថ្ងៃបុណ្យឱកាសចូលឆ្នាំថ្មីក៏កន្លងហួសទៅ ។ មនុស្សម្នាដែលធ្លាប់តែអ៊ូអរគ្រុកគ្រាក់ទាំងថ្ងៃទាំងយប់ ក៏ប្រែសភាពទៅជាស្ងប់ស្ងាត់ដូចប្រក្រតីឡើងវិញ ។

កម្លោះណាស៊ី តាំងពីថ្ងៃជួយសង្គ្រោះនារីលង់ទឹកនោះមក អ្នកក៏ក្លាយទៅជាមនុស្សស្រងូតស្រងាត់ គិតច្រើន ព្រួយច្រើន ។ ក្លិនខ្លួនស្រស់ស្រីដែលអ្នកបានបីត្រកងពីក្នុងទឹក ហាក់ដូចជានៅថ្មីៗ រង្វង់មុខមូលក្រឡង់ដូចវង់ចន្ទ

របស់នារី បានធ្លាក់ក្នុងបេះដូងគេជាប់ស្អិត ហើយគ្មានពេលណានឹងរលាយទៅវិញទេ ។ ប្រុសកម្លោះចង់ឃើញមុខនាងម្តងទៀត ចង់ស្គាល់ឈ្មោះ, ចង់ស្គាល់សំឡេង, ជាពិសេសចង់បានប្រណយកមកបីបនែ្លងនៃបនិត្យផ្ទាប់ឱរា ឱ្យបានកក់ក្តៅអស់មួយជីវិត ។

មួយខែផុតទៅ ...

ថ្ងៃនេះ ជាថ្ងៃចូលកងវិញ សិស្សានុសិស្សគ្រប់ថ្នាក់រៀបចំខ្លួនប្រាណស្អាតបាត កំពៀតកាតាបសៀវភៅទៅកាន់អាគារសិក្សារៀង១ខ្លួន ដោយមានទឹកមុខញញឹមប្រិមប្រិយ៍ ។ ណាស៊ី និងខ្ញុំក៏ត្រូវចូលរៀនដូចជា កូនសិស្សទាំងពួងដែរ ។

ខណៈដែលយើងទាំងពីរ កំពុងឈរតំរៀបជាជួរជាមួយគេឯង រង់ចាំស្តាប់ការហៅឈ្មោះពីលោកចាងហ្វាងសាលា ដើម្បីទៅកាន់បន្ទប់រៀននោះស្រាប់តែណាស៊ី ក្រឡេកទៅឃើញនារីលង់ទឹក ដែលគេបានជួយសង្គ្រោះកាលពីថ្ងៃមុនឈរនៅក្នុងជួរក្បែរខ្លួនគេជិតបង្កើយ ។ ណាស៊ី ត្រេកអរណាស់គេមិននឹកស្មានថានឹងបានជួបនារីនេះទៀតសោះ ។ ប្រុសកម្លោះចង់និយាយរាក់ទាក់ទៅរកនាង ចង់ណែនាំឱ្យនាងស្គាល់ច្បាស់ថា គេហ្នឹងហើយជាអ្នកជួយសង្គ្រោះនាងឱ្យផុតពីសេចក្តីស្លាប់កាលពីថ្ងៃចូលឆ្នាំខ្មែរ ដែលទើបនឹងកន្លងផុតទៅ តែហើយគេក៏មិនហ៊ាន ដោយនឹកខ្លាចខុសក្រិត្យវិន័យសាលានិងជាការមិនគាប់ភ្នែកអ្នកទូទៅផង ។ ណាស៊ីទ្រាំអត់សង្កត់ចិត្តរហូតដល់ពេលចេញពីរៀន ។ គ្រាន់តែផុតរបងសាលាភ្លាម ណាស៊ីជិះកង់មកទន្ទឹមនាងជាប់ ពេលមួយគេក៏ដាច់ចិត្តសួរទៅនាងថា :

-អត់ទោស អ្នកនាងនៅចាំខ្ញុំបានទេ ?

នារីធ្វើភ្នែកឡឹងឡង់ ដោយនាងនឹកមិនឃើញថា តើបុរសនេះស្គាល់នាងពីកាលណា ? ចំពោះនាង១មិនដែលស្គាល់បុរសនេះទាល់តែសោះមែន ...បានជានាងមិនស្គាល់ព្រោះពេលដែលណាស៊ី លោតទៅជួយស្រង់នាងពីក្នុងទឹកពេលនោះនាងសន្លប់បាត់ស្មារតីទៅហើយ ។

ក្រោយពីការអឹមអៀន និងនឹកងឿងឆ្ងល់មក នារីក៏ដាច់ចិត្តឆ្លើយទៅណាស៊ីវិញ ដោយសំឡេងទន់ភ្លន់ញញឹមយ៉ាងសុភាពថា :

ចាំះ អត់ទោស ខ្ញុំដូចជាភ្លេចទៅហើយ តើលោកស្គាល់ខ្ញុំយូរហើយឬ ?

ណាស៊ីប្រញាប់ឆ្លើយទៅយុវ នារីរូបស្រស់វិញទាំងញញឹមពព្រាយ :

-បាទ កាលពីចូលឆ្នាំខ្មែរ អ្នកនាងលិចទូកនៅបារាយណ៍ ខ្ញុំនេះឯងជាអ្នកលោតទៅជួយគ្រាហ៍អ្នកនាងឡើងគោក ។

-អូ ! បងនឹងឬ ! ( ស្រស់នារីភ្ញាត់សំឡេងចេញមកដោយនាងត្រេកអរហួសប្រមាណ) ខ្ញុំសូមអរគុណបងអស់មួយជីវិត ថ្ងៃនោះបើកុំបានបងលោតទៅជួយស្រង់ខ្ញុំ ប្រហែលជាខ្ញុំត្រូវបាត់បង់ជីវិតទៅហើយ ក្រោយមកខ្ញុំដឹងខ្លួនវិញ ខ្ញុំសួរប៉ាម៉ាក់រកអ្នកដែលជួយខ្ញុំដែរ តែគាត់ប្រាប់ថា ស្តាយណាស់ដោយភ័យនឹងខ្ញុំខ្លាំងពេកក៏មិនបានអរគុណ និងមិនបាន ចំណាំមុខអ្នកជួយខ្ញុំនោះទាល់តែសោះ ។

-បាទ មិនបាច់អរគុណស្រ័យអ្វីច្រើនពេកទេអ្នកនាង នេះក៏វាជាភារៈរបស់មនុស្សដែលត្រូវជួយសង្គ្រោះមនុស្សទេតើ ?

តាមពិត ណាស៊ីគ្រាន់តែឮគេថាអរគុណមួយជីវិត អ្នកសប្បាយចិត្តស្ទើរនិងលោតបញ្ឆេង ឱ្យបាក់កង់ទៅហើយ តែគេខំសម្រួលទឹកមុខធ្វើហាក់ដូចជាការធម្មតាទៅវិញ ។

ក្រោយពីឈប់ស្ងៀមបន្តិច យុវនារីផ្តើមសួរទៅណាស៊ីទៀតថា :

-អត់ទោស បងឈ្មោះអ្វីទៅ ? ហើយរៀននៅថ្នាក់ណាដែរ ?

-បាទ ខ្ញុំអា ... ឈ្មោះណាស៊ី ផ្ទះខ្ញុំនៅចុងស្ពានថ្ម ខ្ញុំរៀននៅថ្នាក់ទី១ ទំនើប (Classe de 1e're MN ) អ្នកនាង តើអ្នកនាងឈ្មោះអ្វីដែរទៅ ? ហើយរៀននៅថ្នាក់ណា ? ព្រោះតាមខ្ញុំស្មានទៅអ្នកនាងមិនមែនអ្នកស្រុកសៀមរាបទេ ។

-ខ្ញុំរៀននៅថ្នាក់តូចជាងបងឆ្ងាយណាស់ ( នារីមើលមុខណាស៊ី ហើយឱនមុខចុះទ្រង់អឹមអៀន ) ខ្ញុំរៀននៅថ្នាក់ទី ៤ ទំនើប ខ្ញុំឈ្មោះ សោភិនីហើយស្រុកកំណើតខ្ញុំនៅកំពង់ធំឯណោះ តែលោកឪពុកខ្ញុំត្រូវរាជការផ្លាស់មកនៅខេត្តសៀមរាប ខ្ញុំក៏ត្រូវមកនៅរៀនជាមួយគាត់ឯណេះទៅ ។

អុំ ... ! បើតចឹងយើងអ្នកស្រុកជាមួយគ្នាទេតើ អ្នកនាង ខ្ញុំក៏អ្នកស្រុកកំពង់ធំដែរ តែគ្រួសារខ្ញុំបានមកនៅរកស៊ីឯសៀមរាបនេះយូរហើយ លុះលោកឪពុកខ្ញុំទទួលអនិច្ចកម្មផុតទៅ ម្តាយខ្ញុំក៏ចង់វិលទៅស្រុកវិញ ហើយក៏នៅសៀមរាបជាប់រហូតមកទល់សព្វថ្ងៃនេះ ។

-កាលបងនៅកំពង់ធំ តើនៅម្តុំណាដែរ ? ខ្ញុំដូចជាមិនដែលប្រហាក់ប្រហែលមុខបងសោះ ។

ណាស៊ីញញឹមទទួលសំណួរសោភនីបន្តិចទើបគេវាចាថា :

-កាលខ្ញុំនៅកំពង់ធំ ខ្ញុំនៅម្តុំភូមិអាចារ្យលាក់ណាអ្នកនាង ពេលនោះបើទោះជាអ្នកនាងធ្លាប់ឃើញខ្ញុំក៏រកចំណាំមិនបានដែរ ព្រោះយើងនៅតូចៗណាស់ ។

កង់ទោចក្រយានចេះវិលទៅមុខឥតអាក់ រីឯការសន្ទនាវវាងអ្នកកម្លោះណាស៊ី និងកញ្ញាសោភិនីក៏រឹតតែស្និទ្ធស្នាលខ្លាំងឡើងជាលំដាប់ ។ មិន

យូរប៉ុន្មានទោចក្រយានទាំងគូក៏មកដល់ស្ពានថ្ម ណាស៊ីដឹងវាជិតដល់ផ្ទះ ហើយគេក៏និយាយលាទៅសោភិនីថា :

-អ្នកនាង ខ្ញុំសូមបត់ទៅតាមស្ពានថ្មហើយនុ៎ះនន់ ! ផ្ទះខ្ញុំ ។

ណាស៊ី ចង្អុលប្រាប់សោភិនីឱ្យស្គាល់ផ្ទះរបស់គេ ។ សោភិនី ក្រឡេកមើលទៅតាមដៃគម្លោះ រួចនាងបែរមកនិយាយជាមួយណាស៊ីវិញថា :

-ចាំ ចាំថ្ងៃណាមានឱកាស ខ្ញុំនិងទៅស្គាល់ផ្ទះបងហើយស្អែកបងត្រូវតែទៅលេងផ្ទះខ្ញុំជាដាច់ខាត ពីព្រោះឪពុកម្តាយខ្ញុំគាត់ចង់ស្គាល់បង ណាស់

-បាទអរគុណច្រើនណាស់អ្នកនាង ។

និយាយរួច ណាស៊ីក៏ជិះកង់បត់ទៅតាមស្ពានថ្មទៅ ចំណែកសោភិនីនាងត្រូវជិះកង់តទៅទៀត ពីព្រោះផ្ទះនាងនៅឯភូមិវត្តស្វាយឯណោះ ។

ព្រឹកស្អែកឡើង ក្រោយពេលចុះពីសាលារៀន សោភិនីក៏នាំ ណាស៊ីទៅលេងផ្ទះនាង ។

យុវតី បាននិយាយរៀបរាប់រឿងណាស៊ីជួយសង្គ្រោះនាងពីថ្ងៃមុនជំរាបឪពុកម្តាយយ៉ាងល្អិតល្អន់  លោកភិរុណ និងលោកស្រីទទួលរាក់ទាក់និងត្រេកអរណាស់ កាលបើដឹងថា ណាស៊ីជាអ្នកជួយសង្គ្រោះកូន លោកឱ្យរួចពីការលង់ទឹកស្លាប់ ។

-ខ្ញុំមិនភ្លេចគុណក្មួយទេ ដែលបានជួយសង្គ្រោះជីវិតកូនខ្ញុំ ( លោកភិរុណនិយាយទៅណាស៊ី) ថ្ងៃនោះ ខ្ញុំវាភ័យខ្លាំងពេក ក៏ភ្លេចអរគុណក្មួយទាល់តែជីកសោភិនីទៅដល់ពេទ្យទើបខ្ញុំនឹកឃើញក្មួយឯង ខ្ញុំនិង ម៉ាក់វាចង់វិលមករកក្មួយវិញដែរ តែខ្ញុំវាភ្លេចចំណាំមុខក្មួយទៅទៀត ឥឡូវបានស្គាល់គ្នាហើយសូមក្មួយអភ័យទោសឱ្យខ្ញុំផង ។

-បាទ ខ្ញុំមិនដែលនឹកគិតពីរឿងគុណស្រ័យអ្វីទេលោកអ៊ំ ផ្ទុយទៅវិញខ្ញុំត្រេកអរណាស់ដោយបានស្គាល់លោកអ៊ំទាំងពីរ និងបានលោកអ៊ំរាប់អានខ្ញុំយ៉ាងដូច្នេះ ។

កាយវិការសុភាពរាបសា និងសម្តីទន់ភ្លន់របស់ណាស៊ី ធ្វើឱ្យលោកស្រីពន្លកពេញចិត្ត និងស្រឡាញ់អ្នកក្រៃលែង ។

លោកស្រីញញឹមមើលមុខណាស៊ីបន្តិច ហើយក៏មានប្រសាសន៍មួយៗថា :

-ទោះបីក្មួយមិនត្រូវការគុណស្រ័យអ្វីពីខ្ញុំក៏ដោយ ក៏ខ្ញុំត្រូវតែជូនរង្វាន់ដល់ក្មួយខ្លះដែរ ហើយជាពិសេស ខ្ញុំសូមប្រាប់ក្មួយដោយត្រង់ថា ខ្ញុំពេញចិត្តនឹងឫកពារសុភាពរាបសាររបស់ក្មួយណាស់ បើក្មួយមិនយល់ទាស់ទេខ្ញុំសូមជូនប្រាក់ក្មួយប្រាំពាន់រៀល គ្រាន់ទុកចាយវាយទិញសៀវភៅសម្រាប់រៀនសូត្រ ។

និយាយចប់ លោកស្រីពន្លកក៏ដកលុយពីក្នុងកាបូបមួយដុំធំហុចទៅឱ្យណាស៊ី ។ ប្រុសកម្លោះមិនហ៊ានទទួលភ្លាមទេ អ្នកនឹករារែកក្នុងចិត្ត ខ្លាចក្រែងគេថាជួយសោភិនីដើម្បីទារសគុណ ។ តែដោយលោកប្រុស លោកស្រីនិង សោភិនីចេះតែបង្ខំពេក អ្នកក៏ព្រមទទួលយកទាំងទើសទាល់ក្នុងចិត្ត ។

ខ្ញុំបាទ សូមអរព្រះគុណនឹងចិត្តមេត្តាធមិរបស់លោកអ៊ំទាំងពីរជាទីបំផុត ។

-មិនបាច់អរគុណខ្ញុំទេក្មួយ ( លោកភិរុណនិយាយ) តាមពិតខ្ញុំគួរតែអរគុណក្មួយវិញទេតើ ប្រាក់ប្រាំពាន់នេះ វាមិនធួនល្មមនឹងគុណដែលក្មួយមានមកលើកូនខ្ញុំផង ។

ពេលនោះ សោភិនីក៏យកផ្លែឈើនិងទឹកក្រូចមកជូនណាស៊ី ។

-អញ្ជើញញុំាទឹកក្រូច និងផ្លែមៀននេះទៅបង ។

-បាទ ! បាទ ! អរគុណអ្នកនាង ។

ណាស៊ីប្រញាប់ទទួលកែវទឹកក្រូចពីដៃសោភិនីយកមកកាន់ ។

លោកភិរុណ សង្កេតពិនិត្យពិច័យណាស៊ីតាំងពីក្បាលរហូតចុងជើងទាំងសម្តីសំដៅ, ទាំងឫកពា សរបញ្ជាក់ឱ្យដឹងថា ណាស៊ីជាកូនអ្នកមានពូជពង្សថ្លៃថ្នូរ ហើយបានទទួលការអប់រំពីអ្នកអាណាព្យាបាលយ៉ាងហ្មត់ចត់ ។

កាលបើឃើញប្រុសកម្លោះផឹកទឹកក្រូចអស់បន្តិចហើយ លោកក៏ផ្តើមសួរទៅទៀតថា :

-ផ្ទះក្មួយឯងនៅឯណា ? ឪពុកម្តាយធ្វើការអ្វីដែរ ? ហើយសព្វថ្ងៃក្មួយរៀនសូត្រដល់ថ្នាក់ណាហើយ ?

ណាស៊ីដាក់កែវទឹកក្រូចលើតុ គេហូតកូនកន្សែងមកជូតមាត់ព្រមទាំងវាចាទៅលោកភិរុណដោយទន់ភ្លន់ថា :

-បាទលោកអ៊ំ ឪពុកម្តាយខ្ញុំគាត់ជាអ្នកជំនួញទេ តែសព្វថ្ងៃលោកឪពុកខ្ញុំគាត់ទទួលអនិច្ចកម្មទៅហើយ ផ្ទះខ្ញុំនៅចុងស្ពានថ្មនៅឯណោះ ចំណែកការសិក្សាវិញ ឆ្នាំនេះរៀននៅថ្នាក់ទី១ (Classe de 1e’re M.N)

លោកភិរុណបើកភ្នែកធំៗ ដោយលោកមិននឹកស្មានថាណាស៊ី រៀនដល់ថ្នាក់ខ្ពស់ដូច្នេះ ។

-អូ ! រៀនថ្នាក់ទី ១ ? បើតចឹងឆ្នាំក្រោយក្មួយត្រូវប្រឡងយកមធ្យមសិក្សាប័ត្រហើយមែនទេ ?

-បាទ លោកអ៊ំ ...

-ដល់ក្មួយប្រឡងជាប់ ក្មួយមានគោលបំណងនឹងប្រឡងចូលធ្វើការរាជការក្នុងក្រសួងណាដែរ ?

-បាទលោកអ៊ំ (ណាស៊ីឆ្លើយទៅលោកភិរុណទ្រង់អឹមអៀន) បើខ្ញុំប្រឡងជាប់ ខ្ញុំគ្មានបំណងទាមទារកៅអីក្នុងក្រសួងណាមួយទេ ខ្ញុំតាំងចិត្តថានិងប្រកបរបរកសិកម្មវិញ ។

លោកភិរុណ យកដៃច្បូតសក់ ព្រមទាំងគ្រវីក្បាលដោយមិនពេញចិត្តនឹងបំណងរបស់ណាស៊ី ។

-ក្មួយគិតដូច្នេះមិនត្រូវទេ នេះខ្ញុំស្រឡាញ់ក្មួយហើយបានជាដាស់តឿនណា បើក្មួយប្រឡងជាប់មធ្យមសិក្សាប័ត្រហើយបែរទៅកាន់នង្គ័លធ្វើស្រែចម្ការវិញ មធ្យមសិក្សាប័ត្ររបស់ក្មួយវាមិនអស់តំលៃទៅហើយ ? ចុះក្មួយខំរៀនអស់រយៈពេលជាងដប់ឆ្នាំកន្លងទៅ វាមិនខាតលុយកាក់ទទេៗទៅទៀត ។ មើលរូបខ្ញុំជាតួយ៉ាង ខ្ញុំពីក្មេងរៀនមិនបានទាំងឪបួមឪផ្លាំងអីផង ខ្ញុំខំប្រឡងចូលធ្វើការទាល់តែបានធ្វើមន្ត្រីយ៉ាងធំដុំ ដូចក្មួយឃើញស្រាប់ ដល់ឥឡូវលទ្ធផលវាហុចឱ្យខ្ញុំស្រណុកកាយ សប្បាយចិត្តលែងភ័យពីរឿងមានក្រ ដាច់ខែបើកលុយទាំងបាច់ៗ គ្មានទៅហត់នឿយធ្វើស្រែចម្ការឈរហាលថ្ងៃក្ដៅអីសោះ ។

សម្ដីដាស់តឿនទូន្មានរបស់លោកភិរុណទាំងប៉ុន្មាន មិនបានធ្វើឱ្យ ណាស៊ីរំភើបចិត្តទេ ផ្ទុយទៅវិញគេនឹកស្អប់នឹងគំនិតគ្រួសារនិយមនេះណាស់តែដោយនឹកខ្លាចចិត្តលោកភិរុណ និងស្រឡាញ់នាងសោភិនីជាដើមទុនស្រាប់ផងណាស៊ីក៏ឆ្លើយតបទៅលោកភិរុណវិញ ទាំងទើសទាល់ កោតក្រែងចិត្តថា :

-ខ្ញុំសូមអរព្រះគុណលោកអ៊ំជាទីបំផុត ដែលបានពន្យល់ឱ្យខ្ញុំមានអនាគតថ្កុំថ្កើងទៅថ្ងៃមុខ តែពេលនេះខ្ញុំមិនទាន់ចង់ធ្វើការរាជការទេ លោកអ៊ំពីព្រោះដីស្រែឪពុកម្ដាយខ្ញុំក៏សល់ច្រើន ណាមួយទៀតខ្ញុំយល់ថា អ្នកស្រែចម្ការក៏ត្រូវតែមានចំណេះវិជ្ជាខ្ពង់ខ្ពស់ស្មើនឹងអ្នករាជការដែរ ។ ប្រទេសឯករាជ្យនិមួយៗ បើមានចំណេះវិជ្ជាចំពោះតែអ្នករាជការ ហើយទុកឱ្យពលរដ្ឋល្ងង់ខ្លៅប្រទេលនោះក៏មិនចម្រើនទៅមុខបានដែរ ? លោកអ៊ំគិតមើល សព្វថ្ងៃសម្ដេចឪយើង ព្រះអង្គខំខ្នះខ្នែងគ្រប់វិស័យ ដូចជា កសាងស្ពានថ្នល់, សាលារៀន, រោងចក្រធំៗ, ដឹកនាំស្រែកអំពាវនាវឱ្យប្រជាពលរដ្ឋទាំងបុរសស្ត្រីគ្រប់ទិសទីជនបទ ខំរៀនអក្សរឱ្យបានចេះដឹងគ្រប់ៗគ្នាឡើងទាំងនេះ គឺប្រយោជន៍ឱ្យប្រទេសយើងឈានទៅរកវឌ្ឍនភាព កុំឱ្យធ្លាក់ខ្លួនទៅជាខ្ញុំកញ្ជះបាតជើងក្រពត្តិនិយមដូចជា ប្រទេសជិតខាងយើងណាលោកអ៊ំ ។

លោកភិរុណស្ពឹកមុខ ស៊ើចលែងសម ។ មន្ត្រីចាស់ដឹងខ្លួនថាត្រូវថ្លែរបស់ណាស៊ីហើយ លោកភ្ញាក់ស្មារតី មិននឹកស្មានថាយុវជនសម័យនេះមានឧត្ដមគិតថ្លៃថ្នូរដូច្នេះសោះ ។

ក្រោយពីអង្គុយស្ងាត់ស្ងៀមមួយសន្ទុះលោកភិរុណ ក៏ប្រែបទសន្ទនានិយាយពីរឿងអីផ្សេងៗទៅវិញ ។

-អា ... ខ្ញុំយល់ថាក្មួយត្រូវតែមកលេងផ្ទះខ្ញុំឱ្យបានញឹកញាប់កុំខ្លាចកោតក្រែងចិត្តអ្វីឱ្យសោះ ចូរក្មួយគិតថាផ្ទះនេះជាផ្ទះរបស់ក្មួយទៅចុះ ហើយថ្ងៃនេះខ្ញុំក៏មិនទាន់ឱ្យក្មួយត្រឡប់ទៅផ្ទះវិញភ្លាមទេ នៅញ៉ាំបាយជាខ្ញុំមួយពេលសិនណា៎ ។

-មែនហើយបងណាស៊ី ត្រូវតែនៅញ៉ាំបាយផ្ទះខ្ញុំមួយពេលសិនទើបសុខចិត្ត ។

សោភិនី និយាយកាត់ពាក្យលោកភិរុណ ហើយក៏ក្រោកដើរទៅកាន់ផ្ទះបាយ រៀបចំធ្វើម្ហូបអាហារ ទុកឱ្យលោកឪពុកអ្នកម្តាយនាងសន្ទនាជាមួយណាស៊ីតទៅទៀត ។

ក្រោយពីបរិភោគអាហាររួច អង្គុយលេងសំណេះសំណាលបន្តិចមកណាស៊ីក៏សូមលាសោភិនី និងលោកប្រុសលោកស្រីត្រឡប់ទៅផ្ទះខ្លួនវិញ ។

ថ្ងៃខែរត់លឿនទៅមុខដូចផ្លេព្រួញ រីឯការវិវឌ្ឍន៍របស់មនុស្ស លោកក៏ចេះតែប្រែទៅតាមកាលៈទេសៈ ចាប់តាំងពីថ្ងៃណាស៊ីបានទៅលេងផ្ទះនាងសោភនីម្តងមក ចំណងមិត្តភាពរវាងក្រមុំកម្លោះគូនេះ ក៏មានសន្ទុះនឹងរីកធំឡើងជាលំដាប់ ។ មិត្តភក្តិដែលធ្លាប់ស្គាល់ណាស៊ី និង សោភិនី នាំគ្នាបូញមាត់បូញក ខ្លះក៏នឹកច្រណែនឥច្ឆា រហូតដល់ទៅហ៊ាននិយាយថា ណាស៊ី និងសោភិនីជាសង្សារគ្នាទៅហើយ ។ មែន ... សម ពាក្យគេនិន្ទាមិនខុស ដែលមានឬក្រមុំនិងកម្លោះជាពួកម៉ាកនឹងគ្នា ? មិនយូរប៉ុន្មាន ចំណងមិត្តភាពក្លែងក្លាយ ដែលមានសរកាមទេពចាំជួយរុកឆ្មៀលបេះដូងក្រមុំកម្លោះ ជារៀងរាល់ថ្ងៃនោះ ក៏ប្រែសភាពរូបរាងមកជាចំណងស្នេហាវិញ ។

~៣~

## ចំណងស្នេហា

| | |
|---|---|
| ចំណងស្នេហាកើតឡើងហើយ | ទ្រូងអើយសប្បាយអ្វីម្ល៉េះទេ |
| ស្លាប់រស់ព្រោះលើនួនមាសមេ | រូបកាយបងផ្ទេរជូនទាំងអស់ ។ |
| បងសូមតែចិត្តអូនស្មោះត្រង់ | កុំឱ្យបោះបង់បងឱ្យសោះ |

មានក្រធ្វើម្ដេចទ្រាំទៅចុះ                ខ្លួនរៀមជាប្រុសសូមធានា ។

ព្រឹកថ្ងៃមួយ ជាថ្ងៃអាទិត្យ ណាស៊ី និងសោភិនីបាននាំគ្នាទៅលេងភ្នំក្រោម ។ ក្រមុំកម្លោះទិញបាយខ្ចប់ស្លឹកឈូក និងមាន់អាំងពីរបីចង្កាក់យកទៅញ៉ាំលើកំពូលភ្នំ ។

នៅតាមដងផ្លូវពីសៀមរាបទៅភ្នំក្រោម ដែលមានចម្ងាយជាង ដប់គីឡូម៉ែត្រ យុវជន យុវតី នាំគ្នាធាក់កង់ក្នុងល្បឿនមធ្យមក្រោមកំដៅសូរ្យសែងនៃព្រះអាទិត្យ ។ សង្សារថ្មីជិះកង់មិនឱ្យឃ្លាតឆ្ងាយពីគ្នាទេ ពាក្យអូន បង បានរអិលចេញពីមាត់អ្នកទាំងពីរ ដូចគ្រាប់ភ្លៀងហូរតាមទឹកក្នុងពេលភ្លៀងខ្លាំង បងអ្ហា ... ! អូនអើយ ... ! គ្មានដាច់សូរ ។ ជួនកាលគេបែរមកញញឹមដាក់គ្នា គេសើច, គេសម្លក់, គេធ្វើជាងរ មុខក្រញូវដូចជាខឹងគ្នាមួយរយឆ្នាំមកហើយ ផុតពីនោះ គេក៏ច្រៀងលើកទំនុកឆ្លោះឆ្លងគ្នាទៅវិញទៅមក ។ គិតពិចារណាឱ្យសព្វៗទៅ ណាស៊ី និង សោភិនីពេលនេះ មិនខុសប្លែកពីត្រីក្រឹមដំឡើងស្រកាអួតដាក់គ្នាមុនពេលប្រជល់ទេ ។

ឱហ៎ ... ! សេចក្ដីស្នេហាមានឥទ្ធិពលខ្លាំងក្លាណាស់ ។ ថ្ងៃមុខឡើងខ្លាញ់រងើម ញើសជោកអស់ទាំងខ្លួនដូចជាគេងូតទឹក តែ ... អ្នកទាំងពីរគ្មានដឹងខ្លួនថាក្ដៅ ឬហត់នឿយអ្វីបន្តិចសោះ គេរវល់តែសប្បាយនឹងស្នេហាភ្លេចហត់, ភ្លេចរោយជើង, ភ្លេចអ្វីៗទាំងអស់នៅក្នុងលោក ចាំបានតែម៉្យាងគឺរូបគេពីរនាក់ប៉ុណ្ណោះ ។

ម៉ោង ១១ គត់ ណាស៊ី និងសោភិនីក៏បានទៅដល់ភ្នំក្រោម ។ ក្រោយពីផ្ញើកង់នឹងផ្ទះអ្នកស្រុកស្រួលបួលហើយ ណាស៊ីក៏ដឹកដៃស្រស់នារី ដួងចិត្តរបស់គេ ឡើងជណ្ដើរថ្មទៅលេងខាងលើកំពូលភ្នំ ។

ខ្យល់ភ្នំ បក់រំភើយៗ ធ្វើឱ្យត្រជាក់ស្រួលអ្វីម្ល៉េះទេ អាកាសក្ដៅ ស្អុះស្អាប់ពីមុនៗ មកអន្តរធានបាត់អស់រលីង ។ ព្រឹក្សាលតាវល្លិទាំងឡាយលូតលាស់សន្លឹកខៀវខ្ចីបកស្លឹករវិចៗយ៉ាងស្រស់ញញឹម ។ ក្រឡេកមើលទៅក្រោមឃើញវាលស្រែក្រឡាតូចៗ ដូចជាក្រឡាចត្រង្គ ហើយនៅឆ្ងាយឯនាយនោះ ខ្សែទឹកវែងអន្លាយជាប់នឹងជើងមេឃគឺជាបឹងទន្លេសាប ។

ណាស៊ីនាំសង្សារទៅអង្គុយលើផ្ទាំងសិលាមួយ ប្របដើមជ្រៃក្រឹមភ្នែកគេរំពៃគយគន់មើលទេសភាពជុំវិញខ្លួនយ៉ាងជក់ចិត្ត ។ វាតាបក់បោកមកប្រឡែងនឹងសក់អ៊ិតវែងអន្លាយរបស់សោភិនី ធ្វើឱ្យសក់នាងរសាត់ចុះ រសាត់ឡើងដូចជារលកទឹក ហើយក៏ស្រាប់តែប៉ើងមកគ្របមុខនាងជិត ប្រុសកម្លោះប្រញាប់យកដៃទៅច្បួតសក់នាងឱ្យមកក្រោយដូចធម្មតា វិញ ។

-អូនសោភិនី អូនកំពុងអង្គុយគិតពីរឿងអ្វីហ្នឹង ?

សោភនី បែរខ្នាប់មកញញឹមដាក់ណាស៊ី រួចនាងនិយាយថា :

-ចុះបងអម្បាញ់មិញកំពុងបណ្តែតអារម្មណ៍ទៅឯណាដែរ ?

-ម្តេចក៏អូនសួរបងតចឹង ? ទាំងកាយ, ទាំងចិត្តដួងព្រលឹង សព្វថ្ងៃសណ្ឋិតលើរូបអូនទាំងអស់ហើយទេតើ បងគិត, បណ្តែតអារម្មណ៍,ក៏ដើម្បីរកផ្លូវដោះស្រាយអនាគតយើងទាំងពីរនាក់ណាអូន ។

ថាហើយ ណាស៊ីក៏ចាប់ទាញខ្លួនសោភិនីឱ្យមកគៀកជិតគេ ។

-ចុះបងនៅចាំគិតអ្វីទៀត (សោភិនីនិយាយ) ឬមួយបងខ្លាចអូនចិត្តមិនស្មោះត្រង់ ?

-មិនមែនតចឹងទេអូន បងយល់ច្បាស់ថាអូនប្រាកដជាស្រឡាញ់បងហើយ តែថា ... ! វណ្ណៈយើងវាខុសគ្នាឆ្ងាយណាស់ណាអូន បងជាកូនអ្នកក្រ រីឯអូនវិញជាកូនលោកមន្ត្រីទ្រព្យសម្បត្តិក៏ស្តុកស្តម្ភ ជាពិសេសយើងស្រឡាញ់គ្នានេះ លោកឪពុកអ្នកម្តាយអូនក៏លោកអត់ទាន់បានជ្រាបសោះ បងខ្លាចថ្ងៃក្រោយលោតែលោកជ្រាបហើយ មិនព្រមឱ្យយើងទាំងពីររៀបការ បងមុខជាប្រេះទ្រូងស្លាប់ជាប្រាកដ ... ។

ណាស៊ីដកដង្ហើមធំធ្វើមុខក្រៀមផ្អេះ ។ សោភិនីញញឹម យកដៃទាំងពីរទៅឱបចង្កេះណាស៊ីប្រលោមចិត្តប្រុសស្នេហ៍នាង ។

-អូនស្មានតែរឿងអ្វីធំដុំ រឿងតចឹងទេឬ ? ស្នេហាអត់ប្រកាន់វណ្ណៈទេបង សុភមង្គលកើតឡើងក៏មិនមែនមកពីទ្រព្យសម្បត្តិដែរ រឿង ក្រឬមានមិនជាការសំខាន់សំរាប់ស្នេហាបរិសុទ្ធទេ សូមបងកុំយករឿងអពមង្គលនេះមកគិតទៀត ។

-នេះចំពោះតែចិត្តអូន ? (ណាស៊ីនិយាយដោយមិនទាន់អស់ចិត្ត) ចុះឧបមាថា បងចូលស្តីដណ្តឹងអូនតែឪពុកម្តាយអូនមិនព្រមឱ្យ ហើយបែរជាយកអូនទៅរៀបការជាមួយអ្នកណាផ្សេងទៅវិញ តើអូនគិតយ៉ាងម៉េច ?

-គ្មានពិបាកគិតអ្វីទេបង អូននឹងមិនព្រមទទួលអ្នកណាក្រៅពីរូបបងមួយជាដាច់ខាត ចំណែកឪពុកម្តាយអូនលោកជាអ្នកចេះដឹងទាន់សម័យនឹងគេដែរ លោកមិនមែនចិញ្ចឹមកូនទុកលក់ដូចជាជ្រូកទេបង ក៏មិនមែនជាអ្នកទីទាល់ថោកទាបឯណា ? ចំណេះវិជ្ជារបស់បងវាថ្លៃថ្នូរជាងទ្រព្យសម្បត្តិទៅទៀត ឆ្នាំនេះបើបងប្រឡងមធ្យមសិក្សាប័ត្រជាប់ បងក៏អាចចេញទៅរកការងារធ្វើបានដោយងាយ ហើយឪពុកម្តាយអូនក៏មុខជាពេញចិត្តចំពោះបងជាមិនខាន សូមបងឈប់ព្រួយទៅបងណា (សោភិនី យកដៃទៅអង្អែលចង្កាណាស៊ីដោយសេចក្តីស្រឡាញ់លាយឡំនិងការអាណិត) បងគិតតែពីខំរៀនសូត្រឱ្យមែនទែនទៅ អូនមិនក្បត់ចិត្តបងទេ ក្នុងជាតិនេះសោភិនី សូមប្រគល់បេះដូងនិងកាយចំពោះតែបងណាស៊ី ម្នាក់ប៉ុណ្ណោះ ។

និយាយរួច សោភិនីក៏ប្រាសខ្លួនដេកកើយភ្លៅប្រុសស្នេហ៍ ។

ណាស៊ីបានស្គាល់វាចារបស់សង្សារសែនត្រជាក់ចិត្ត លែងភិតភ័យ លែងព្រួយបារម្ភទៀតហើយ គេគិតថាចាប់ពីថ្ងៃនេះទៅត្រូវតែខំរៀនមួយទ្វេជាពីរ ដើម្បីយកមធ្យមសិក្សាប័ត្រមកឱ្យសោភិនីខាងតែបាន ។

-សោភិនីអូន ... !

-ចាំះ បង ... !

-ក្នុងជាតិនេះ បងជាមនុស្សមានសំណាងធំណាស់ ហើយប្រហែលជាគ្មានអ្នកណាមានភ័ព្វវាសនា បានប្រពន្ធស្អាតដូចជារូបបងទេ មើលទៅ... ដើម្បីឱ្យសមនឹងរង្វាន់ដ៏គាប់ប្រសើរនេះ បងត្រូវតែខំរៀន ប្រឡងយកមធ្យមសិក្សាប័ត្រ មកបង្អួតអូនទាល់តែបានមែនទេអូននី ?

សោភិនីក្ដិចភ្លៅណាស៊ីតិច១ ព្រមទាំងសើចបញ្ចេញធ្មេញសស្គុះដូចភ្លុក ។ គ្រប់ម៉ាត់របស់ណាស៊ីធ្វើឱ្យនារីរីករាយក្នុងហឫទ័យឥតឧបមា ។

-កុំបញ្ជោរអូនខ្លាំងពេក !... ដំបូងវាចេះតែឃើញល្អឃើញស្អាតឥចឹងហើយ ដល់យូរនឿយណាយទៅ ពាក្យផ្អែមល្ហែមទាំងនេះក្រែងវាមិនស្ថិតស្ថេរណាបង ពាក្យប្រុសគេថាផ្អែមជាងទឹកឃ្មុំទៅទៀត ហើយបើនិយាយពីស្មោគ បោកប្រាសវិញ ស្រី១ដេញជើងមិនទាន់ទេ ។

-កុំនិយាយឥចឹងអូន "ណាស៊ីប្រញាប់ប្រកែកដំឡើងភ្នែកធំ១ដាក់សោភិនី" ដូងមួយធ្លាយគង់មានតក់មានទាឡិ ត្រីមួយត្រកមិនមែនស្អុយទាំងអស់ទេ ចំណែកប្រុស១ក៏គេមានល្អគគោកដែរ ត្រង់ស្រី១អាក្រក់ម្ដេចក៏អូនមិនលើកយកមកនិយាយផង ?

សោភិនីក្រោកអង្គុយសម្លក់ថ្ងៃរទៅណាស៊ី ។

-ត្រង់ស្រីណាអាក្រក់ខ្ញុំមិនដឹងដែរ ! ព្រោះខ្ញុំមិនបានឃើញ តែចំពោះស្រីខ្ញុំល្អណាស់ ។

-ប្រុសយ៉ាងបងក៏ល្អដែរ (ណាស៊ីឆ្លើយយ៉ាងរហ័ស) អូនយកបងទៅប្រដូចនឹងប្រុសខិលខូចឯទៀតម្ដេចនឹងកើត បងមិនមែនជាព្រាននារីទេ ហើយបើសិនបងព្រានវិញ ក៏ព្រាននារីចំពោះលើរូបអូនម្នាក់ប៉ុណ្ណោះ ។

-ថ្លង់ណាស់ឈប់និយាយទៅ ... !

សោភិនី យកដៃចុកត្រចៀក ងរមុខក្របូរខិតមកអង្គុយឆ្ងាយពី ណាស៊ី ។

រឹតតែងរក៏រឹតគួរឱ្យស្រឡាញ់ខ្លាំងឡើង រាងដ៏ល្វតល្វន់ត្រូវនឹងខោត្រាកាលេចចេញសាច់កំភួនជើងសខ្ចីដូចទ្រយូងចេក ។ កញ្ចឹងក ម៉ត់ផង់, បបូរមាត់ស្ដើងក្រហមព្រឿង១ តាមធម្មជាតិ , ភ្នែកទាំងគូ មើលចំអ្នកណាថ្លាមុតហើយខ្មៅក្រីបសមនឹងសក់វែងប៉ប្រាសស្មាទៀត វាសែនល្អអ្វីម្ល៉េះទេ ! កាន់តែ

មើលយូរក៏កាន់តែស្អាតឡើង ។ ទ្រាំអង្គុយលេបទឹកមាត់បញ្ឆោតពោះខ្លួនឯងទៅទៀតលែងកើត ណាស៊ីខិតមកជិត ប្រវាដៃឱបសោភិនីជាប់ ព្រមជាមួយគ្នានេះច្រមុះកំព្រើលរបស់គេរ៉ាសដូចជ័រឆក់ ឱនទៅជុម្ពិតភួងថ្កាល់ដ៏រលើបរលោងរបស់នារីរកតែនាងការពារ ក៏មិនទាន់ ។

សោភិនី ខំប្រឹងរើបំរះអស់ទំហឹង តែដៃណាស៊ីឱបរឹតជាប់ ច្រមុះថេះតែឈ្ងុសសព្វទីកន្លែងសំខាន់ៗ ។ ទន់ដៃទន់ជើង, លែងបំរះ, ខ្លួននាងដូចអណ្តែតនៅលើដុំពពក ត្របកភ្នែកទ្រង់ស្លឹកបើកលែងចង់រួច ហើយបន្ទាប់មកក៏ទន់ករងៀកនៅក្នុងរង្វង់ដៃសង្សារ ។ ពេលនេះ ឥទ្ធិពលនៃព្រះកាមទេពមានជ័យជំនះលើចិត្តនាងហើយ ខ្លួនប្រាណទាំងមូល បណ្តោយឱ្យណាស៊ីឈ្លេចឈ្លីថើប ស្ទាប ញីញក់តាមអំពើចិត្ត ។ លែងចង់ក្រោក លែងចង់បើកភ្នែក, ចង់ដេកត្បុលក្បាលក្រោមកំដៅឱណ្ណៗ នៃផ្ទាំងទ្រូងរបស់ណាស៊ីយ៉ាងនេះរហូតអស់មួយជីវិត ។ លុះព្រះកាមទេព ដកឃ្លោទ័ពចេញពីរឿណរង្គត្រឡប់ទៅវិញ សោភិនីក៏ផ្ទារខ្លួនភ្ញាក់ព្រើតនឹង ខ្ទាសណាស៊ី ប្រញាប់ប្រញាល់ស្ទុះក្រោកអង្គុយមួយរំពេច ។

ណាស៊ីដឹងថាសោភិនីអៀន ហើយខ្លួនគេក៏ប្រព្រឹត្តខុសដែរ អ្នកនឹងបន្ទោសខ្លួនឯងជាក្រោយ មិនគួរណាធ្វើឱ្យសោភិនីអាក់អន់ចិត្តសោះ ។

-អូននី ... ! (ណាស៊ីបន្លឺវាចាឡើងក្រោយពីអង្គុយគិតមួយសន្ទុះ) អម្បាញ់មិញបងខុសហើយ សូមអូនអភ័យទោសឱ្យបងផងចុះ គ្រប់យ៉ាងដែលបងធ្វើទៅក៏ព្រោះតែបងស្រឡាញ់អូនខ្លាំងពេក ... ។

សោភិនី បែរមកមើលណាស៊ី ឃើញមុខក្រៀមស្រពោនទទួលកំហុស នាងក៏នឹកអាណិត កំហុសទាំងនេះនាងមិនត្រូវទម្លាក់ឱ្យណាស៊ី ទាំងអស់ទេ ខ្លួននាងក៏ត្រូវមានទទួលចំណែកដែរ ។ មាណវីផ្លាស់ទឹកមុខ ពីអៀនមកជាញញឹម ហើយនិយាយទៅកាន់ណាស៊ីថា :

-ឈប់គិតវាទៀតទៅបង រឿងកន្លងហួសមកហើយសូមកុំយកមកធ្វើជាអារម្មណ៍អី ... ចំពោះរូបបងមួយសោភិនីអភ័យទោសឱ្យទាំងអស់ អូនគ្មានប្រាថ្នាអ្វីក្រៅពីឱ្យបងចិត្តស្មោះត្រង់នឹងអូន ហើយស្រឡាញ់អូនយ៉ាងនេះរហូតទេ ។

-ព្រលឹងមាសបងអើយ ... សម្តីអូនផ្អែមត្រជាក់ដឹតជាប់ក្នុងបេះដូងបង ក្នុងជាតិនេះឬជាតិណាក៏ដោយ បងសូមប្រាថ្នាគ្រប់ៗជាតិឱ្យបានជួបតែនឹងអូន ទោះបីបងក្រីក្ររហេមរហាមស្ទើរដាច់ពោះស្លាប់ ក៏សូមឱ្យស្លាប់ក្បែរដៃស្រីចុះ អូនសោភិនី ... អូនមើលលើមែកឈើឯណោះន៎ ! (ណាស៊ីចង្អុលប្រាប់សោភិនីឱ្យមើលតាមដៃគេ) សត្វសេកមួយគូកំពុងប្រចឹកគ្នាដូចជារូបយើង

កំពុងតែថ្នាក់ថ្នមគ្នាឥចឹងដែរណាអូនឃើញទេ ? វាមិនហ៊ានទំឱ្យឃ្លាតឆ្ងាយពីគ្នាទេ សូម្បីតែវាជាសត្វតិរច្ឆានក៏គង់វាមានស្នេហាដូចជាយើង ។

-បងណាស៊ីចា៎ះ ! បើបងស្រឡាញ់អូនពិតមែន សូមបងអាណិតអូនឱ្យច្រើនជាងស្រឡាញ់ណាបងណា កុំធ្វើឱ្យអូនត្រូវក្រៀមក្រំខ្លោចផ្សាទៅថ្ងៃក្រោយឱ្យសោះ ជីវិតនិងអនាគតរបស់អូនសូមផ្ញើលើបងហើយអូនសូមលើកដៃសច្ចាព្រៃព្រឹក្សាលើខ្នងភ្នំនេះ ឱ្យជួយធ្វើជាក្សិណសាក្សីថា អូននឹងស្មោះត្រង់ចំពោះលើរូបបងមួយលុះអស់សង្ខារ ។

-ចំណែករូបបងវិញក៏ដូច្នោះដែរ បងសូមស្បថស្បែចំពោះធម្មជាតិនៅជុំវិញខ្លួន ព្រមទាំងវត្ថុស័ក្តិសិទ្ធដែលស្ថិតនៅលើកំពូលភ្នំនេះ សូមជួយដឹងជួយឮ ថាបងនឹងប្តូរផ្តាច់ តស៊ូនឹងឧបសគ្គគ្រប់យ៉ាង ហើយស្រឡាញ់តែអូនម្នាក់គត់ក្នុងជាតិនេះ ឬជាតិណា១ក៏ដោយ ។

បន្ទាប់ពីនាំគ្នាស្បថស្បែ យកមេឃយកខ្យល់ យកព្រៃព្រឹក្សាអ្នកតាភ្នំមកធ្វើជាក្សិណរវេង១ខ្លួនហើយ សង្សារថ្មោងថ្មីក៏ចាប់ផ្តើមលាកញ្ចប់បាយនិងដោះមាន់អាំងចេញពីចង្កាក់នាំគ្នាបរិភោគយ៉ាងឆ្ងាញ់ពិសា ។

ដួងទិនករជ្រេទៅខាងទិសបស្ចឹមបន្តិចហើយ កំដៅសូរ្យសែងរោលរាលពីថ្ងៃ បន្ថយឥទ្ធិរិទ្ធចុះមកជាលំដាប់ ។ នៅក្រោមដើមជ្រៃក្រឹមងណោះ សោភិនីដេកបិទភ្នែកជិតកើយលើភ្លៅណាស៊ី ។ ព្រះវាយោផាត់រំភើយ១ មិនដាច់រយៈហាក់ដូចជាជួយមកបបោសអង្អែលឱ្យស្រីក្រមុំ លង់ក្នុងមន្តស្នេហ៍ខ្យល់ភ្នំលេងចង់ក្រោកតែម្តង ។

ណាស៊ីលើកនាឡិកាដៃមើលឃើញម៉ោងបួន គេក៏ដាស់សោភិនី ឱ្យភ្ញាក់ឡើង ។

-អូនសោភិនី ... ! ក្រោកឡើងអូន ថ្ងៃល្ងាចហើយ ។

សោភិនីភ្ញាក់ឡើងភ្នែកមមីរ ស្វាបហ៊ម១ ពត់ដៃជើងយ៉ាងខ្ជិលច្រអូស ។ ស្រស់ស្រីក្រោកឈររលាស់សក់ច្បូតមកក្រោយឱ្យមានរបៀបរៀបរយ រួចនាងសួរទៅណាស៊ីថា :

-ម៉ោងប៉ុន្មានហើយបង ?

-អូ៎ ! ម៉ោងជាងបួនហើយ ( ណាស៊ីលើកនាឡិកាដៃបង្ហាញ សោភិនី) យើងល្មមទៅផ្ទះវិញអូន កុំឱ្យលោកប៉ាលោកម៉ាក់អូនគាត់មើលផ្លូវណា៎ ។

ចា៎ះ បង ... !

ណាស៊ី និងសោភិនីកាន់ដៃគ្នាដើរចុះពីកំពូលភ្នំ ។ មកដល់ខាង ក្រោម គេទៅយកទោចក្រយានដែលផ្ញើនឹងផ្ទះអ្នកស្រុក ហើយក៏នាំគ្នាជិះត្រឡប់ទៅសៀមរាបវិញ ។

សំណាងនិយាយមកដល់ត្រង់នេះឈប់ស្ងៀមបន្តិចមក អ្នកហូតបារីមួយមកអុជជក់ ទើបក៏និយាយទៅវង្សរិទ្ធិថា ៖

-ឃើញទេវង្សរិទ្ធិ ស្នេហាដំបូងរវាងណាស៊ី និងសោភិនីវាមានទឹកដមផ្អែមល្ហែមណាស់ តែ ...

-តែអ្វីទៅសំណាង ? (វង្សរិទ្ធិនិយាយកាត់ឡើង) ខ្ញុំដូចជារឿងឆ្ងល់រកស្តាប់មិនយល់សោះ បើណាស៊ី និងនាងសោភិនីស្រឡាញ់ប្តូរផ្តាច់ដល់ម្លឹងដែរ ហេតុដូចម្តេចបានជាណាស៊ីខូចចិត្តឈឺទាល់តែស្លាប់ ? ហើយសព្វថ្ងៃនាងសោភិនី នៅឯណាទៅ ?

-រឿងវានៅវែងឆ្ងាយណាស់វង្សរិទ្ធិ បើខ្ញុំនិយាយមិនទាន់ចប់មិត្តស្តាប់មិនយល់ទេ ចំណែកសោភិនី មិត្តកុំទាន់ចង់ដឹង ចាំខ្ញុំនឹងនិយាយរឿងគេទៅទៀត ។

មានពេលថ្ងៃមួយ ក្រោយពីណាស៊ីមកពីដើរលេងជាមួយសោភិនី មីងមឿនក៏ហៅណាស៊ីមកសួរថា ៖

-ណាស៊ី កូនជិតដល់ពេលប្រឡងផង ឃើញតែដើរលេងបាត់ពីផ្ទះរៀងរាល់ថ្ងៃ ឥឡូវស្រាប់តែឮដំណឹងមិនគួរគប្បីមកដល់ម្តាយទៀត ។

-រឿងអ្វីទៅម៉ែ ? (ណាស៊ីសួរទ្រង់ឆ្ងល់) ខ្ញុំដូចជាមិនដែលឈ្លោះប្រកែកជាមួយអ្នកណាទាល់តែសោះ ។

មីងមឿនសម្លឹងមើលមុខកូនគាត់ដោយពិនិត្យពិច័យ ឈប់ស្ងៀមមួយស្របក់គាត់ក៏បន្តសម្តីថា ៖

-ឥឡូវនេះ រឿងកូនឯងស្រឡាញ់កូនលោកមន្ត្រីនៅភូមិវត្តស្វាយ អ្នកស្រុកគេនិយាយរអារអួមស្ទើរគ្រប់មាត់ទៅហើយ ម្តាយខ្មាសគេ ណាស់ គេថាយើងជន្លេនចង់ឈោងចាប់ផ្កាយលើមេឃ រៀនសូត្រមិនគិតខិតខំ រវល់តែមកចង់ស្រី ហ៊ឺ ! ពិបាកណាស់ (មីងមឿនដកដង្ហើមធំ) តើរឿងនេះវាពិតឬមិនពិតកូន សូមកូនប្រាប់ម៉ែឱ្យត្រង់មក ។

ណាស៊ីនឹកអេះអុញក្នុងចិត្ត តែហើយគេក៏យល់ថាត្រូវតែជំរាបរឿងពិតឱ្យម្តាយដឹង ។

-ខ្ញុំស្រឡាញ់គេមែនម៉ែ ... ហើយគេក៏ស្រឡាញ់ខ្ញុំដែរ ...

ពិបាកណាស់កូនអើយ ... ! ម៉ែមិនចង់ជំទាស់ ... និងគោលបំណងកូនទេ តែថា ... វ័យរបស់កូនពេលនេះកំពុងត្រូវការរៀនសូត្រ ណា មួយយើងទីទ័លក្រ ចំណែកគេជាកូនអ្នកមានស្តុកស្តម្ភហើយជាមន្ត្រីផង ម៉ែគ្មានសង្ឃឹមថាគេនឹងព្រមឱ្យកូនគេមកធ្វើវាសនាលើឯងទេ ទីបំផុតឯងនឹងត្រូវខូចចិត្តរៀនសូត្រលែងកើត ហើយមធ្យមសិក្សាប័ត្រដែលម៉ែខំដុតធូបបែបន់ព្រះសំពះទេវតារាល់ថ្ងៃ ក៏នឹងត្រូវខកខានទៅដែរ ។

មីងមឿនិយាយចប់ ទឹកភ្នែកគាត់ក៏ហូរហៀរចេញមកដោយមិនដឹងខ្លួន ។ ណាស៊ីភ័យណាស់ស្ទុះទៅឱបម្ដាយមុខស្លឹតស្លាំង គេនិយាយចេញមកដោយសំឡេងញ័រៗថា :

ម៉ែ ... ! ម៉ែ ... ! យំឬ កូនបានជាខុសទៅហើយសូមម៉ែអភ័យទោសឱ្យខ្ញុំផង ...

មីងមឿនប្រឹងញញឹមទាំងនៅទឹកភ្នែករហាម គាត់យកដៃអង្អែលស្មាបុត្រសម្លាញ់បន្តើរៗ ដោយសេចក្ដីអាណិតអាសូរ ។ តាំងពីប្ដីគាត់ស្លាប់ទៅគាត់សង្ឃឹមតែលើរូបណាស៊ីមួយទេជាពន្លឺជីវិតរបស់គាត់ទៅអនាគត ។ បើគ្មានណាស៊ី គាត់នឹងត្រូវដាច់ខ្យល់ស្លាប់មួយរំពេច នេះហើយទឹកចិត្តមាតាស្នេហាបុត្រ ។

-ណាស៊ីកូនមាសម្ដាយ ... ចាប់តាំងពីថ្ងៃនេះទៅកូនត្រូវខំរៀនឱ្យមែនទែនណា ចាំពាក្យម៉ែចុះ ថាស្ត្រីជាសត្រូវក្នុងការរៀនសូត្រ ។

-បាទម៉ែ ! ខ្ញុំនឹងប្រតិបត្តិតាមពាក្យម៉ែទាំងអស់ ។

មីងមឿនញញឹមចេញមកម្ដងទៀត គាត់យកក្រមាជូតទឹកភ្នែកឱ្យស្អាត ហើយនិយាយថា :

-កូនទៅញុំាបាយចុះ ថ្ងៃនេះម៉ែស្ងួរម្ជូរសាច់គោស្លឹកថ្នឹងដែលឯងធ្លាប់ចូលចិត្តទុកឱ្យហើយ ។

ថារួច គាត់ក៏ក្រោកដើរចេញទៅ ទុកឱ្យណាស៊ីនៅតែម្នាក់ឯង អង្គុយត្រចោមក្បាលជង្គង់តប់ប្រមល់ក្នុងចិត្តស្ទើរនឹងប្រេះទ្រូងស្លាប់ ។

~៤~

## សម្បថក្រោមដើមពោធិ៍

**សម្បថស្បថស្បែក្រោមដើមពោធិ៍ ក្រោយពេលភ្លៀងហូរជោកជាំដី**
**រន្ទះផ្គូងផាំងចាំងរស្មី រុក្ខជាតិខៀវខ្ចីភ័យតក្កមា ។**
**អូនហើយនិងបងរួមស្នេហ៍ស្និទ្ធ ផ្លាស់ប្ដូរដួងចិត្តឥតសង្កា**
**លើកហត្ថាប្រណម្យមាត់សច្ចា កើតជាតិណាៗ មូលមេត្រី ។**

អស់ពេលមួយរាត្រី ណាស៊ីដេកមិនលក់សោះ បញ្ហាពាន់ម៉ឺនប្រការបានចោទសួរឡើងចំពោះគេក្នុងពេលនេះ ។ ម្ដងគេគិតថា ខ្លួនគេត្រូវតែឈប់ទាក់ទងនឹងសោភិនីតាមពាក្យម្ដាយ ពីព្រោះខ្លួនគេទីទ័លក្រ គេជាសត្វជន្លេន

ដែលរស់នៅក្រោមកំអែលដី តើវាមានប្រយោជន៍អ្វីទៅឈោងចាប់ផ្កាយលើមេឃ ? លទ្ធផលហុចឱ្យគ្មានអ្វីក្រៅពីធ្វើឱ្យគេកើតទុក្ខ, ដំបៅដើមទ្រូង, រៀនសូត្រលែងកើត, ហើយទីបំផុតគេនឹងត្រូវខូចអនាគតជាប្រាកដ តែគំនិតថ្មីមួយទៀតធ្វើឱ្យយល់ថា គេមិនត្រូវលះបង់ សោភិនី ដែលនាងគ្មានដឹងខ្លួនហើយអត់កំហុសនោះទេ ។ ស្នេហាគ្មានប្រកាន់វណ្ណៈ ស្នេហាជាឱសថទិព្វ, ដែលជួយជម្រុញចិត្តគេឱ្យខំរៀនសូត្រ មួយទ្វេជាពីរ បើគ្មានសោភិនី គេក៏គ្មានសេចក្ដីសុខដែរ ។

វិលវល់ក្នុងគំនិតរកគិតមិនលេច ម្ដងចង់ប្រតិបត្តិតាមពាក្យម្ដាយដើម្បីឱ្យគាត់សប្បាយចិត្ត ម្ដងចង់រេមករកសោភិនីវិញដែលជាពន្លឺសុភមង្គលរបស់គេទៅអនាគត ។ គិតទៅគិតមកនៅតែមិនដាច់ស្រេច ជញ្ជីងដួងចិត្តមិនដឹងជាថ្លឹងដាក់កូនទម្ងន់ខាងណាឱ្យធ្ងន់ជាង ។ ម្ខាងជាម្ដាយបង្កើតដែលមានព្រះគុណធ្ងន់លើសលប់ ម្ខាងទៀតជាសង្សារស្រឡាញ់ប្ដូរផ្ដាច់ស្មើជីវិត ។

ណាស៊ីដេកដកដង្ហើមធំ យកដៃគងថ្ងាសបើកភ្នែកភ្លឺះៗ សម្លឹងមើលទៅដំបូលមុងយ៉ាងធុញថប់ ។ ទីបំផុតគេក៏សម្រេចក្នុងចិត្តជាឯកច្ឆន្ទថា ត្រូវតែស្រឡាញ់សោភិនីតទៅទៀត ។

បីខែក្រោយមក ...

រឿងស្នេហាអាថ៌កំបាំងរវាងណាស៊ី និងសោភិនី ក៏លេចឮខ្ចរខ្ចាយពេញទាំងវិទ្យាល័យ ។ មិនយូរប៉ុន្មានដំណឹងនេះក៏ជ្រួតជ្រាបទៅដល់ត្រចៀកលោកភិរុណ និងលោកស្រីពន្លក ។

លោកប្រុសលោកស្រីខឹងណាស់ គ្រាន់តែដឹងដំណឹងភ្លាមក៏ហៅ សោភិនីមកសួរថា :

-ម៉េចសោភិនី ! (លោកភិរុណនិយាយ) ឯងសព្វថ្ងៃដឹងខ្លួនទេ ? កេរ្តិ៍ឈ្មោះឯង និងអញវាស្អុយរហ៊ឹពេញទាំងសៀមរាបទៅហើយ អញឱ្យឯងទៅរៀន តែឯងបែរជាទៅរៀនស្រឡាញ់គ្នាជាមួយអាណាស៊ីទៅវិញ អញខ្មាសគេណាស់ ដើរទៅត្រង់ណាឮតែគេនិយាយប្រាប់ តើឯងជាស្រីក្រមុំ ឯងធ្វើតចឹងវាត្រូវឬ ? មុខមាត់, កេរ្តិ៍ឈ្មោះ, បុណ្យស័ក្តអញធំដុំប៉ុណ្ណោះ ឯងទៅយកក្លិនគំរង់ស្អុយអាសោចឹមកលាបឱ្យប្រឡាក់ប្រឡូកអស់ តើឯងដេកគិតទៅមើលមានកូនសិស្សឯណាធ្វើដូចជាឯងដែរ ?

-ឯងនេះចង់ធ្វើឱ្យអញខ្មាសគេ នៅស្រុកសៀមរាបលែងបានហើយ (លោកស្រីពន្លកស្ដីព្រមទាំងលើកដៃចង្អុលមុខសោភិនី) ពូជពង្សវង្សអំបូណ៍អញថ្លៃថ្នូរណាស់ មិនដែរធ្វើអាវ៉ាឫកឱ្យប្រុសតាមឌឺត សព្វតែ តាមសាលា តាមផ្សារផ្សោតចឹងទេ ហ៊ឺះ ! ស្រឡាញ់អ្នកណាមិនស្រឡាញ់ ទៅស្រឡាញ់អាណាស៊ី ដែលសព្វថ្ងៃវាក្ររហាមស្មើរនឹងរកខោស្លៀកមិនបានទៅហើយ តើឯងរំពឹង

ទ្រព្យសម្បត្តិអំពីវា ឬក្រឡេកឃើញអាផ្ទះឈើកំពុកមួយហ្នឹង ? ប្រយ័ត្នណា ... ! ពីថ្ងៃនេះទៅឈប់ទាក់ទងជាមួយនឹង អាណាស៊ីជាដាច់ខាត តែអញ និង ប៉ាឯងលេចឮដំណឹងគួរអាម៉ាសមុខនេះម្ដងទៀត អញនឹងធ្វើទារុណកម្មនាងឯង ឱ្យខ្លាំងដែបន្តិចហើយតិចថាអញមិនបានប្រាប់ណាំ ... !

និយាយរួច លោកស្រីពន្លកកញ្ចក់ហិមស្លាពីលើក្ដារជឿមកបៀកម្លូ ញាត់ទៅក្នុងមាត់ទំពារផ្ទាច់ៗ ដោយទំហឹងក្រេវក្រោធ ។

សោភិនី អង្គុយបត់ជើងនឹងកំរាលឥដ្ឋឱនមុខជ្រប់ នាងមិនហ៊ានងើប មើលមុខលោកឪពុកអ្នកម្ដាយនាងឡើយ ។ គ្រប់យ៉ាងដែលបានប្រព្រឹត្តហួស ទៅ នាងដឹងដែរថាវាខុសនឹងប្រពៃណី តែនឹងធ្វើម្ដេចកើត បើនាងបានលង់ចិត្ត ស្រឡាញ់គេជ្រុលហួសទៅហើយ ។ លោកភិរុណ ឃើញ សោភិនីអង្គុយស្ងប់ ស្ងៀមមិនចេញស្ដី លោកក៏បន្តប្រយោគរបស់លោកទៀតថា :

-ឯងគិតមើលឱ្យស្រួលបួលទៅ កិត្តិយសឪពុកម្ដាយ និងអំណាច ស្នេហា ឯងរើសយកខាងណា សព្វថ្ងៃកេរ្ដិ៍ឈ្មោះក្រមុំរបស់ឯងវាកំពុងមាន មន្ទិលហើយ ឯងនាំគ្នាទៅលេងភ្នំក្រោម, បារាយណ៍ទឹកថ្លា, អង្គរតូច, ស្ពានថា គេមិនឃើញ គេមិនដឹងឬ ? បើឯងនៅតែប្រព្រឹត្តដូច្នេះទៀត ឯងនឹងត្រូវលោក ចាងហ្វាងសាលាបណ្ដេញឈប់ឱ្យរៀនជាមិនខាន ពេលនោះហើយដែលអញ ត្រូវទទួរស្បែកឆ្កែទៅធ្វើការ ( លោកភិរុណឈប់ស្ងៀមបន្តិច ហូតយកថ្នាំ Virgisnia មកញាត់ក្នុងខ្សៀរអុជបឺតបង្ហុយផ្សែងទ្រលោម រួចទើបលោក និយាយតទៅទៀត) ឯងត្រឡប់ទៅបន្ទប់វិញចុះ ស្អែកនេះអញនឹងឱ្យគេទៅ ហៅអាណាស៊ីមកសួរ តើដើមទងមុនដំបូងវាយ៉ាងម៉េច ។

ថាហើយ លោកភិរុណក៏ក្រោកដើរទៅរានហាលខាងមុខបាត់ទៅ ឃើញទឹកមុខលោកភិរុណ និងលោកស្រីពន្លកភ្លាម គេត្រជាក់ខ្លួនស្រឹតយល់ ច្បាស់ថាមុខជាមានរឿងអីកើតឡើងចំពោះរូបគេជាមិនខាន ។

ក្រោយពីលោកភិរុណឱ្យអ្នកអង្គុយ ( លោកភិរុណលែងហៅក្មួយដូច ពេលមុនៗ) គឺខ្ញុំចង់សួរការពិតតែពីរបីម៉ាត់ទេ ដូច្នេះចូលអ្នកស្ដាប់សំណួរខ្ញុំឱ្យ បាន ហើយឆ្លើយដោយត្រង់មក ។ ណាស៊ីឯងសព្វថ្ងៃស្រឡាញ់ សោភិនី កូនខ្ញុំ មែនទេ ?

ណាស៊ី បែកញើសប៉ុនៗគ្រាប់ពោត បេះដូងលោតក្ដុកក្ដាក់ខុសចង្វាក់ ធម្មតា គេឆ្លើយទាំងញ័របបូរមាត់ទទ្រើតថា :

-បាទ ... បាទ ... ខ្ញុំស្រឡាញ់អូនសោភិនីមែនលោកអ៊ំ ... !

-ហាំ... ! ហាំ... !( លោកភិរុណសើចទាំងក្នុងទ្រូងពុះពោរទៅដោយ ទោសៈ) ច្បាស់ល្អណាស់ ... ! ខ្ញុំសូមកោតសរសើរចំពោះអ្នកដែលហ៊ានឆ្លើយ

ការពិតប្រាប់ខ្ញុំ ។ កាលពីថ្ងៃមុន អ្នកនាំកូនខ្ញុំទៅលេងភ្នំក្រោម. បារាយណ៍ទឹកថ្លា. អង្គរតូចមែនទេ ?

-បាទ ! ... អា ... ! មែនលោកអ៊ំ ។

-អ៊ឺម៉ ... ខ្ញុំសូមសរសើរនូវសិល្បស្នេហារបស់អ្នកម្ដងទៀតក្នុងចំណោមកូនសិស្សទាំងអស់ អ្នកជាអ្នកពូកែខាងថែចង់ស្រីជាងគេមែនទេ?

លើកនេះណាស៊ីឆ្លើយលែងរួច ដឹងខ្លួនថាជាប់កុនរបស់លោក ភិរុណមែនទែនហើយ ។ ប្រុសកម្លោះអង្គុយកេះក្រចក ដាក់មុខចុះសម្លឹងមើលកំរាលឥដ្ឋទ្រង់ជាទំនងអង្វរឱ្យលោកអាណិត ។

ឃើញណាស៊ីនៅស្ងៀមឈឹងមិនចេញស្ដី លោកភិរុណក៏សង្កត់ពាក្យបន្ថែមថា :

-ហេតុអ្វីដែលបណ្ដាលឱ្យអ្នកស្រឡាញ់កូនខ្ញុំ ? ឬមកពីអ្នកចង់ទារសគុណក្នុងកិច្ចដែលអ្នកបានជួយស្រង់កូនខ្ញុំលង់ទឹកពីថ្ងៃមុន ហា៎! ហា៎! (លោកភិរុណសើចសម្លឹងមើលមុខណាស៊ី) ខ្ញុំខំរាប់អានអ្នកទុកដូចជា កូនក្មួយបង្កើតដោយយល់ថាអ្នកជាមនុស្សចេះដឹង ជាកូនអ្នកមានពូជអំបូណ៍ តែទីបំផុត អ្នកបានរំលាយសេចក្ដីទុកចិត្តរបស់ខ្ញុំ ដោយកាលលួចស្រឡាញ់សោភិនី អ្នកគិតមើលតើមនុស្សរបៀបអ្នកឱ្យឈ្មោះអ្វីសម ? ឥឡូវខ្ញុំមិនបាច់និយាយរៀបរាប់អ្វីឱ្យវែងឆ្ងាយ នាំឱ្យខូចពេលវេលាទេ ខ្ញុំសូមនិយាយយ៉ាងខ្លីហើយងាយស្ដាប់ជាទីបំផុត គឺថា ខ្ញុំទិញតំលៃស្នេហារបស់អ្នកឯងមួយម៉ឺនរៀល ហើយចាប់តាំងពីវិនាទីនេះទៅ ត្រូវឈប់ទាក់ទងជាមួយកូនខ្ញុំជាដាច់ខាត ចំណែកកាំជណ្ដើរផ្ទះខ្ញុំ អ្នកក៏មិនត្រូវមកជាន់ ទៀតដែរ ។

លោកភិរុណដកក្រដាសប្រាក់ប្រាំរយមួយបាច់ធំ ពីក្នុងហោប៉ៅបោះដាក់មុខណាស៊ី ។

ប្រុសកម្លោះសែនតានតឹងក្នុងចិត្ត សម្ដីស៊កសៀតទ្រគោះបោះបោករបស់លោកភិរុណ ធ្វើឱ្យអ្នកចុកចាប់ក្នុងទ្រូងស្ទើរនឹងក្អួតឈាមស្លាប់ ។ ពេលនេះហើយទើបអ្នកដឹងខ្លួនថា ពាក្យម្ដាយអ្នកទូន្មានគ្មានខុសត្រង់ណាសោះ ស្នេហាគឺនាំមកនូវសេចក្ដីទុក្ខ ។ ណាស៊ី ខំលួចរកមើល សោភិនីក្រែងនៅជិតតែមិនឃើញនាងឡើយ ក្រោយពីអង្គុយគិតមួយសន្ទុះធំ គេក៏ដាច់ចិត្តនិយាយជំរាបទៅលោកភិរុណថា :

-ប្រាក់មួយម៉ឺននេះសូមលោកអ៊ំទទួលទុកវិញចុះ ចំណែករឿងអូនសោភិនី និងខ្ញុំ ... ខ្ញុំសូមសន្យាថានឹងឈប់ទាក់ទងគ្នាត្រឹមណេះហើយព្យាយាមដកខ្លួនឱ្យឆ្ងាយជាទីបំផុត ។

ថាហើយ ណាស៊ីក៏សូមលាលោកភិរុណ និងលោកស្រីត្រឡប់មកផ្ទះខ្លួនវិញជាបន្ទាន់ ។

ឃើញទេ ... ទីចុងចប់នៃស្នេហា វាហុចផលល្វីងជូរចត់ឱ្យដូច្នេះ ឯងសប្បាយច្រើនរែងកើតទុក្ខច្រើន ។ ឥឡូវណាស៊ីក្លាយទៅជាមនុស្សស្ងប់សៅទុញទាល់ប្រាជ្ញា កិច្ចការរៀនសូត្រឱនថយជាលំដាប់ ។ តាំងពីថ្ងៃលោក ភិរុណហៅគេទៅជេរស្តីមក និស្សិតវិបត្តិស្នេហាក៏ព្យាយាមគេចមុខពីសោភិនី លែងឱ្យជួប ទោះជានាងខំស្កាត់តាមរកដល់ផ្ទះ ឬផ្ញើសំបុត្រណាត់ឱ្យទៅជួបនៅកន្លែងណា ក៏ណាស៊ីពុំព្រមទៅជួបដែរ ។ ម៉្ងៃ១គេអង្គុយសំកុកកើតទុក្ខគ្មានទឹកនាពីរឿងបាយទឹកអ្វីទាំងអស់ ជួនកាលគេដេកសម្លឹងមើលដំបូលពាកដែលរសាត់គ្រឿន១នៅលើមេឃ ដកដង្ហើមធំ ហើយស្រាប់តែស្រក់ទឹកភ្នែកមកឯង ។ មីងមឿន លបមើលឃើញអាកប្បកិរិយាកូនខុសប្លែកដូច្នេះ គាត់រំជួលក្នុងចិត្តឆ្អិតណែនឱរា ខំនិយាយអង្វរលួងលោមពន្យល់ហេតុផលសព្វគ្រប់ ។ តែជាការឥតប្រយោជន៍ ... ណាស៊ីមិនបានសប្បាយរីករាយ ឬរសាយពីគំនិតទុក្ខគេឡើយម្ល៉ោះហើយ អ្នកមីងមេម៉ាយក៏ត្រូវដេកដើរបង្ហូរទឹកភ្នែកទឹកសម្បោរ កើតទុក្ខម្នាក់ថែមទៅទៀត ។

ឱហ្ន៎ ... ! ជំងឺស្នេហាកាចសាហាវគួរឱ្យខ្លាចមែន បើគិតឱ្យដល់ទៅជំងឺនេះ វាអាក្រក់ឃោរឃៅជាងជំងឺអាសន្នរោគរាប់រយដងទៅទៀត ណាស៊ីខំកាត់ចិត្តបំភ្លេចរូបសោភិនី ខំគេចវៀសមិនឱ្យជួបមុខ ដោយតាំងចិត្តយ៉ាងអង់អាចថាស្នេហាពិតត្រូវហ៊ានធ្វើពលិកម្ម មនុស្សដែលចុះញ៉មនឹងអំណាចស្នេហាគឺជាមនុស្សខ្វះសតិសម្បជញ្ញៈ គិតឱ្យបានគ្រប់គ្រាន់ ជាមនុស្សគំរក់បំផុតក្នុងលោក តែ ... ទិដ្ឋិមានះនេះមិនបានប៉ុន្មាន ក៏ត្រូវរលាយខ្សុរដូចអំបិលត្រូវទឹក ។ ភាពពីអតីតកាលចេះតែមកលងគេគ្រប់ទិនទិវារាត្រី ឱ្យគេនឹកឃើញអនុស្សាវរីយ៍ចាស់១នឹកស្តាយក្លិនខ្លួន ដែលធ្លាប់ថ្នមបីផ្ទាប់នឹងផ្ទាំងទ្រូងក្តៅឧណ្ហ១សម្បថនៅលើខ្នងភ្នំហាក់ដូចជាឮនៅថ្មី១ ជាប់សោតា បើម្ល៉េះ១តើគេបំភ្លេចម្តេចកើត ។ បើមុខនឹងគេត្រូវស្លាប់សូមឱ្យស្លាប់លើដៃស្រីទៅចុះ ធ្វើម្តេចជាតិនេះបានជាមានកម្មក្រាស់ ស្រឡាញ់តែសោភិនីម្នាក់ ទាំងចិត្ត, បេះដូង, សូមបូជាចំពោះស្រីតែមួយ ប្រសិនប្រែជាមិនបានទៅវិញ ជីវិតរស់នៅក៏គ្មានខ្លឹមសារអ្វីដែរ ក្នុងលោកនេះ គេមិនអាចរស់នៅឯកឯងដោយគ្មានរូបសោភិនីនៅជិតបានទេ ។

ដួងចិត្តវិបល្លាស វិលវល់គំនិត មានពេលខ្លះគេគិតឈប់រៀន ហើយចង់និរទេសខ្លួនឱ្យចេញឆ្ងាយពីដែនដីសៀមរាប ដើម្បីកុំឱ្យយល់ស្រមោល សោភិនីទៀត លុះមកគិតឃើញម្តាយចាស់ ណាស៊ីក៏ត្រូវខាំមាត់ សង្កត់ចិត្តលែងយកមកគិតអារម្មណ៍ទៅវិញ ។

ថ្ងៃមួយ ក្រោយពេលចេញពីរៀន ខណៈដែលណាស៊ីជិះកង់រៀបបត់មកខាងស្ពានថ្ម ស្រាប់តែគេភ្ញាក់ព្រើត នៅលើស្ពាន សោភិនីឈរចាំគេ ជាស្រេច ណាស៊ីចង់បត់កង់ទៅក្រោយវិញ តែសោភិនីបានស្រែកឃាត់គេថា :

-ឈប់សិនបងណាស៊ី !

សំឡេងសោភិនីហាក់ដូចមន្តសណ្ដំ ណាស៊ីចាប់ហ្វ្រាំងកង់ឈប់ទ្រឹងមួយកន្លែង ។ សោភិនី ឥឡូវនេះនាងស្គាំងស្គម ភ្នែករូង បបូរមាត់ស ស្លេកស្លាំងខុសពីសោភិនីមុនឆ្ងាយណាស់ ។ ប្រុសកម្លោះអាណិតសង្សារ ខ្លោចចិត្តគេយល់ច្បាស់ហើយ ថាហេតុដែលបណ្ដាលឱ្យនាងស្គាំងស្គម ដូច្នេះមកពីនាងនៅមិនដាច់អាល័យពីគេពិតប្រាកដ ។

-បងណាស៊ី ... !

សោភិនី ហៅម្ដងទៀត ទើបណាស៊ីភ្ញាក់ខ្លួន ចុះពីលើកង់ដឹកតំរង់ចូលមករក ។

-អូនសោភិនី !

-បងណាស៊ី ...

សោភិនីនិយាយបានត្រឹមណោះ ទឹកភ្នែកក៏ហូរហៀរជោកថ្ពាល់ទាំងសងខាងមួយរំពេច ។

-សោភិនីអូនយំ?

-បងណាស៊ី ... បងអស់អាល័យខ្ញុំហើយឬ ម្ដេចក៏បងចាំគេចមុខពីខ្ញុំយ៉ាងឥចឹង ... ?

ណាស៊ីអួលដើមករកកល់ចង់ចេញទឹកភ្នែក ។

-អូនយល់ដូច្នេះខុសហើយ បងឥតមានស្អប់ខ្ពើមអូនទេ លោកប៉ាអូនទេតើ លោកស្អប់បង លោកជេរស្ដីបងឱ្យទាក់ទងជាមួយអូនទៀត ពីព្រោះលោកយល់ឃើញថា បងជាកូនអ្នកក្រខ្សត់ គ្មានទ្រព្យសម្បត្តិធូនល្មម នឹងរកសេចក្ដីសុខឱ្យអូនបាន ...

-បងណាស៊ី ... មាសប្រាក់ទ្រព្យសម្បត្តិមិនអាចទិញទឹកចិត្តអូនបានទេ ក្នុងជាតិនេះអូនប្ដូរផ្ដាច់មិនព្រមទទួលបុរសណាមកធ្វើគូគ្រងជីវិត ក្រៅពីបងឡើយ បើទុកណាជាមានគេបង្ខិតបង្ខំក៏យកបានតែរាងកាយ ប្រាសចាកវិញ្ញាណប៉ុណ្ណោះ ។

គ្រប់ៗមាត់របស់សោភិនី ធ្វើឱ្យណាស៊ីត្រជាក់ចិត្ត និងរិតតែស្រឡាញ់អាណិតអាសូររកទីបំផុតគ្មាន ។

-អូនសោភិនី អូនស្កាត់មកជួបបងនេះ មានការណ៍អ្វីសំខាន់ដែរ ឬ ? យើងឈរនៅកន្លែងនេះយូរមិនគាប់ភ្នែកអ្នកដទៃទេ ។

-ចាំបងអូនមានការត្រូវពិភាក្សាជាមួយបងច្រើនណាស់ ស្អែកព្រឹកថ្ងៃអាទិត្យ បងទៅជួបអូននៅអង្គរធំបានទេ ?

ណាស៊ីគ្រវីក្បាលដកដង្ហើមធំដោយព្រួយបារម្ភ ។

-ហ៊ឹ ! បងដូចជាញញើតណាស់អូន លោតែលោកឪពុកអូនដឹង ម្តងទៀត បងមុខជាមានរឿងធំហើយ បើយើងកុំជួបគ្នាមិនបានទេឬ ?

-រឿងនេះវាទាក់ទងដល់យើងទាំងពីរនាក់ណាបង បើស្អែកបងមិនព្រមទៅជួបអូនទេ បងនឹងលែងបានឃើញមុខអូនទៀតហើយ ។

ណាស៊ីស្មានយល់ភ្លាមថា ក្នុងគ្រួសារសោភិនីច្បាស់ជាមានកើតរឿងអ្វីជាមិនខាន ហើយបើគេប្រកែកពុំព្រមទៅជួប ជួនកាលសោភិនី អាចធ្វើឃាតខ្លួនឯងក៏មិនដឹង គិតឃើញដូច្នេះ គេក៏និយាយទៅនាងថា :

-បើតចឹងមិនអីទេអូន ស្អែកព្រឹកម៉ោង ៨ បងនឹងទៅជួប ឥឡូវសូមអូនត្រឡប់ទៅផ្ទះវិញចុះ ។

-ចាំបង ព្រលឹមឡើងអូនទៅចាំបងឯណោះមុនណា ។

និយាយចប់ សោភិនីទាញចក្រយានដែលផ្អែកនឹងបង្កាន់ដៃស្ពានជិះចេញទៅ ។ ណាស៊ីឈរមើលទាល់តែបាត់ស្រមោលនាងមើលលែងឃើញ ទើបគេជិះកង់ត្រឡប់មកផ្ទះ ។

ព្រឹកស្អែកឡើង ម៉ោង ៨ កន្លះ ណាស៊ីក៏ទៅដល់អង្គធំ គ្រាន់តែគេចុះពីកង់ភ្លាម សោភិនីចេញមកទទួលល្មម ។

-អូនមកចាំបងយូរហើយឬ ?

ណាស៊ីសួរ ព្រមទាំងដឹកកង់ចូលទៅក្នុងអង្គរ ។

-ចាំ អូនមកដល់មុនពេលនេះបន្តិច ។

សង្សារកម្សត់ពីអង្គារ នាំគ្នាទៅអង្គុយត្រង់មុខព្រហ្មខាងលើប្រាសាទរួចសោភិនីក៏ចាប់បើកឆាកសន្ទនា ដោយសួរទៅណាស៊ីថា :

-បងណាស៊ី ... ! សព្វថ្ងៃបងស្រឡាញ់អូនទេ ?

-ម្តេចក៏អូនសួរបងតចឹង មានតែសេចក្តីស្លាប់ប៉ុណ្ណោះទេអាចធ្វើឱ្យបងបំភ្លេចរូបអូនបាន សព្វថ្ងៃបងស្ទើរនឹងឆ្កួតលីលា ចង់រត់ចោលការរៀនសូត្រម្តងៗ ក៏ព្រោះតែរូបអូនហ្នឹងហើយ ។

សោភិនីឮសម្តីសង្សារ នាងយំហ៊ូរចេញមកប្រាសចាកអៀនខ្មាសស្រស់ស្រីផ្តេកក្បាលទៅនឹងស្មាប្រុសស្នេហ៍អណ្តឹតអណ្តកក្អុកក្អួលក្នុងឱរា បន្តិចមកទើបឮនាងនិយាយថា :

-បងណាស៊ីចាំ ...! ឥឡូវប៉ាម៉ាក់អូនគាត់ឱ្យអូនឈប់រៀនហើយ ដើម្បីធ្វើកុំឱ្យយើងទាំងពីរនាក់បានជួបគ្នាទៀត ( សោភិនីសង្កៀតធ្មេញយ៉ាងឈឺចាប់) មិនត្រឹមតែប៉ុណ្ណោះបងអើយ ... គាត់បង្ខិតបង្ខំឱ្យអូនមានប្តី តែ ... អូនប្តេជ្ញាចិត្តរួចជាស្រេច ទោះបីគេបង្ខិតបង្ខំធ្វើទារុណកម្មយ៉ាងណា ក៏អូនមិនព្រមទទួលជាដាច់ខាត ។

ពេលនេះណាស៊ីយល់ច្បាស់ហើយថា សោភិនីមានចិត្តស្មោះត្រង់ភក្តីភាពចំពោះគេ កម្រនឹងរកនារីណាក្នុងលោកមកប្រដូចបាន អាណិតណាស់ ! ប្រសិនបើជាគេមានសិល្ប៍មន្តគាថាអាចប្រែក្រឡាបានដូចគ្រុឌ គេនឹងឆាបឆក់យកសោភិនីហោះហើរកាត់សមុទ្រសាគរ ទៅទុកនៅស្ថានមួយដ៏ឆ្ងាយសែនឆ្ងាយមិនឱ្យអ្នកណាទៅរកឃើញឡើយ តែគេជាមនុស្ស បចុជ្ជនធម្មតាវាហួសវិស័យនឹងធ្វើទៅកើត ។

ឥឡូវត្រូវរកគិតដូចម្តេចទៅវិញ បើគេនៅតែស្រឡាញ់សោភិនីតទៅទៀត គិតទៅគិតមកត្រឡប់ប្លូនដប់សា ណាស៊ីក៏សម្រេចចិត្តថា ត្រូវតែលះបង់សោភិនីឱ្យទៅប្រុសដទៃ ដើម្បីកិត្តិយសវង្សត្រកូលនាង និង ដើម្បីអនាគតរបស់នាងទៅថ្ងៃមុខ ពីព្រោះគេទីទាល់ក្រយ៉ាងដូច្នេះមិនអាចរកសុភមង្គលឱ្យនាងបានគ្រប់គាន់ទេ គិតហើយណាស៊ីក៏និយាយទៅ សោភិនីថា :

-អូនសោភិនី បងយល់ថាអូនគួរតែរៀបការតាមឪពុកម្តាយទើបសម ទាំងនេះមិនមែនបានសេចក្តីថា បងមិនស្រឡាញ់អូន ឬខ្វះការតស៊ូទេ បងស្រឡាញ់អូនណាស់ ... ស្រឡាញ់ជាងជីវិតរបស់បងទៅទៀត ដោយអំណាចស្រឡាញ់នេះហើយ ទើបបងសុខធ្វើពលិកម្ម ចូរអូនគិតមើលមើល៍ បើអូនស្រឡាញ់បង អូននឹងត្រូវខូចអនាគត ហើយពាក្យអ្នកស្រុកគេនិន្ទាអូនយ៉ាងណាទៅ ជាពិសេសឪពុកម្តាយអូន លោកនឹងត្រូវក្រៀមក្រំក្នុងចិត្ត អាប់កិត្តិយស ខ្មាសញ្ញាតិមិត្តជិតខាង ពីព្រោះតែកូនក្រមុំ មិនលុះដោយដំបូន្មាន (ណាស៊ីឈប់ស្ងៀមឱនទៅថើបសក់សង្សារបន្តិច ទើបនិយាយតទៅទៀត) យើងកើតមកជាតិនេះកម្មក្រាស់ណាស់អូន បើជាតិក្រោយមានមែនដូនពាក្យសន្មតបងសូមប្រាថ្នាជួបអូនគ្រប់ៗជាតិ ហើយសុំកុំឱ្យចិត្តមនុស្សលោក លោភលន់កាចសាហាវយង់ឃ្នង ប្រកាន់វណ្ណៈអាងទ្រព្យសម្បត្តិ ដូចជាជាតិនេះឱ្យសោះ ។

-បងណាស៊ី ... ! (សោភិនីនិយាយតិចៗ ស្ទើរតែស្តាប់មិនឮព្រមជាមួយគ្នានេះទឹកភ្នែកចង្រៃ ក៏រអិលចេញពីរង្វង់ចក្ខុដូចតំណក់ភ្លៀងមក មួយរំពេច) បងឱ្យអូនទៅរៀបការជាមួយប្រុសដទៃ គឺបងឱ្យអូនទៅរកសេចក្តីស្លាប់ ។

ថាតែប៉ុណ្ណោះ មាណវីក៏អួលដើមករកហាមាត់និយាយតទៅទៀតលែងរួច ។

ផ្ទៃមេឃអម្បាញ់មិញខៀវស្រឡះផ្លាស់មកជាងងឹតឈ្លប់ ផែនពពកខ្មៅផ្ទាំងធំៗប៉ុនផ្ទះ កំពុងអណ្តែតលឿនស្លោតទម្រង់មករកកន្លែងអ្នកទាំងពីរ ខ្យល់បក់បោកកាន់តែខ្លាំងឡើងៗ ស្លឹកឈើចាស់ជ្រុះចាកមែកឮ សូរ៉ាវៗ មិន

ដាច់រយៈ ។ បន្ទាប់មក ព្រះភិរុណបង្អុរភ្លៀងមួយមេយ៉ាងធំស្រោចស្រពលើផែនប្រថពី ។

-ភ្លៀងធំណាស់អូន ! ... យើងឆាប់រត់ចូលទៅក្នុងប្រាសាទភ្លាមឡើង ។

ថាហើយ ណាស៊ីក៏កាន់ដៃសោភិនីរត់ចុះទៅកាន់បន្ទប់អណ្ដូងប្រេង ដើម្បីជ្រកភ្លៀង ។

ច្រាវ ! ច្រាវ ! ដំណក់គ្រាប់ព្រះភិរុណបោកប៉ះនឹងផ្ទាំងសិលាខ្ទាតមកត្រូវខ្លួនសោភិនីធ្វើឱ្យស្រស់ស្រីរងញ័រចំប្រប់ដូចកូនសត្វ ។ នៅលើមេឃាងណោះ ព្រះវាយុទេពគក់ឱរាក្ដុង ! ក្ដុង ! ហាក់ដូចជាក្រេវក្រោធ នឹងធម្មជាតិ ។

ក្នុងបន្ទប់អណ្ដូងប្រេងងងឹតសូន្យសុង កាំរន្ទះមួយបាញ់ឆ្វាចទៅត្រូវដើមគគីរ បណ្ដាលឱ្យលាន់ឮសូរឆាំង ! កក្រើកអស់ទាំងផែនដី ។ ស្រីក្រមុំស្ទុះទៅឱបកណាស៊ីជាប់ ខ្លួននាងត្រជាក់ស្រឹតញ័រសព្វមំសា ។ ពេលជាមួយគ្នានេះណាស៊ី ក៏ទាញខ្លួនសោភិនីមកឱបផ្ទាប់នឹងដើមទ្រូងគេ ។ ចំហាយក្ដៅឧណ្ហៗដែលកញ្ជ្រោលចេញពីបេះដូង ធ្វើឱ្យកម្លោះក្រមុះ អណ្ដែតអណ្ដូងមួយខណៈ ។

នៅខាងក្រៅ ភ្លៀងនៅតែបង្អុរគ្រាប់ខ្លាកៗ មួយមេហើយមួយមេទៀតគ្មានស្រាកស្រាន្ត ណាស៊ីឱបរិតខ្លួនសោភិនីជាប់ ។ ព្រះកាមទេពបានច្យុតចុះមកថ្លែងសរទំលុះបេះដូងអ្នកទាំងពីរហើយ ។ ភួងថ្ពាល់ដឹតជាប់នឹងច្រមុះដើមទ្រូង នឹងដើមទ្រូង ប្រកិតគ្នាជាប់ស្ទើរនឹងរលាយសាច់មួយ ។ ពេលនេះណាស៊ីគ្មានទឹកឃើញអ្វីទាំងអស់ គេកំពុងបណ្ដោយខ្លួនឱ្យលង់ទៅក្នុងសមុទ្រតណ្ហាដែលពេលពេញទៅដោយរលកបែកផ្កាត្រែង ។

នាវាតូចមុចងើបៗ កណ្ដាលមហាសាគរ ស្ទើរលិចស្ទើរអណ្ដែត ជួនកាលត្រូវរលកបោកខ្លាំងក៏លិចបាត់ទៅក្នុងបាតសមុទ្រមួយខណៈ រួចក៏ផុសផ្ងោលឡើងវិញ ។ ពេលនេះឆ្លាមកំណាចមួយស្ទុះហោមករកកូនទូកតូច មហាមច្ឆាយកខ្នងកើលទូកឱ្យផ្អៀង បណ្ដាលឱ្យទឹកចូលលិចបាត់ទៅក្នុងបាតសមុទ្រជ្រៅមួយរំពេច ។

ភ្លៀងខ្យល់ស្ងប់បាត់អស់ហើយ ផ្ទៃមេឃដែលងងឹតដូចជាពេលយប់អម្បាញ់មិញ ក៏ត្រូវព្រះអាទិត្យរះបំភ្លឺដូចធម្មតាឡើងវិញ ។ វត្ថុគ្រប់យ៉ាងដែលជាទីហួងហែង នឹងមានតំលៃសម្រាប់វ័យក្រមុំរបស់ សោភិនី នាងបានប្រគល់ជូនបុរសជាទីស្រឡាញ់របស់នាងអស់គ្មានសល់ ។ មិនមែនគេប្លន់នាងទេ តែនេះនាងពេញចិត្តនឹងបូជាចំពោះគេដោយស្មោះត្រង់ ។

ណាស៊ី យកដៃទៅច្បូតសក់នាងបន្ថើរៗ ដោយសេចក្ដីស្រឡាញ់ និងអាណិតអាសូរ ពេលនេះគេផ្លាស់គំនិតថ្មីហើយ ទោះបីស្លាប់រស់យ៉ាងណាក៏មិន

អាចបំភ្លេចរូបសោភិនីចោលបានទេ គេត្រូវតែតស៊ូប្ដូរពុះពារនឹង ឧបសគ្គគ្រប់បែបយ៉ាងដែលវានឹងកើតឡើងចំពោះមុខគេ ទោះជាយ៉ាង ណាក្ដី សោភិនីក៏បានជាប្រពន្ធគេរួចទៅហើយដែរ ។

-អូនសោភិនី ... !

-ចាំ បង ... !

-ម្ដេចក៏អូនធ្វើមុខស្រពោនឥចឹង អូនខឹងនឹងបងឬ ?

សោភិនី នាងខំប្រឹងញញឹមទាំងមិនទាន់បាត់ស្នាមទឹកភ្នែក ដោយវាចាមួយៗ ថា :

-ចាំ អូនអត់ខឹងនឹងបងទេ តែអូនព្រួយបារម្ភខ្លាចបងបោះបង់អូនចោលទៅថ្ងៃក្រោយ ទោះជាអាក្រក់ល្អយ៉ាងណា អូនក៏ជាប្រពន្ធបងរួចទៅហើយ សូមបងអាណិតកុំធ្វើឱ្យនារីកម្សត់នេះត្រូវដេកបង្ហូរទឹកភ្នែករីងរៃទាល់តែស្លាប់ខ្លួនណាបងណា ។

ណាស៊ីប្រញាប់ញញឹមប្រលោមចិត្តសង្សារដោយវាចាលោមថា:

-តែប៉ុណ្ណោះហើយបងមិនបោះបង់អូនចោលទេ សូមអូនសង្ឃឹមទុកចិត្តមកលើបងចុះ យើងសុខចិត្តស្លាប់រស់ជាមួយគ្នាណាអូនណា ស្នេហាយើងជាស្នេហាអមតៈ ។

សែនត្រជាក់ក្នុងហឫទ័យអ្វីម្ល៉េះទេ បានឮតែសម្ដីសង្សារប៉ុណ្ណោះ នាងលែងកើតទុក្ខព្រួយទៀតហើយ ។ មាណវីលើកខ្នងដៃសង្សារមកអង្អែលថើបស្រាលៗ ដោយបីតិសោមនស្សរីករាយ រួចនាងក៏និយាយថា:

-អូនឮសម្ដីបងដូច្នេះ អូនត្រេកអរណាស់ ពីថ្ងៃនេះទៅយើងត្រូវតាំងចិត្តឱ្យក្លាហានណាបង ទោះបីមនុស្សលោកមើលសេចក្ដីស្មោះត្រង់ យើងទាំងពីរនាក់មិនឃើញ ក៏គង់ឥន្ទ្រព្រហ្មទេវតាព្រះអង្គមានព្រះនេត្រទិព្វ ព្រះកាណ៌ទិព្វ ជួយឱ្យយើងសម្រេចគោលបំណងក្នុងថ្ងៃណាមួយជាមិន ខាន។

បន្ទាប់មក សង្សារកម្សត់ទាំងពីរប្រាណក៏នាំគ្នាដឹកកង់ចេញពីអង្គរដើរតំរង់ទៅក្រោមដើមពោធិ៍ដែលមានខ្ទមអ្នកតាមួយស្ថិតនៅទីនោះ ។

ដល់ពេលណាស៊ីក៏និយាយទៅកាន់សោភិនីថា :

-អ្នកតានេះខ្លាំងពូកែហើយស័ក្ដិសិទ្ធណាស់អូន យើងចង់បែរបន់ពីរឿងអ្វី ច្រើនតែបានដូចប្រាថ្នា ឥឡូវយើងសូមធ្វើសច្ចាបណិធានទាំងពីរនាក់ទៅ ដើម្បីឱ្យលោកជួយយើងបានគ្នាជាប្ដីប្រពន្ធទៅអនាគត ។

-ចាំ បង ... !

ណាស៊ី និងសោភិនី នាំគ្នាអង្គុយតប់ជើងលើកដៃប្រណម្យចំពោះមុខវត្ថុស័ក្ដិសិទ្ធ ។ រួចហើយណាស៊ីក៏ចាប់ផ្ដើមសច្ចា :

-ខ្ញុំសូមសច្ចាបណិធានចំពោះអ្នកតាដ៏មានឫទ្ធិខ្លាំងពូកែ សូមលោកជួយធ្វើជាក្សិណសាក្សីនៃខ្ញុំ ថាខ្ញុំនឹងស្រឡាញ់តែអូនសោភិនីមួយនាក់គត់ក្នុងជាតិនេះ ។ បើថ្ងៃក្រោយខ្ញុំគេចកែពាក្យសម្តី បែរទៅជាស្រឡាញ់ស្រីណាម្នាក់ទៀត ក្រៅពីអូនសោភិនី សូមលោកតាបរាមុខនឹង វាយបំបាក់កខ្ញុំ កុំឱ្យខ្ញុំមានជីវិតរស់តទៅទៀត តែបើខ្ញុំមានសេចក្តីស្មោះត្រង់ចំពោះអូនសោភិនីពិតមែន សូមលោកដ៏មានរិទ្ធជួយឱ្យខ្ញុំបានជួបគ្នា ជាប្តីប្រពន្ធកុំបីអាក់ខានឡើយ ។

សោភិនី លើកដៃសច្ចាបណិធានខ្លាំងៗ តបទៅណាស៊ីវិញថា :

ចំពោះនាងខ្ញុំសូមសច្ចាដោយដួងចិត្តបរិសុទ្ធថា នាងខ្ញុំនឹងតាំងចិត្តស្មោះត្រង់តែលើរូបបងណាស៊ីម្នាក់គត់ បើប្រសិនថ្ងៃមុខ នាងខ្ញុំបែរជាមានចិត្តក្បត់វៀចវេរទៅស្រឡាញ់ប្រុសដទៃ ក្រៅពីរូបបងណាស៊ីវិញ សូមលោកដ៏មានរិទ្ធ ដែលស្ថិតនៅក្រោមដើមពោធិ៍ព្រឹក្សនេះ ដាក់ទណ្ឌកម្មដល់ខ្ញុំគ្រប់បែបយ៉ាង កុំឱ្យនាងខ្ញុំងើបមុខរួចពីអន្លង់ទឹកភ្នែកឱ្យនាងខ្ញុំ ស្គាល់តែសេចក្តីទុក្ខ ខ្លោចផ្សា និងវេទនាអស់មួយជីវិត តែប្រសិនបើនាងខ្ញុំមានសេចក្តីស្មោះត្រង់វិញ សូមលោកតាជួយបង្វែរចិត្តឪពុកម្តាយនាងខ្ញុំ ឱ្យស្រឡាញ់បងណាស៊ី ហើយឱ្យនាងខ្ញុំនិងបងណាស៊ីបានគ្នាជាប្តីប្រពន្ធ ទៅហោង ។

សច្ចាស្បថស្បែចំពោះមុខអ្នកតាក្រោមដើមពោធិ៍ រួចស្រេចអស់ហើយ ។ ណាស៊ី និងសោភិនី ក៏ជិះទោចក្រយានត្រឡប់មកកាន់គេហដ្ឋានរៀងៗខ្លួនវិញ ។

~៥~

## សុខចិត្តនៅព្រៅមិនឱ្យខ្ញីរៀបការ

**កើតមកមួយជាតិធាតុមួយក្តាប់ បំណាច់នឹងស្លាប់ជាស្មូលដី**
**ស្នេហ៍មួយចិត្តមួយប្រពន្ធប្តី ប្រុសក្រៅទីទៃមិនប្រាថ្នា ។**
**បើសិនជាស្នេហ៍ប្រែអភ័ព្វ សុខចិត្តពីស្លាប់មិនព្រមការ**
**នៅព្រៅទល់គ្នាថ្ងៃមរណា ឪអើយមេត្តាឱរាកូន ។**

នៅផ្ទះលោកភិរុណថ្ងៃនេះ មានការរៀបចំតុបតែងលំអគេហដ្ឋានប្លែកពីធម្មតា ។ តាំងពីព្រលឹមមកអ្នកបំរើប្រុសស្រីគ្មានឈប់ទំនេរដៃស្ងៀមទេ បន្តិចរត់ទៅខាងផ្ទះបាយ បន្តិចរត់មកជូតខាត់ខាងលើផ្ទះធំ ។

ប្រហែលជាម៉ោង ១០ យប់ រថយន្តមែរសឺដេស (Mercdes 220S) ពណ៌ត្រួយចេកមួយក៏លូនមកចតមុខផ្ទះ ។ អ្នកបើករថយន្តប្រញាប់ចេញមកបើកទ្វារស្លែងក្រោយ ពេលនោះស្ត្រីចំណាស់រាងធាត់បន្តិច ក៏ឈានជើងចុះពីរថ ។ លោកភិរុណ និងលោកស្រីពន្លក ស្ទុះចេញពីក្នុងផ្ទះមកទទួលដល់មាត់ជណ្ដើរយ៉ាងរាក់ទាក់ ។

-សូមអញ្ជើញឡើងលោកស្រី ។

-ចាំ ... ចាំ ... ! មិនអីទេ កាត់ពីភ្នំពេញមកដល់មុខផ្ទះប៉ុណ្ណោះហើយ គង់តែមិនអញ្ជើញក៏ឡើងដែរ ។

លោកស្រីលិនថោង និយាយចំអន់លេងរបៀបគ្នាឯង រួចក៏ឡើងទៅលើផ្ទះធំ ។

អង្គុយស្រួលបួលហើយ លោកស្រីពន្លកក៏ស្រែកហៅក្មេងបំរើឱ្យយកទឹកក្រូច និងផ្លែឈើមកជូនភ្ញៀវ ។ ក្រោយពីលោកស្រីលិនថោងឈរសម្រាកបាត់ហត់ លោកស្រីក៏មានប្រសាសន៍ឡើងថា :

-លោកប្រុសលោកស្រីសុខសប្បាយជាទេឬ ?

-បាទ សុខសប្បាយជាទេ ។

-ចាំះ សុខសប្បាយជាទេលោកស្រី ។

-អា ... ! ចុះក្មួយស្រីទៅណាទៅដូចជាមិនឃើញ ?

-ចាំះ ទៅធ្វើការផ្ទះបាយឯណោះ ( លោកស្រីពន្លកបែរទៅហៅ សោភិនី) សោភិនី ! អី ... សោភិនីចេញមកក្រៅបន្តិចកូន អ៊ីឯងគេមកលេងណែ ...!

សោភិនី ដើរចេញពីផ្ទះបាយមក ដោយទឹកមុខមិនសូវស្រស់ ។

-ជំរាបសួរលោកអ៊ីទៅកូន ។

បុត្រីលោកភិរុណនិយាយឡើង ។

-ជំរាបសួរលោកអ៊ី ។

-អើ លើកដៃថ្វាយព្រះ ! សូមឱ្យអាយុវែងណាក្មួយស្រី ( លោកស្រីបែរទៅញញឹមពព្រាយដាក់លោកភិរុណ) បើចេះគួរសមហើយ ស្អាតម្លឹង។ឱ្យអ្នកណាអត់ស្រឡាញ់បានហក៎ ។

និយាយរួចលោកស្រីលិនថោងក៏សើចកាច់កកាច់ស្រង់ បណ្ដាលឱ្យលោកភិរុណអត់ទ្រាំមិនបាន ក៏សើចតាមគេតាមឯងដែរ ។ លោកស្រីពន្លកដឹងថាសោភិនីអៀន និងមិនសូវសប្បាយចិត្ត លោកស្រីក៏ធ្វើជានិយាយឡើង :

-សោភិនី កូនទៅមើលនាងចែមមើល ប្រាប់វាឱ្យឆាប់យកទឹកក្រូចមកជូនលោកស្រីផង ។

ចាំះ ម៉ាក់ ...

ឆ្លើយហើយ នាងក៏ដើរចូលទៅផ្ទះបាយវិញទៅ ។

បន្តិចមក នាងចែមក៏លើកភេសជ្ជៈ និងផ្លែឈើមកជូនភ្ញៀវ ។ លោកស្រីពន្លកលើកកែវទឹកក្រូចហុចទៅលោកស្រីលិនថេង :

-អញ្ជើញពិសាទឹកក្រូចទៅលោកស្រី ។

-ចាំ ... ចាំ ... កុំព្រួយលោកស្រី ( មាត់តែថា ដៃក៏ទទួលយកកាន់) ខ្ញុំមកនេះ គឺចង់មកសួរសម្រេចចិត្តពីលោកប្រុសលោកស្រី តើរឿងកូនចៅនោះឥឡូវលោកប្រុសលោកស្រីសម្រេចយ៉ាងម៉េចទៅហើយ ។

-ខ្ញុំមិនយល់ទាស់អ្វីទេលោកស្រី ( លោកភិរុណនិយាយ) កិច្ចការទាំងនេះស្រេចតែទៅលើម៉ាក់វាចុះ ...

-អូ ... ! កុំព្រួយឱ្យសោះលោកស្រី ( លោកស្រីពន្លក និយាយកាត់ពាក្យលោកភិរុណ) ខ្ញុំតែថាឱ្យប្រាកដជាឱ្យហើយ សូមតែខាងលោកស្រីកំណត់ពេលវេលាលើកជំនួនភ្ជាប់ពាក្យមកចុះថ្ងៃណាក៏បានដែរ តែថាក្មួយប្រុសកូនលោកស្រី សព្វថ្ងៃគេធ្វើការអ្វីដែរ ? ពីព្រោះប្រាប់ថ្ងៃមុនខ្ញុំ វាភ្លេចទៅហើយ ។

-ចាំះ ... ! គេធ្វើភូឈួយខេត្តណាលោកស្រី ប្អូនកូនខ្ញុំវាត្រឹមត្រូវណាស់ ស្រាក៏មិនចេះផឹក បារីក៏មិនចេះជក់ ហើយបើនិយាយពីរឿងស្រីញីវិញ វាស្អប់ខ្ពើមជាទីបំផុត ។ ឆ្នាំក្រោយនេះឮថាបែបត្រូវផ្លាស់ឱ្យមកនៅសៀមរាបផង កូនខ្ញុំមុខមាត់ស្អាតណាស់ រាងរៅក៏សមសួនជាអ្នកធំ បើនឹងនិយាយស្តីវិញ អ្នកណាក៏គេកោតគោរពវាដែរ ( លោកស្រីលិនថេង ហូតយករូបថតកូនប្រុសមកបង្ហាញលោកស្រីពន្លក) ឃើញទេមុខមាត់វា សមជាអ្នកមានអំណាចណាស់ណាំ ...

លោកស្រីពន្លក យករូបកូនប្រសាក្នុងអនាគតមកពិនិត្យពិច័យយ៉ាងពេញចិត្ត ។ លោកស្រីសប្បាយណាស់ញញឹមបិទមាត់មិនជិតទេ គិតឃើញថាសោភិនីមានសំណាងល្អមែន ។ បន្តិចទៀត សោភិនីនឹងមានគេ ហៅលោកស្រីភូឈួយខេត្ត ចំណែករូបលោកស្រីវិញ ក៏នឹងបានឡើងឋានៈជាម្តាយក្មេកលោកភូឈួយខេត្តដែរ ។ លោកស្រីហុចរូបថតទៅប្តី ហើយបែរមកនិយាយជាមួយលោកស្រីលិនថេងថា :

-អា ... បើឥចឹង លោកស្រីអញ្ជើញទៅភ្នំពេញវិញ ប្រញាប់លើកជំនួនភ្ជាប់ពាក្យឱ្យហើយទៅ បើបានជាសម្រេចថាព្រមឱ្យ ខ្ញុំមិនចង់បង្អែរបង្អង់ឱ្យយឺតយ៉ាវតទៅទៀតទេ ។

-ចាំ កុំព្រួយលោកស្រី បានខាងណេះឱ្យឆាប់របស់ខ្ញុំតែអរខ្លាំងណាស់ទៅហើយ អាប៊ូរិនកូនខ្ញុំម៉្ញៅៗ វារំអុកឱ្យតែខ្ញុំមកសៀមរាបសម្រេចរឿងហ្នឹងទេតើ ! បើតចឹង ខ្ញុំគិតថាសូមលាលោកស្រីត្រឡប់ទៅភ្នំពេញវិញឥឡូវហ្នឹង ។

-ប្រញាប់ម្លេះលោកស្រី នៅសំណាក់នឹងខ្ញុំមួយយប់សិនហើយ ។

លោកស្រីពន្លកឃាត់ជន្លងមិនចង់ឱ្យទៅ តែលោកស្រីលិន ថោងបានប្រកែកដោយបង្ហាញហេតុផលថា :

-នៅមិនបានទេលោកស្រី ណាមួយប៉ាវានៅផ្ទះឯណោះក៏មិនសូវស្រួលខ្លួនផង ណាត្រូវគិតគូររឿងកូនចៅនេះឱ្យឆាប់បានលើកជំនូនមកទៀតណាស់ហើយ ! ខ្ញុំសូមលាសិនហើយណា ។

-បាទ អញ្ជើញ ។

-ចាំះ អញ្ជើញលោកស្រី ។

លោកភិរុណ និងលោកស្រីជូនដំណើរភ្ញៀវមកដល់រថយន្ត ។ បន្ទាប់មកមែរសឺដេស (Mercedes 220 S) ក៏រត់ខ្សៀកចេញផុតពីបរិវេណផ្ទះតំរង់ឆ្ពោះមុខទៅកាន់រាជធានីភ្នំពេញ ។

ព្រលប់ហើយ ...

ក្រោយពេលបរិភោគបាយរួច លោកភិរុណ និងលោកស្រីក៏ហៅ សោភិនីមកសួរស្ងាត់ៗនៅក្នុងបន្ទប់ទទួលភ្ញៀវ ។

លោកភិរុណផ្តើមសួរទៅសោភិនីថា :

-ឥឡូវប៉ានឹងឱ្យកូនមានប្តីហើយ ប្តីឯងនេះគេជាភូឈួយខេត្តផងណា តើកូនយល់យ៉ាងម៉េចដែរ ។

សោភិនី មិនទាន់បានរកពាក្យឆ្លើយនឹងសំណួរបិតានាងផង លោកស្រីក៏និយាយកាត់ឡើងមុន :

-វាត្រូវតែយល់ព្រមរឿងហ្នឹង បានប្តីធ្វើដល់តែភូឈួយខេត្តហើយចង់បានយ៉ាងម៉េចទៅទៀត ។

សោភិនីតឹងតែងក្នុងទ្រូងស្ទើរប្រេះធ្លាយ នេះឬទឹកចិត្តម្តាយចង់រកសុភមង្គលឱ្យកូន ។ បុណ្យស័ក្តិភូឈួយខេត្តមិនបានធ្វើឱ្យនាងព្រឺព្រួច សូម្បីបន្តិចទេ នាងនឹកស្អប់លោកប៊ូរិន ស្អប់លោកស្រីលិនថោង ហើយស្អប់គ្រប់ៗគ្នាដែលចូលមកស្ទីដណ្តឹងនាង ។ ក្នុងលោកមានតែម្នាក់គត់ ដែលនាងស្រឡាញ់គឺរូបណាស៊ីទេវបុត្រស្នេហារបស់នាងមួយប៉ុណ្ណោះ ។

សោភិនី នាងនឹកស្អប់រហូតទៅដល់គំនិតចាស់គំរិលរបស់ឪពុក ម្តាយភាគខ្លះ ដូចជាឪពុកម្តាយនាងជាតួយ៉ាង ដែលចូលចិត្តបង្ខិតបង្ខំកូនឱ្យមានប្តីដោយខ្វះការយល់ព្រមពីសាមីខ្លួន ទុកកូនក្រមុំដូចជាសត្វជ្រូក ចិញ្ចឹមធំធាត់

ឡើងដើម្បីលក់ ដោយសំអាងទៅលើប្រពៃណីចង្រៃមួយប្រយោគថា "នំមិនដែលធំជាងនាឡិ" នារីកំព្រាលបេះដូង អង្គុយគិតអស់ពេលមួយសន្ទុះធំ ទើបដាច់ចិត្តឆ្លើយតបទៅលោកឪពុកនាងវិញទាំងក្ដុកក្ដួលឱរា :

-ខ្ញុំមិនទាន់ចង់បានប្ដីទេលោកប៉ា វ័យរបស់ខ្ញុំនៅក្មេងណាស់ មិនអាចទទួលភារៈជាមេផ្ទះបានទេ សូមលោកប៉ាអាណិតពន្យាពេលឱ្យកូនមានឥស្សរភាព ពីរបីឆ្នាំទៀតសិន ។

-ហ៊ឹះ ! ចាំពីរបីឆ្នាំទៀត ( លោកភិរុណសម្ដែងអាការមិនពេញចិត្ត) ចាំទាល់តែផើមស្នេលជាមួយនឹងអាណាស៊ីទៅឬយ៉ាងម៉េច ? ប៉ាចង់រកសុភមង្គលឱ្យកូន ចង់ឱ្យកូនមានមុខមានមាត់នឹងគេ តែផ្ទុយទៅវិញឯងចង់តែពន្លឹចកេរ្តិ៍ឈ្មោះពូជពង្សត្រកូលឱ្យលិចបាត់នឹងភក់ជ្រាំ នេះហើយឬសេចក្ដីតញ្ញូកតវេទីរបស់ឯងចំពោះឪពុកម្ដាយ ?

ផុតប្រយោគលោកភិរុណភ្លាម លោកស្រីពន្លកក៏ស្រែកគំរាមសន្ធាប់សោភិនីទៀត ។

-ឯងនេះថោកណាស់ អញលែងចេះប្រើពាក្យផ្អែមល្ហែមជាមួយទៀតហើយ មីកំពូចក្អែកខ្មៅ ! ធ្វើម្ដេចវានឹងចូលទៅនៅរួមជាមួយពពួកហង្សកើតចិញ្ចឹមឯងធំឡើងឯងធំឆ្អឹងចង់រើសប្ដីចិត្តឯងឬ ? មីស្រីចិត្តចើក ! ឪពុកម្ដាយរៀបចំផ្សំផ្គុំឱ្យមានមុខមាត់មិនចង់ទេ ចង់តែធ្វើអាសអាភាស តាមព្រៃតាមផ្សៃ ស្រីរបៀបឯងនេះសមតែនៅតាមចិញ្ចើមថ្នល់ទើបវាសមមុខ អញសូមនិយាយឱ្យដាច់ណាត់ថា ឯងត្រូវតែរៀបការជាមួយបូរិនជា ដាច់ខាត ឯងមិនចាំបាច់រកពាក្យអ្វីមកដោះសារទៀតទេ ។

-សូមម៉ាក់អាណិតកូនចុះ ចំពោះរឿងផ្សេងៗ កូនអាចតាមម៉ាក់បានទាំងអស់ តែបញ្ហារើសគូស្រករ សូមម៉ាក់អាណិតបើកសិទ្ធិឱ្យកូនមានសេរីភាពរើសដោយខ្លួនឯងផង ។

និយាយចប់សោភិនីក៏លូនទៅឱបជើងម្ដាយយំខ្សឹកខ្សួល តែត្រូវលោកស្រីរលាស់ជើងចេញ ខាកស្ដោះដោយគ្មានមេត្តា ។

-ឯងមិនបាច់ធ្វើកិច្ចកលមាយាយំសោកឱ្យវាខាតទឹកភ្នែកទេ ! អញរើសប្ដីឱ្យឯងដល់ទៅភូឈួយខេត្ត ប៉ុណ្ណឹងហើយឯងនៅតែមិនពេញចិត្ត ! តើចង់បានដល់ណាទៀត កុង្សីឬ ? ហ៊ឹះ ! ចិត្តឯងអញយល់ហើយ បានជាឯងប្រកែកមិនព្រមយកប្ដី មកពីឯងនៅមិនដាច់អាល័យពី អា ណាស៊ី ។ កុំសង្ឃឹមពេកនាងស្រីល្អ តិចលោថ្ងៃក្រោយទឹកភ្នែកជោកក្បាលជង្គង់ថាអញមិនប្រាប់

លោកស្រីពន្លកឈរយកដៃទឹមចង្កេះ សម្លឹកសម្លក់សោភិនីស្ទើរស៊ីសាច់ ។

ពេលនេះ សោភិនី ខំរួបរួមប្រមូលកម្លាំងចិត្តឱ្យក្លាហាន នាងលែងលាក់ការអាថិកំបាំង និងកោតញញើតទៀតហើយ ។ ជាតិនេះបើមិនបានណាស៊ីមកធ្វើជាប្តី នាងសុខចិត្តនៅព្រៅ ល្អជាជាងទទួលប្រុសដទៃ ដែលនាងមិនស្រឡាញ់ ។

-ម៉ាក់ ! ... ទោះបីស្លាប់រស់យ៉ាងណា ខ្ញុំមិនព្រមទទួលលោកភូឈួយខេត្តបូរិនធ្វើប្តីជាដាច់ខាត បងណាស៊ីគេក្រីក្រពិតមែន តែគេមានចំណេះវិជ្ជាគ្រប់គ្រាន់ មនុស្សម្នាក់ៗ បើសម្លឹងឃើញតែទ្រព្យសម្បត្តិបុណ្យស័ក្តិ សំអាងថាជាសុភមង្គលរបស់ខ្លួន វាមិនបានយូរអង្វែងទេ ឫសគល់នៃការរើសគូស្រករឱ្យបានសេចក្តីសុខដុំរម្មនាតទៅអនាគតវាសម្រេចទៅលើការពេញចិត្តរវាងគ្នា និងគ្នារបស់ស្វាមីខ្លួនទេតើ ? លុះថ្ងៃក្រោយទៅ មានរឿងទាស់ទែងខ្វែងគំនិតរហូតដល់ទៅបាក់បែកគ្រួសារ តើអ្នកណាមួយទទួលខុសត្រូវក្នុងរឿងនេះ មិនរូបខ្ញុំទេឬម៉ាក់ ! ...

លោកស្រីក្តៅណាស់ ដូចជាគេយករងើកភ្លើងមកជះកណ្តាលដើមទ្រូង ស្ទុះទៅទះតប់សោភិនីបីបួនដៃទាល់តែចេញឈាមមាត់ ទើបលោកស្រីឈប់រហត់ ឃូ ! ឃូ ! ហើយស្រែកជេរប្រទេចទៅនាងទៀតថា :

-យើ ! មីឃ្មី ! ហងឥឡូវចេញវប្បធមិចេះប្រៀនប្រដៅអញផង ? (លោកស្រីលាត់សំពត់អង្អើញដូចមនុស្សខ្មោចចូល) អញក្បាលចាស់សក់ស្កូវមួយៗហើយ មិនមែនមកទន់ទោរតាមសម្តីមីក្មេងកើត ម្សិលម្ង៉ៃមិនទាន់ជ្រុះប្រហើយនោះទេ បើហងឯងនៅអាល័យសហាយហងឯងណាស់ ហងចុះចេញពីផ្ទះអញទៅនៅជាមួយវាទៅ បើនៅផ្ទះអញត្រូវតែធ្វើតាមអញ ។

សោភិនី និយាយលែងរួច នាងអស់សង្ឃឹមនឹងពន្យល់ទៀត ហើយបើនាងតែមាត់រឹង នាងនឹងត្រូវលោកស្រីធ្វើទារុណកម្មកាន់តែខ្លាំងជាងនេះជាពុំខាន ។ ទាល់ប៉ុចនារីអង្គុយសំរក់ទឹកភ្នែកយកដៃជូតឈាមមាត់ទាំងឈឺចាប់ ។

-គិតមើលឱ្យស្រួលបួលទៅសោភិនី (លោកភិរុណនិយាយដាក់សំឡេងទន់ភ្លន់) ប៉ាមិនចង់ឱ្យវាអាម៉ាសមុខតទៅទៀត កំហុសដែលវាខុសរួចមកហើយ យើងត្រូវតែកែខ្លួនឡើងវិញ បើកូនឯងមិនព្រមរៀបការ តើឱ្យឪពុកម្តាយយកមុខទៅទុកដាក់ឯណា កិត្តិយសឪពុកម្តាយ និង អាណាស៊ី ឯងដេកគិតទៅមើល ខាងណាវាមានតម្លៃជាង ? ចំពោះវិជ្ជា មានពិតមែន តែដូចឯងឮស្រាប់ វាថាវាឈប់រៀនវាទៅធ្វើស្រែ អ្នកធ្វើស្រែវាមិនមែនបានសុខកាយសប្បាយចិត្តដូចជាគេអ្នករាជការទេ ម្ង៉ៃៗឈរដក ឈរស្ទូងកណ្តាលថ្ងៃក្តៅតើវានឹងមានសេចក្តីសុខពីត្រង់ណាមក?

សោភិនី នឹកស្អប់ណាស់ អ្នកណានិយាយមើលងាយអ្នកស្រែ នាងចង់តបតសម្តីលោកឪពុកនាងវិញ តែរកហាមាត់និយាយមិនរួច ទឹកភ្នែកស្រក់តក់

ៗ គ្មានស្រោកស្រាន្តនាងមិនមែនចង់យំទេ តែទឹកភ្នែកចេះតែហូរចេញមកឯងៗ ។

ប្រាំថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍ចង្រៃកើតមានលើរូបនាងសោភិនី មក ! លោកស្រីលិនថោងក៏លើកជំនូនភ្ជាប់ពាក្យកូនក្រមុំ ដើរដង្ហែជាក្បួន អធឹក អធម្ម គគ្រឹកគគ្រេងផ្អើលគេឯងមើលឈ្ងូរឆរដូចហែកឋិន ។ លោក ស្រីលិនថោងថ្ងៃនេះធ្វើខ្លួនស្អាតបាតណាស់ សក់ទើបនឹងអ៊ុតថ្មីលាបថ្នាំខ្មៅ រំលាយស្កូវមួយៗ ឡើងខ្មៅរលោង ។ នៅត្រចៀកមានពាក់ទំហ៊ូពេជ្រ ដេញថ្ងៃភ្លឺចិញ្ចាចកនិងដៃពាក់មាសក្រហមឆ្អិនឆ្អៅស្ទើរនឹងស្រោបខ្លួនបាន ហើយបើគេក្រឡេកមើលចង្កេះវិញ គេនឹងឃើញខ្សែចង្កេះមាសប៉ុនៗ ចង្កើះធ្លាក់ស្រយាកជិតដល់ទ្រគាក ។

ចំណែកលោកស្រីពន្លក ក៏មិនឱ្យអន់ជាងលោកស្រីលិនថោង ប៉ុន្មានដែរ មាសពេជ្រ គ្រឿងអាភរមានប៉ុន្មាន លោកស្រីយកមកពាក់ព័ទ្ធហ៊ុំ ឈៀងមើលតែពួកទាហ៊ានឆ័ត្រយោង ។ បន្តោងពេជ្រតម្លៃជាងមួយសែនប៉ុនបាតដៃព្យួរនៅនឹងកតេកតោកៗ ចាំងភ្នែកភ្ញៀវស្ទើរចង់ខ្វាក់ ។

ពេលនេះបើគេពិនិត្យមើលឱ្យច្បាស់ទៅឃើញថា ដន្លងទាំងពីរធ្វើខ្លួនជាងកូនក្រមុំទៅទៀត ។ នេះហើយអ្នកមាន ... ពេលធ្វើមង្គលការ ឬបុណ្យអ៊ានអ្វីម្ដងៗ គេប្រកួតប្រជែង, គេប្រកាសសង្គ្រាមគ្នា តែនឹងគ្រឿងអលង្ការមាសពេជ្រ ។ គួរឱ្យអាសូរដល់សោភិនីណាស់ គេសប្បាយរីករាយសើច ក្អាកក្អាយគ្រប់គ្នាខុសអ្វីតែរូបនាងម្នាក់ អង្គុយកើតទុក្ខជំរុះ ទឹកភ្នែក ដូចទឹកសន្សើមធ្លាក់ក្នុងហេមន្តរដូវ ។

នៅចំកណ្ដាលនៃល្វែងគេហដ្ឋាន ភ្ញៀវប្រុសស្រីអង្គុយត្រៀបត្រាចំហមាត់ ចាំស្ដាប់ការចូលស្ដីដណ្ដឹងតាមប្រពៃណី ។ អ្នកមហា និងមេបាសាកសួរចោទឆ្លើយគ្នាទៅវិញទៅមកបែកពពុះមាត់ស្ពុល បើគិតឱ្យសព្វៗទៅមិនខុសគ្នានឹងនាយល្ខែនាងសម្បត្តិ ច្រៀងឆ្លើយឆ្លងនៅមុខវាំលព្រះមេរុក្នុងពេលសមាជិជាតិ ។

ក្រោយពីធ្វើពិធីស្ដីដណ្ដឹងជូនជំនូនដល់ឪពុកម្ដាយខាងស្រី តាមទំនៀមទំលាប់រួចហើយ ពេលរសៀលនៃថ្ងៃនោះលោកស្រីលិនថោង និង ញាតិមិត្តខាងភ្នំពេញ ក៏សូមលាលោកភិរុណ និងលោកស្រីពន្លកត្រឡប់ទៅផ្ទះវិញ ។

## ឃ្លាតកាយណាយចិត្ត

ចិត្តស្រីប្រួលប្រែរដូចស្រល់ តាមខ្យល់កញ្ជ្រោលបោកបក់បែន
ពាក្យស្បថពាក្យស្នេហ៍រាប់ម៉ឺនសែន លុះយកមែនទែនឥតបានការ ។
ឃ្លាតកាយណាយចិត្តគ្មាននឹងភ្នក ឱ្យប្រុសសោយសោកទ្រូងខ្លោចផ្សា
ស្រវឹងមាសប្រាក់បាក់ក្រឡា ឆ្កួតកាមតណ្ហាសង្សារថ្មី ។

ចាប់តាំងពីថ្ងៃលើកជំនូនមក សោភិនីក៏អស់សេរីភាពនាងមិនអាចដើរទៅណាមកណាបានតាមអំពើចិត្តដូចជាពេលមុនទេ ម៉ែ្ញលាក់ខ្លួនពួនអាត្មានៅតែក្នុងផ្ទះ ។ បើមានការចង់ទៅផ្សារ ឬទៅលេងផ្ទះញាតិណាម្តងៗតោងតែមានអ្នកដើរតាមជាអង្គរក្សគ្រប់ៗជំហាន ។

សោភិនី ឥឡូវកាន់តែស្គមដោយនាងព្រួយពេក ពេលយប់គេងមិនលក់ ពេលថ្ងៃញ៉ាំមិនបាន មិត្តកំសត់កម្ររបស់នាងដែលចិត្តស្មោះត្រង់ជាងគេក៏មានតែទឹកភ្នែកមួយមុខប៉ុណ្ណោះ គិតច្រើនយំច្រើន ។ ការទាក់ទងរវាងនាងនិងណាស៊ីត្រូវឃ្លាតឆ្ងាយដាច់ស្រឡះ ជាងពីរខែមកហើយ ដែលនាងមិនបានជួបមុខប្រុសបណ្តូលចិត្តសូម្បីតែបន្តិចបន្តួច ។ អាការរោគប្លែកចេះតែកើតមានឡើងជារៀងរាល់ថ្ងៃ ដូចជាឈឺក្បាលវិលមុខ, ចង់ក្អួតចង្អោរ, ចង់ញ៉ាំម្ជូរ ។ សោភិនីនាងសង្ស័យនឹងនឹកភ័យណាស់ នាងបានទៅលួចសួរយាយម៉មអ្នកធ្វើបាយ ដែលជាអ្នកជំនិតទំនុកទុកចិត្តទីបំផុតនាងក៏ដឹងថា ខ្លួននាងមានផ្ទៃពោះជាងមួយខែរួចទៅហើយ ភ័យណាស់ សោភនីប្រញាប់សរសេរជាកូនសំបុត្រតូចមួយ ប្រើយាយម៉មឱ្យ យកទៅប្រគល់អោយណាស៊ីមានសេចក្តីថា :

បងណាស៊ីបណ្តូលចិត្ត ... !

ឥឡូវនេះអូនមានផ្ទៃពោះជាមួយបង ជាងមួយខែទៅហើយ សូមបងជួយគិតអូនផង តើយើងត្រូវធ្វើយ៉ាងម៉េច ណាមួយថ្ងៃរៀបការក៏កាន់តែកៀកមកហើយដែរ អូនសព្វថ្ងៃអត់ចេញទៅណាបានទេ សូមបង ណាស៊ីអាណិតជួយដោះស្រាយឱ្យបានឆាប់ផង បើមិនដូច្នោះអូនដាច់ខ្យល់ស្លាប់ជាប្រាកដ

សូមតបមកវិញជាប្រញាប់

ទេព-សោភិនី

ណាស៊ី គ្រាន់តែបានទទួលសំបុត្រយកមកអានដឹងសេចក្តី គេរន្ធត់ក្នុងចិត្តស្ទើរប្រេះទ្រូងស្លាប់ ។ សោភិនីជិតការ ហើយមានផ្ទៃពោះ តើគិតជួយនាងម្តេចនឹងកើតគ្មានផ្លូវទេ ឱ ! វាសនាកូនក្នុងផ្ទៃជាតិនេះ ប្រហែលអ្នកធ្លាក់ក្នុងកណ្តាប់ដៃឪថ្មីទេដឹង ?

ក្នុងថ្ងៃនោះណាស៊ី ក៏សរសេរសំបុត្រមួយផ្ញើតាមយាយម៉មទៅ សោភិនីវិញ មានសេចក្តីថា :

សោភិនីមាសបង ... !

បងបានដឹងរឿងអូនអស់ហើយ បងជួយព្រួយនឹងអាណិតអូនណាស់ តែបងមិនដឹងជារកផ្លូវដោះស្រាយជួយអូនយ៉ាងម៉េចកើត បងគិតថា នៅពេលជិតរៀបការ យើងទាំងពីរនាក់ ត្រូវតែសំពះបាទជើងលោកប៉ា លោកម៉ាក់អូន សារភាពជំរាបការណ៍ពិតឱ្យលោកដឹងថា យើងស្រឡាញ់គ្នារហូតមានផ្ទៃពោះ កាលណាបើរឿងនេះគេដឹងឮឡើង លោកបូរិនក៏គេមុខជាមិនព្រមរៀបការជាមួយអូនទេ ឯលោកប៉ាលោកម៉ាក់អូន លោកមុខជាឃើញចិត្តយើងហើយអាណិតអាសូរលើកទោសឱ្យយើងទាំងពីរនាក់ ពុំខាន ។

នេះជាគំនិតចុងក្រោយបំផុតរបស់បង បើអូនយល់ព្រមនៅពេលសល់ពីរបីថ្ងៃរៀបការ បងនឹងទៅសំពះបាទជើង សុំអភ័យទោសពីលោកប៉ា លោកម៉ាក់អូន ... ។

ឌួង- ណាស៊ី

គ្រាន់តែយាយម៉មចេញផុត ណាស៊ីក៏ដើរទៅប្រាសខ្លួនដេកសន្ធឹងសន្ធៃលើគ្រែទាំងទុក្ខព្រួយ ។

យុវជនអភ័ព្វស្នេហ៍ ដេករំពឹងគិតម្នាក់ឯងថា ក្នុងជីវិតនេះ ម្តេចក៏អភ័ព្វជាងគេម្ល៉េះ ព្រហ្មលិខិតចាំតែឆ្លៀតឱកាសទំលាក់ទុក្ខទោស ធ្វើទណ្ឌកម្មគេគ្រប់ពេកវេលា ឪពុកស្លាប់, ម្តាយទីទ័លក្រ, រំពឹងទៅលើតែតិរិះវិជ្ជាដែលខំសិក្សាមក ។ លុះមានសង្សារក៏ត្រូវគេមកពង្រាត់ចេញពីទ្រូងទៀត បើចេះតែមានរឿងទុក្ខសោកផ្ទួនៗគ្នាដូច្នេះ ការសិក្សារបស់គេដែលកំពុងតែខំឱហាតរៀងរាល់ថ្ងៃ វានឹងក្លាយជាយ៉ាងម៉េចទៅវិញ ? ឱ ...,! មធ្យមសិក្សាប័ត្រអើយ ឆ្នាំនេះឬក្នុងជាតិនេះប្រហែលជាខ្ញុំមិនបានយល់អ្នកទេមើលទៅ ...,។

ពេលវេលាចេះតែធ្វើដំណើរទៅមុខឥតអាក់ យប់ហើយថ្ងៃៗហើយយប់ ផ្លាស់វេនគ្នាជាលំដាប់រៀងទៅ ។ នៅសល់តែពីខែទៀតទេ សោភិនីនឹងត្រូវរៀបការហើយ ។

លោកភិរុណ ឃើញបុត្រីចេះតែស្លុបសៅស្គមទៅៗ លោកក៏នឹកព្រួយបារម្ភ ខ្លាចក្រែងសោភិនីធ្លាក់ខ្លួនមានជំងឺដំកាត់ នាំឱ្យខកដល់ពិធីរៀបមង្គលការ ។ ថ្ងៃមួយលោកក៏ផ្ញើសំបុត្រទៅលោកស្រីលិនថោងនៅភ្នំពេញឱ្យអញ្ជើញទៅលេងសៀមរាប ហើយបបួលលោកភូឈួយខេត្ត បូរិនទៅជាមួយផង ដើម្បីឱ្យសោភិនី និងបូរិនបានទាក់ទងដើរលេងស្គាល់ចិត្តស្គាល់ថ្លើមគ្នារសាយពីក្តីទុក្ខ និងបំភ្លេសោភិនីឱ្យឆាប់ភ្លេចណាស៊ី ។

ដូច្នេះហើយ បានជាប្រាំថ្ងៃក្រោយពីលោកភិរុណផ្ញើសំបុត្រទៅភ្នំពេញ គេឃើញរថយន្តមែរសឺដេស 220 S ពណ៌ត្រួយចេកមកផ្ទះលោកម្តងទៀត ។

ប៉ូរិន មន្ត្រីកម្លោះរាងសង្ហារមែន ទាំងសម្តីសំដៅឬកពាក់ទន់ភ្លន់ ហើយអង់អាច សមតាមពាក្យលោកស្រីលិនថោងអួតឥតខ្មោះ ។ ភូឈួយ ខេត្តកម្លោះព្យាយាមវាយខ្លួនឱ្យជិតស្និទ្ធនឹងសោភិនីជាទីបំផុត ។ លោក ភិរុណ បើកអំណាចឱ្យប៉ូរិនបញ្ជិះឡានសោភិនីទៅអង្គរតូច, អង្គរធំ, បារាយណ៍ទឹកថ្លា និងកន្លែងសប្បាយផ្សេងៗទៀងជាច្រើន ។ តែ ... ទោះ ជាយ៉ាងនេះក៏ដោយ សោភិនីពុំបានត្រេកត្រអាលសប្បាយរីករាយ ឬរាក់ទាក់តបនឹងប៉ូរិនវិញទេ នាងអង្គុយក្នុងរថយន្តថ្មីងថ្មៃដូចរូបចម្លាក់ ទុកឱ្យប៉ូរិននិយាយប្រាជ្ញព្រោកឆ្កាដៃជើង ដូចមនុស្សឆ្កួតតែម្នាក់ឯង ។ សោភិនីនាងកំពុងបង្ហើរវិញ្ញាណទៅរកណាស៊ីទេវបុត្រស្នេហារបស់នាង តែមួយងណោះ នាងបន់ឱ្យជិតដល់ថ្ងៃរៀបការ នាងនឹងអាលទំលាយការពិតប្រាប់ទៅឪពុកម្តាយនាង នឹងឪពុកម្តាយប៉ូរិនឱ្យដឹងខ្លួន ។

លោកស្រីលិនថោងឃើញកូនកម្លោះ និងកូនក្រមុំមិនសូវចុះសម្រុងគ្នា លោកស្រីក៏សុំអនុញ្ញាតពីលោកភិរុណ ឱ្យប៉ូរិននាំសោភិនីទៅលេងកំពត, កែប, ក្រុងព្រះសីហនុទៀត ។

ប៉ុន្មានថ្ងៃក្រោយមក មែរសឺដេស (Mercede’f 220 S)ក៏បោលកាត់ផ្សែងធូលីនាំសោភិនីចេញផុតពីសៀមរាប ឆ្ពោះទៅក្រុងព្រះសីហនុ, កំពត, កែប, តាមចំណង់ម្ចាស់របស់វា ។

តាមទស្សនវិទូផ្នែកវិទ្យាសាស្ត្រ ថាផែនដីយើងវិលពិតជាត្រូវមែន ចំណែកចិត្តមនុស្សលោកក៏វិលវល់ រកជឿយកប្រាកដទាត់ទៀងមិនបានដែរ ។ យ៉ាងណាមិញ សោភិនីដែលជានារីម្នាក់មានចិត្តស្មោះត្រង់ប្តូរផ្តាច់ចំពោះណាស៊ីជាគូសង្សារកម្សត់កម្រតាំងពីដើមទីមក ឥឡូវដោយប៉ូរិននាំដើរលេងនិយាយបញ្ចុះបញ្ចូល ចាយវាយប្រាក់កាសហ៊ឺហាគ្មាន ញញើតដៃ សប្បាយចិត្តនិងជិះឡានថ្មីយកខ្យល់ពេលល្ងាចត្រជាក់ ។ ដឹកនាំបង្វក់ខួរក្បាលនាងឱ្យត្រឡប់ធាតុយល់តែការសប្បាយ ហ៊ឺហា, ផឹកស្រាបារាំង, ជក់បារី, រៀនរាំ ។ ចូលចិត្តកាត់សំពត់អាវណាស្តើងៗ ស្ទើរតែមើលសាច់ខាងក្នុងឃើញទាំងអស់ ដំណើរដែលធ្លាប់តែដើរស័ក្តិសម ក៏រៀនពាក់ស្បែកជើងកែងចោត មួយតឹកដើរទើសទាសងរមុខងរក្រោយ ដូចមនុស្សដំបៅលេច ។ នេះហើយឬការស៊ីវិល័យរបស់អ្នកទីក្រុង ?

មិនយូរប៉ុន្មាន អារ្យធម៌ទីក្រុងក៏ស្រោបដួងវិញ្ញាណរបស់សោភិនី ជិតអស់ នាងលែងនឹកនាណាស៊ីហើយ សូម្បីសៀមរាបក៏នាងចង់ភ្លេចដែរ ដែលនាងចាំច្បាស់ក៏មានតែប៉ូរិនកំពូលដួងចិត្តរបស់នាងមួយប៉ុណ្ណោះ នាងនឹក

សរសើរវាសនានាងថាខ្ពស់មែន ចេះបានមកជួបនឹងបូរិន កុំអីនាងមុខជាត្រូវខកខ្លួននឹងណាស៊ីជាមិនខាន បូរិនរបស់នាងស្អាតណាស់ គេចេះពោលពាក្យស្នេហាយ៉ាងផ្អែមត្រជាក់ ក្លិនគេក៏ក្រអូបឈ្ងុយឈ្ងប់ប្រស់ព្រំទៅដោយទឹកអប់ធុនថ្លៃៗ មិនធុំញើសឆ្អេះឆ្អាបដូចជាណាស៊ីទេ បាតដៃគេទន់ល្មើយស្ទាបប៉ះត្រង់ណាក៏ចេះតែឱ្យស្រើមស្រាល ចង់តែធ្មេចភ្នែក ពេលគេងក៏គេជួយដោះអាវឱ្យជូនកាលគេជួយទាំងដោះអាអាវទ្រនាប់ រីនៃតាទៅទៀត ។ មិនដូចជា ណាស៊ីល្ងង់ណាស់មិនចេះស្ទាប, មិនចេះ ថ្នាក់ថ្នម, មិនចេះដោះអាវឱ្យ ពោលសរុបសេចក្តីបុរសក្នុងលោក សោភិនី ចាត់ទុកថា ចាញ់បូរិនរបស់នាងទាំងអស់ ។

ឱហ៎្ន ... ចិត្តស្រីវេដូចចុងស្រល់ តើក្នុងលោកមានស្រីរបៀប សោភិនីប៉ុន្មាននាក់ ? ហើយស្រីចិត្តសាវ៉ារបៀបសោភិនីនេះ ឱ្យឈ្មោះអ្វីសម ? ច្រើនឈ្មោះណាស់ បើតាមតែកំហឹងយើងចង់ដាក់ឱ្យ ស្រីកាកី ! ស្រីមេអំបៅ ! ស្រីចិត្តចើក ! ស្រីសាវ៉ា ! ស្រីក្បែកមាស ! ។ល។

នៅលើសណ្ឋាគារក្រុងកែប សោភិនីពាក់អាវវែងនីឡុងស្តើង មើលឃើញសាច់ខាងក្នុង (សម្លៀកបំពាក់នេះគេសម្រាប់ពាក់ដេកយប់ គឺមានតែអាវស្តើងហើយស្រូងដល់កែងជើងអត់សំពត់ទេ) ដេកគងអន្ទាក់ខ្លា បង្ហយបារីបញ្ចេញសាច់ភ្លៅសស្គុះដូចត្រយូងចេកមកខាងក្រៅ ។ ពេលនោះបូរិនដើរចូលមក លោកស្រីលិនថោងដឹងអធ្យាស្រ័យកូនកម្លោះគាត់ណាស់ គាត់ស្ទុះចេញទៅក្រៅហើយទាញទ្វារផ្ទឹបជិតមកវិញ ។

-បងទើបនឹងមកពីផ្សារឬ ?

សោភិនីសួរ កាលបើឃើញបូរិនមកអង្គុយផ្លាស់សារុងជិតនាង។

-ត្រូវហើយអូន បងទើបនឹងមកពីផ្សារ ចាំថ្ងៃក្តៅបន្តិចយើងនាំគ្នាទៅងូតទឹកសមុទ្រទៀតណា ។

-ចាំ ... បង ... ។

បូរិនមាត់តែនិយាយ ភ្នែកខំសម្លឹងមើលសាច់ភ្លៅសស្គុះរបស់ សោភិនីស្ទើរលៀនគ្រាប់ភ្នែក គគ្រឹត ! គេហៀរទឹកមាត់ ! ដូចយើងឃើញគេស៊ីអំពិលខ្ទិះចឹង ។ មិនចាំបាច់ទេមទោមឱ្យយូរការ បូរិនក៏ប្រាសខ្លួនដេកជិតសោភិនី ដៃត្រកងពីប្រាណដ៏ល្អតល្វៃមកឱបរឹត យ៉ាងក្រហល់ក្រហាយដូចសុនខដាច់សង្វែង ហើយពើមប្រទះនឹងត្រពាំងទឹកថ្លាខ្យង ។

ពេលនេះ គេកំពុងកាន់ដៃគ្នាទៅឋានសួគ៌ហើយ គេសើច, គេប្រឡែង, គេឱបរឹតយ៉ាងគ្មានកោតក្រែង ឬខ្មាសអៀនអ្នកណាទាំងអស់។ រីឯលោកស្រីលិនថោង ឈរទំពារស្លាផ្ទាច់ៗ នៅខាងមុខបន្ទប់រង់ចាំពេលវេលាគេនឹងបើកទ្វារឱ្យគាត់ចូលទៅវិញ ។

## ភ្លេចបងហើយឬអូន ?

ផែនជីវិតវល់ពុលគំនិត ស្រស់ស្រីបែកចិត្តព្រមរៀបការ
ភ្លេចភ្លាំងវិញ្ញាណឃ្លានតណ្ហា ចិត្តថ្លៃសាវាឬស្បាក្រៃ ។
សោភិនីភ្លេចបងហើយឬអូន ទ្រូងរវៀមស្រពោនសូន្យស្មើរក្ស័យ
ដូចយកកាំបិតមកប្រល័យ ចាក់ចំហឫទ័យឱ្យមរណា ។

សោភិនី បានមកដល់សៀមរាបវិញហើយ ។ លោកភិរុណ និង លោកស្រីពន្លកត្រេកអរណាស់ ដោយដឹងថាកូនលោកផ្លាស់ចិត្តគំនិតបែរមកស្រុះស្រួលព្រមស្រឡាញ់ប៉ូរិន ។

នៅតែ ៧ ថ្ងៃទៀតទេ នឹងដល់ថ្ងៃចូលរោងអាវាហ៍វិវាហ៍មង្គលមុខផ្ទះលោកភិរុណ ពួកអ្នកបំរើស្រីប្រុស និងញាតិអ្នកស្រុកជិតខាង កំពុងជួយគ្នាសង់រោងការយ៉ាងប្រញ៉ាប់ប្រញាល់ ។ ដំណឹងអាពាហ៍ពិពាហ៍រវាងលោក ភូឈួយខេត្ត ប៉ូរិន និងកញ្ញាសោភិនីក៏ឮសុសសាយពេញទាំងក្រុងសៀមរាប ។

-គួរអាណិតណាស៊ីណាស់ គេគ្រាន់តែបានដំណឹងថាមួយអាទិត្យទៀតសោភិនីរៀបការ ប្រុសកម្លោះងងឹតមុខឈរចង់ដួលទាំងជំហរ ភ័យណាស់ ! ស្តាយណាស់ ! ខ្លាចបានសោភិនីទៅគេ ។ ណាស៊ីរៀនលែងចូល គិតលែងឃើញជីវិណ ចិត្តគេនឹកមមៃរកតែសោភិនីមួយយ៉ាង ហើយគេក៏ក្លាយទៅជាមនុស្សខូចចិត្តភ្លីភ្លើ និយាយច្រើន ភ្លេចមុខភ្លេចក្រោយ ។

មួយថ្ងៃ ... ពីរថ្ងៃ ... រហូតនៅសល់តែបីថ្ងៃទៀតត្រូវរៀបការក៏មិនទាន់ឃើញស្រមោលនាងសោភិនី ឬសំបុត្រស្នាមអ្វីមកឱ្យដំណឹងគេបន្តិចសោះ ។ ណាស៊ីចេះតែអង្គុយចាំមើលផ្លូវសង្សារ គេមិនបានដឹងថា សង្សារគេកំពុងឈ្លក់វង្វេងនឹងប្រុសថ្មី បំភ្លេចរូបគេចោលឡើយ ។

ល្ងាចមួយ ណាស៊ីក៏សម្រេចចិត្តស្ទាត់ទៅជួបសោភិនី ។ គេទ្រាំលែងបានហើយ ពេលនេះទោះជាអ្នកណាយកទៅកាប់សម្លាប់ ក៏ត្រូវតែទៅជួបសោភិនី មួយភ្លែតសិនដែរ ។ ទៅដល់ក្បែរផ្ទះក្រឡេកឃើញរោងការ ណាស៊ីស្លុតចិត្តចង់រកកលខ្យល់ចាប់ ភ្នែកខំរេរំពៃគយគន់រកសោភិនី តែ ... មិនឃើញនាងសោះ ។ ឱ ... សោភិនីអើយ អូននៅឯណាទៅ តើអូនដឹងថាបងមករកអូន ឬ

ទេ ? ម្តេចក៏បាត់ស្ងាត់ស្ងៀមមិនឃើញអូនដូច្នេះ ឬក៏អូនកំពុងកើតទុក្ខយំសោក ទឹកមកបង កុំកើតទុក្ខពេកសោភិនីអូន ! បើពិតជាគូព្រេងយើងគង់មិនព្រាត់គ្នាឡើយ ! បងមិនបោះបង់អូនទេ ពាក្យសម្បថ និងអនុស្សាវរីយ៍ទាំងប៉ុន្មាន បងនៅចាំជានិច្ច ... ! ឥឡូវបងកំពុងតែមករកអូនដើម្បីយើងទាំងពីរនាក់ទៅសំពះបាតជើងលោកប៉ាលោក ម៉ាក់ ជំរាបការពិតឱ្យលោកបានជ្រាប ។

ណាស៊ីកំពុងឈរគិតភ្លេចខ្លួនក្បែររបងផ្ទះលោកភិរុណ ។ រថយន្ត មែរសឺដេស 220 S មិនដឹងជាមកពីកន្លែងណា ក៏ស្រាប់តែបត់វេរកាត់មុខណាស៊ី ។ សោភិនីនាងឃើញដែរ តែនាងបែរមុខចេញធ្វើជាមិនឃើញ ។ ស្រីកាកីកាន់ដៃលោកបូរិនឡើងជណ្តើរទៅខាងលើផ្ទះធ្វើព្រងើយ ។

ណាស៊ីកម្លោះកំព្រាបេះដូង ខំអើតមើលតាមគេទាល់តែគេបណ្តើរគ្នាឡើងទៅខាងលើផ្ទះបាត់ ។ឆ្ងល់ណាស់ហេតុអ្វីបានជាសោភិនី មិនមើលមកគេ ឬមួយនាងមិនឃើញ ... ឬមួយនាងភ្លេចរូបគេទៅហើយ ។ ឈរចាំទាល់តែព្រលប់ងងឹត មិនឃើញសោភិនីចុះមក ណាស៊ីក៏ដើរត្រឡប់ទៅផ្ទះវិញ ។

ព្រឹកស្អែកឡើង ណាស៊ីក៏មកឈរចាំជួបសោភិនីនៅកន្លែងដដែលទៀត ភ្នែកខំប្រឹងសម្លឹងមើលទៅលើផ្ទះស្ទើរមិនពព្រិច ឈរចាំរោយជើងហើយក៏ចេះតែចាំតទៅទៀត ទាល់តែថ្ងៃជិតត្រង់ទើបគេភ្ញាក់ព្រើតដោយឃើញសោភិនីដើរចុះពីលើផ្ទះ ហើយមានកាន់ក្រណាត់ព្រៃមួយដុំធំ ទំនងជាទៅកាត់សំពត់អាវ ។ ណាស៊ីត្រេកអរណាស់ប្រញាប់ស្ទូតដំណើរតាមទៅដល់ជិតគេក៏ស្រែកហៅនាងពីក្រោយ :

-សោភិនីអូន ... !

ស្រស់ស្រីបែរខ្វាប់មករកអ្នកហៅ លុះឃើញណាស៊ីហើយ ទឹកមុខដែលញញឹមអម្បាញ់មិញក៏ប្រែជាក្រញូវមួយរំពេច ។

-បងណាស៊ីទេឬ បងមកនេះមានការអ្វីទៀត ?

សោភិនីនិយាយទៅកាន់ណាស៊ីធ្វើឈ្លើយ ហាក់ដូចជាមនុស្សមិនធ្លាប់ទាក់ទងគ្នាពីមុនសោះ ។

ណាស៊ីឆ្អែតណែនក្នុងដើមទ្រូង គេមិនចាប់ភ្លឹកថានឹងបានឮពាក្យដូច្នេះពីមាត់សោភិនីទេ ខ្លួនប្រាណទាំងមូលញ្ជាប់ញ័ររន្ធត់ តែគេខំសង្កត់ចិត្តស្តីទៅសោភិនីវិញ :

-សោភិនី ... ! ម្តេចក៏ឆាប់ភ្លេចបងម្ល៉េះអូន ... អូនមិនស្គាល់ ណាស៊ីទេឬ ? ណាស៊ីនេះហើយ ដែលស្រឡាញ់ស្មោះត្រង់នឹងអូន ហើយ ណាស៊ីនេះទៀត ដែលអូនធ្លាប់និយាយថា និងស្មោះត្រង់បូរផ្តាច់ សុខចិត្តស្លាប់រស់ជាមួយគ្នា ទោះជាមានឧបសគ្គមករារាំងយ៉ាងណាក៏ដោយចុះ ឥឡូវ ... ពាក្យទាំងនេះវាបាត់ទៅឯណាអស់ហើយ ... ! សម្បថនៅលើខ្នងភ្នំ នៅក្រោមដើមពោធិ៍មុខ

ខុមអ្នកតា វាប្រែជាគ្មានន័យទៅវិញហើយឬ ? ឱ ... សោភិនីអូន ចិត្តអូនម្តេចក៏ឆាប់ប្រែប្រួល ងាយស្បថងាយភ្លេចទៅវិញម៉្លេះ ...

សោភិនីឮពាក្យដំអូញ ប្រកបដោយស៊កសៀតដាក់ផ្ទៃផ្ការបស់ ណាស៊ី នាងខឹងណាស់មុខឡើងក្រហមងាំង នាងនិយាយគំរោះគំរើយទៅដាក់ណាស៊ីវិញថា :

-ហ៊ឺះ ! បងទៅរើកកាយយករឿងយល់សប្តិពីរាជណាមកនិយាយនេះ ខ្ញុំជាកូនត្រូវតែលុះដោយដំបូន្មានឪពុកម្តាយ កាលមុនខ្ញុំនៅឆោតនៅល្ងង់ទើបបងបោកប្រាស់ខ្ញុំបាន ឥឡូវបងចង់មកបោកបញ្ឆោតទៀតឬ ? បងជាកូនសិស្សមានតំរិះវិជ្ជខ្ពស់ គួរណាស់តែយកតំរិះវិជ្ជាដែលរៀនចេះដឹងទៅប្រកបជាមុខរបរចិញ្ចឹមជីវិតនៅក្រសួងណាមួយ មិនគប្បីយកតំរិះវិជ្ជាមកព្រលោមចិត្តកូនក្រមុំគេឥចឹងទេបង ។ រឿងអាក្រក់ដែលវាកន្លងហួសមកហើយ ខ្ញុំមិនប្រកាប់ទោសទេ ខ្ញុំគិតថាវាជាគ្រោះថ្នាក់ប្រចាំជីវិតរបស់ខ្ញុំទៅចុះ តែចាប់ពីពេលឥឡូវទៅ សូមកុំមកតាមឆាឆៅផ្តន្ទាឈ្នា នីសខ្ញុំតទៅទៀត ។

-ពីរោះណាស់សម្តីអូន ! (ណាស៊ីនិយាយទាំងចុកចាប់) សម្តីពិរោះផ្អែមល្ហែមប្រដូចទឹកឃុំលាយជាតិពុលនេះហើយ ដែលធ្វើឱ្យបងភ្លេចកំណើតខ្លួន ! ភ្លេចការរៀនសូត្រ ! ភ្លេចអ្វីៗទាំងអស់នៅក្នុងលោក ! តែទីបំផុតបងក៏ត្រូវជាប់ចោទថាជាអ្នកបោកប្រាស់អូនទៅវិញ ហា៎ ! ហា៎ ! ហា៎ ! ប្រសើរមែនសោភិនី ! ស្ត្រីរបៀបអូនក្នុងលោកមិនរកបានទេ ប្រវត្តិសាស្ត្រស្នេហាគេគង់តែនឹងចារឈ្មោះអូន ទុកក្នុងក្រាំងកាមទេពជាពិតប្រាកដ ហា៎ ! ហា៎ ! ហា៎ !

ណាស៊ីពេលនេះមានកាយវិការមិនខុសពីមនុស្សវិកលចរិត គេសើចគេពេប, ឈរជ្រែងចង្កេះនិយាយខ្លាំងៗ គ្មានខ្លាចអ្នកណាឮ :

-សោភិនីនារីរូបស្រស់ ! ក្នុងលោកគ្មាននរណាស្រស់ឆើតឆាយ ដូចអូនទេ ទាំងសម្តីក៏ស្រស់ ! រូបរាងក៏ស្រស់ ! សរុបសេចក្តីទៅអ្វីៗក្នុងរូបអូនស្រស់ទាំងអស់ ! ហា៎ ! ហា៎ ! អ្នកដែលអាចយកមកផ្ទឹមនឹងសម្រស់អូនបានមានតែមួយគត់ គឺនាងកាកី !

ថាផុតមាត់ ដៃមួយក៏ចាប់ស្មាគេជាប់ ណាស៊ីងាកទៅក៏ឃើញបូរិន គូដណ្តឹងរបស់សោភិនី កំពុងមើលមកគេស្ទើរស៊ីសាច់ ។

-មានកើតរឿងអីឬអូននី ! ហើយអាគាត់នេះវាជាអ្នកណា ។

សោភិនីសើចចំអកឱ្យណាស៊ីបន្តិច ទើបនាងបែរនិយាយទៅ លោកបូរិន :

-ខ្ញុំមិនដែលស្គាល់ទេបង ! មិនដឹងមកពីណាផង ស្រាប់តែមកស្រែកឡូឡាដាក់ខ្ញុំ ... !

សោភិនី និយាយមិនទាន់ផុត លោកភូឈ្លួយខេត្តប៉ូរិនក៏ដាល់មាំង ! ចំធ្គាមណាស៊ី ហើយវ៉ៃធមួយជើងចំឆ្អឹងជំនីលាន់ឮសូរអឿក ! បណ្តាលឱ្យជនសម្បត់ ដួលស្រប៉ាបក្រោកលែងរួច ។

-យើ ! អាក្របីព្រៃ ( លោកប៉ូរិនឈរបោសដៃនិយាយស្រែកគំរាមទៅណាស៊ី) ឯងមកពីណាក៏ហ៊ានសម្តីខែងម្លេះ នេះជាប្រពន្ធរបស់អញណា បើឯងចង់និយាយសម្តីរបៀបនេះ ត្រូវឯងទៅរកកន្លែងនិយាយ ជាមួយស្រីផ្សេងទៀតទៅ ឬមួយក៏អាឯងឆ្កួត ? បើថាឆ្កួតអញនឹងដាក់ឡានបញ្ជូនទៅព្រែកត្នោត ឆ្អើយ ... !

លោកប៉ូរិន ខាកស្តោះទឹកមាត់រួចដើរទៅកាន់សោភិនី ។ ពេលនោះមនុស្សម្នាក៏ផ្អើលឈ្ងូរឆរ មកចោមរោមព័ទ្ធកន្លែងកើតហេតុពេញមួយរំពេច ។

-ទៅផ្ទះវិញអូន កុំនៅឈរមើលអាចំកួតស្អីគេហ្នឹង ! បើចង់ទៅណាមកណាក្រោយប្រាប់បងៗនឹងជូនឡានទៅ ឈប់ដើរម្នាក់ឯងទៀត ឮទេ ?

-ចាំះ បង ... !

លោកប៉ូរិន និងសោភិនី នាំគ្នាឡើងរថយន្តបើកចេញទៅបាត់ ហើយពេលនោះខ្ញុំមកពីផ្សារឃើញគេឈរមើលអ៊ូអរក៏ចង់ដឹងដើរចូលមកមើល ។ លុះឃើញណាស៊ីបែកឈាមមាត់ ខ្ញុំភ័យណាស់ ! ស្ទុះទៅលើកគ្រាហ៍ភ្លាមមក ! ប្រាប់ខ្ញុំឱ្យឆាប់មកណាស៊ី !

ណាស៊ីគ្រវីក្បាលព្រមទាំងឆ្លើយមកខ្ញុំវិញថា :

-កុំទាន់ចង់ដឹងអីសំណាង ចូរមិត្តជួយនាំខ្ញុំទៅផ្ទះសិន ។

ទាល់តែរិះខ្ញុំលែងហ៊ានសួរតទៅទៀត ក៏ជួយគ្រាហ៍ណាស៊ីដាក់រ៉ឺម៉កត្រឡប់ទៅផ្ទះវិញ ជាបន្ទាន់ក្នុងគ្រានោះ ។

~៨~

## អាពាហ៍ពិពាហ៍សង្សារខ្ញុំ

អាពាហ៍ពិពាហ៍សង្សារខ្ញុំ    មេបាចាស់ទុំបាចផ្កាស្លា
អូនឱបក្រួញក្រាបសិរសា    ភ្លេចអស់ស្នេហាគ្រាកម្សត់ ។
ស្តាប់សូរភ្លេងកន្សែងក្រហម    គេផ្ទាក់គេផ្ទមទីបំផុត
បងឈរភ្លេចភ្លាំងកាយស្រយុត    អាសូរតែបុត្រក្នុងផ្ទៃអូន ។

បីថ្ងៃក្រោយមក ពិធីរៀបមង្គលការរវាងលោកបូរិន និងសោភិនីក៏មកដល់ ។ នៅមុខផ្ទះលោកភិរុណមានរៀបចំតុបតែងលំអទៅដោយស្លឹកដូង និងដើមទន្សែ ព័ទ្ធវង់ខ្វាត់ខ្វែងដូចរោងមហោស្រព ។ ឧគ្ឃោសនស័ព្ទពីរចងលើចុងដូង បញ្ចេញសំឡេងភ្លេងការកន្ទ្រែងក្រហមព្នរងំ ធ្វើឱ្យបេះដូងក្រមុំ កម្លោះដែលមកជួយក្នុងពិធីមង្គលការលន្លង់លន្លោច ព្រឺព្រួចគ្រប់ៗអាត្មា ហើយលបលួចសម្លឹងមុខគ្នាទៅវិញទៅមក សង្ឃឹមញញឹមទុកក្នុងចិត្តតែរៀងខ្លួន ។

នៅលើផ្ទះធំ កូនក្រមុំ និងកូនកម្លោះ កំពុងក្រាបសំពះឱនក្បាល ដល់ខ្នើយ ចាំស្តាប់លោកអាចារ្យរៀបចំផ្សំផ្គុំបាចផ្កាស្លា និងឱ្យពរតាមប្រពៃណី ។ ផុតពីលោកអាចារ្យមក អ្នកមហាមេបាចាស់ទុំទាំងសងខាង ក៏ចូលចងខ្សែអំបោះក្រហម លើកដៃក្រមុំកម្លោះម្តងម្នាក់ជាសញ្ញាថា យល់ព្រមទទួលស្គាល់អ្នកទាំងពីរ ជាប្តីប្រពន្ធចាប់តាំងពីពេលនេះទៅហើយ ។ លុះដល់ម៉ោង ៦ ល្ងាច ទើបមានរៀបចំពិធីជប់លៀងភ្ញៀវ កូនកម្លោះកូនក្រមុំចេញមកហុចបារីម្តងទៀតជាសំរេចកិច្ច ។

នៅផ្ទះណាស៊ីងណោះ មីងមឿនអង្គុយបញ្ឈរក្បាលជង្គង់ជូតទឹកភ្នែកអាណិតកូនប្រុសបណ្តូលចិត្តគាត់ស៊ីងរលួយថ្លើមប្រម៉ាត់ ។ ពីរបីថ្ងៃហើយណាស៊ី មិនព្រមស៊ីបាយទឹកសោះ សាលារៀនក៏គេមិនទៅ ម៉ៃៗអង្គុយសំកុកនៅតែក្នុងបន្ទប់ ។ ជួនកាលគេយំ ផុតពីយំទៅគេសើច ។ ឱហ្ន៎ ... ! សេចក្តីស្នេហាកាចសាហាវណាស់ វាធ្វើឱ្យមនុស្សចេះដឹងត្រឡប់ទៅជាឆ្កួតបានដោយងាយយ៉ាងនេះទេតើ បានជាគេហាមផ្តាច់ចំពោះយុវ ជនយុវនារី ដែលកំពុងស្ថិតក្នុងវ័យរៀនសូត្រមិនឱ្យមានស្នេហា តែមានហើយវាក៏មានទុក្ខ រៀនលែងចូល, ចិត្តរវើរវាយ, ដូចណាស៊ីជាតួយ៉ាង ។ គប្បីយុវជន យុវនារីទាំងឡាយចៀសវាងឱ្យផុតពីរណ្តៅជ្រោះស្នេហា ។

មីងមឿន ចូលទៅក្នុងបន្ទប់អង្គុយជិតកូន គាត់យកដៃស្ទាបក្បាលណាស៊ីស្រាលៗ ដោយសេចក្តីស្រឡាញ់ និងអាណិត ។

-ខំកាត់ចិត្តខ្លះៗទៅកូន ប្រហែលជាគេមិនមែនជាគូនឹងយើងពីជាតិមុនទេ បានជាជាតិនេះយើងគ្មានសំណាងរួមរស់វាសនានឹងគេដូច្នេះ ។

មីងមឿនឈប់ស្ងៀមបន្តិច គាត់ទាញជាយក្រមាពាក់លើស្មាយកមកជូតទឹកភ្នែក ដែលចេះតែហូរហៀរមក រួចហើយគាត់ក៏និយាយតទៅទៀត :

-ម៉ែបាននិយាយប្រាប់ឯងជាច្រើនដងហើយដែរ តែឯងមិនព្រមស្តាប់ពាក្យម៉ែសោះ យើងកើតក្នុងត្រកូលអ្នកក្រ កុំលោភលន់ចង់ធ្វើវាសនានឹងអ្នកមានទ្រព្យសម្បត្តិពេក ... ពូជក្អែកត្រូវទៅតាមហ្វូងក្អែក មិនអាចទៅលាយឡំជាមួយហ្វូងហង្សបានទេ ... ទីបំផុតនៃការជំនះចិត្តវានាំអស់សង្ឃឹមក្នុងជីវិតកូន

ស្ត្រីស្អាតរបៀបសោភិនីក្នុងលោកមិនមែនមានតែមួយទេ នៅមានសល់ច្រើនណាស់ ! កូនត្រូវខំរៀនវិញឡើង ដើម្បីប្រឡងយកមធ្យមសិក្សាប័ត្រ កុំឱ្យគេដៀលថា យើងខូចចិត្តប្រឡងធ្លាក់ព្រោះរឿងស្នេហា អនាគតខាងមុខនៅចាំទទួលយើងជានិច្ច ។

ទោះជាឮពាក្យម្ដាយដាស់តឿន ហើយ ខ្លួនគេខំកាត់ចិត្តយ៉ាងណា ក៏នៅតែបំភ្លេចរូបសោភិនីមិនបាន ។ គេនៅតែនឹកអាឡោះអាល័យអនុស្សាវរីយ៏ចាស់ៗ វាចេះតែកញ្ជ្រោលផុសផុលក្នុងគំនិត ឱ្យគេគិត ឱ្យគេស្រមៃ ហាក់ដូចជានៅថ្មីៗ ក្លិចផ្កាល់ក្រអូបប្រហើរ ពាក្យសម្បថដែលថានឹងស្រឡាញ់តែគេមួយនាក់ក្នុងជាតិនេះ ចុះឥឡូវបាត់ទៅឯណាអស់ហើយ ។ អ្នកតាក្រោមដើមពោធិ៍ធ្លាប់ល្បីល្បាញខាងធ្វើឱ្យគេចុកពោះ ! ខាងទទួលពាក្យសម្បថ ! ឥឡូវម្ដេចមិនឃើញមកជួយគេផង ម្ដេចក៏មិនទៅកាច់កសោភិនីឱ្យស្លាប់បាត់ទៅ ទុកនាងឱ្យរស់នៅធ្វើអ្វីទៀត ។

ណាស៊ីដកដង្ហើមធំគេបែរមើលមុខម្ដាយទាំងអណោចអធម្មក្នុងចិត្ត

-ឈប់យំទៅម៉ែ ... ! កុំមកកើតទុក្ខនឹងខ្ញុំខ្លាំងពេក នេះជាកម្មរបស់ខ្ញុំទេ សោភិនីធ្វើឱ្យខ្ញុំផុតសង្ឃឹមគ្រប់យ៉ាងក្នុងជីវិត តែអកុសលណាស់ ! ខ្ញុំនៅតែបំភ្លេចនាងមិនបាន ខ្ញុំខ្មាសគេណាស់ម៉ែ ! ចង់តែស្លាប់ឱ្យបាត់ពីលោកនេះទេ ! រស់ធ្វើអ្វីមិនដូចប្រុសគេឯង ... ។

ម៉ោង ៦ ល្ងាចហើយ ...

នៅផ្ទះលោកភិរុណ ភ្ញៀវប្រុសស្រីកំពុងអញ្ជើញចូលមកជាបន្ទាប់បន្ត រថយន្តតូចគ្រប់ម៉ាកគ្រប់ធុនចតរៀងរាយតាមមាត់ស្ទឹង ។ ឧគ្ឃោសនស័ព្ទបានពន្លឺបទចម្រៀងសម័យដែលនិពន្ធឡើងដោយលោក ពៅស៊ីផូ មានស៊ីនស៊ីសាមុត, នាងហួយមាស, នាងឈុនវណ្ណា, សុសម៉ាត់ ជាអ្នកច្រៀងនោះ ឮសូរគ្រលួចពិរោះចាប់ចិត្តដល់ភ្ញៀវក្រៃ លែង ។

ជុំវិញរោងជប់លៀង រំលេចទៅដោយអំពូលអគ្គិសនីតូចៗ និង អំពូលវែង ( Type Neon) ឆ្លាស់ពណ៌ចំរុះ ស, លឿង, ខៀវ, ក្រហម ។ គេរាល់គ្នាសប្បាយណាស់ ម្នាក់ៗផឹកស្រាតែបីបួនកែវ ខ្លះយកចង្កើះមកគោះដបធ្វើសង្វាងក់តាមភ្លេង ខ្លះស្រវឹងខ្លាំង ក៏ក្រោកពីកន្លែងអង្គុយ ទៅលោតឡកចាក់ក្បាច់កណ្ដាលវង់ ក្រោមស្នូរទះដៃពីពពួកភ្ញៀវឯទៀតៗ ឮសូរព្រោះ ! ព្រោះ ! មិនដាច់រយះ ។

នៅក្រោមដើមស្វាយប្របរបងខាងត្បូងផ្ទះ បុរសមួយរូបឈរអើតមើលនាយមើលអាយ ដូចជាចង់រកអ្នកណាម្នាក់ បុរសនេះគឺណាស៊ី ហ្នឹងឯង គេមកឈរក្រោមដើមស្វាយនេះយូរហើយ ដើម្បីចាំមើលកូនកម្លោះកូនក្រមុំចេញមកហុចបារីបំរើភ្ញៀវ ។

មួយសន្ទុះក្រោយមក គូស្វាមីភរិយាថ្មីក៏បណ្តើរគ្នាចុះពីលើផ្ទះមក កាន់កន្លែងភ្ញៀវ ដោយមានស្ត្រីក្មេង១កំដរកូនក្រមុំ ពីរបីនាក់ទៀតកាន់ពានបារីដើរតាមក្រោយ ។ សោភិនីស្អាតណាស់ នាងតែងខ្លួនក្នុងឈុតសម្លៀកបំពាក់រាត្រីពណ៌ស្វាយសក់បួងលាវរុំផ្កាម្លិះជាកម្រង ពួកភ្ញៀវលែងផឹកបែរមកមើលនាងស្រឡាំងកាំងគ្រប់គ្នា យី ! ស្អាតមែនវើយដូចទេពធីតាច្យុតមកពីឋានលើឥចឹង ភ្ញៀវម្នាក់និយាយឡើង ។

ណាស៊ី ខំសម្លឹងមើលអតីតសង្សារពីចម្ងាយ ទាំងដួងចិត្តក្រៀមស្រពោន ការសោកស្តាយអាឡោះអាល័យ ក៏កន្ត្រាក់អារម្មណ៍គេឱ្យនឹកឃើញម្តងទៀត គេឈរសម្លឹងគិតតែម្នាក់ឯងថា ឱ ... សោភិនីអើយ អូន និងប្តីអូនសមគ្នាណាស់ បុណ្យស័ក្តិគេក៏មាន ! ទ្រព្យសម្បត្តិគេក៏បរិបូណ៌ ... ផ្ទុយស្រឡះពីបង ដែលគ្រាន់តែជាកូនអ្នកក្រ មានដួងចិត្តស្មោះត្រង់ប៉ុណ្ណោះ សូមបំរើអូនទល់ថ្ងៃស្លាប់ សោភិនី ... ! អូននៅចាំសម្បថក្រោមដើមពោធិ៍ទេ ... អនុស្សាវរីយ៍ក្នុងបន្ទប់អណ្តូងព្រេងអង្គរធំ ក្រោមស្នូររន្ទះភ្លៀងផ្គរ ឥឡូវអូនភ្លេចហើយឬ ? មែន ! អូនគួរតែភ្លេច ព្រោះថ្ងៃនេះអូនបានគូថ្មីកៀកកើយ បងមិនខឹងអូនទេ ពីព្រោះបងក្រមិនអាចរកសុភមង្គលឱ្យអូនបានគ្រប់គ្រាន់ ទើបអូនបែរទៅរកគូថ្មី ... សូមថែរក្សាគ្នាឱ្យសុខចុះសោភិនី តែ ... អូនគួរអាសូរដល់កូនក្នុងផ្ទៃផង ពីថ្ងៃនេះទៅវាត្រូវបានឪថ្មីគេថែរក្សា គេថ្នាក់ថ្នម ចំណែកបងគ្មានវាសនានឹងទទួលខ្លួនធ្វើឪពុកទារកនេះទេ ។ ឱ ... វាសនាមនុស្សលោក ម្តេចក៏ឆាប់ប្រែប្រួលភ្លាម១ម្ល៉េះ ? នេះហើយអាពាហ៍ពិពាហ៍សង្សារខ្ញុំ ... !

ភ្ញៀវក្រោកដើរចេញពីតុត្រឡប់ទៅផ្ទះវិញខ្លះ១ ហើយសោភិនី និងប្តីរិនក៏ឡើងទៅលើផ្ទះផ្លាស់សម្លៀកបំពាក់ដែរ ។ បន្ទាប់មកកន្លែងជប់លៀងក៏អស់ភ្ញៀវរលីង នៅសល់តែក្មេងផ្ទះបួនប្រាំនាក់កំពុងសប្បាយ នឹងម្ហូបសល់លើតុនាំគ្នាស៊ីផឹកកំដរបរិយាកាសតទៅទៀត ។

ណាស៊ី ឈានជើងចេញពីផ្ទះលោកភិរុណ ដើរគ្លើស១ តាំងពីភូមិវត្តស្វាយរហូតដល់ផ្ទះ ។

រាត្រីនេះ ជារាត្រីសោកាបំផុតក្នុងជីវិតរបស់គេ ។ យុវជនកម្សត់ដេកបង្ហូរជលនេត្រ ដក់ដាមទៅដោយសេចក្តីព្រួយ និងក្តៅក្រហាយក្នុងដួងកមលដូចភ្លើងកល្បប្រល័យជីព ។

## ប្រឡងធ្លាក់តាំងចិត្តបួស

**ខូចចិត្តស្អិតទ្រូងក្រាំឱរា ដើរលេងផឹកស្រាឥតបើគិត**
**កិច្ចការរៀនសូត្រលែងប្រព្រឹត្ត លង់លើយគំនិតកាមតណ្ហា ។**
**លុះថ្ងៃប្រឡងក៏ធ្លាក់ទៀត ទ្រូងរែងចង្អៀតរិតខ្លោចផ្សា**
**តាំងចិត្តសាងផ្នួសបួសសាសនា ឱ ! អើយអនិច្ចាមិនសម្រេច ។**

រៀបការបានបួនថ្ងៃ លោកភូឈ្មួយខេត្តប៉ូរិនក៏នាំសោភិនីទៅនៅផ្ទះរបស់លោកឯខេត្ត ... ។ ណាស៊ីឥឡូវខុសពី ណាស៊ីមុនឆ្ងាយណាស់ ការរៀនសូត្ររបស់គេចេះតែឱនថយចុះមកជាលំដាប់ គេក្លាយខ្លួនទៅជាមនុស្សប្រព្រឹត្តអំពើអបាយមុខ ចេះជក់បារី, ផឹកស្រា, រាំរែក, ដើរលេងទើស១ភ្លឺជារៀងរាល់យប់ ។

ខ្ញុំនិងមីងមឿន ខំនិយាយលួងលោមដាស់តឿន រិះរកមធ្យោបាយគ្រប់បែប ដើម្បីទាញសតិអារម្មណ៍ឱ្យបែរមកចូលក្នុងការរៀនសូត្រ តែណាស៊ីគ្រវីក្បាលរាដៃ បែរជាមកគំហកកំហែងឱ្យខ្ញុំទៅវិញ។

-សំណាងឯងមិនចាំបាច់មកប្រដៅខ្ញុំទេ ... ! យើងអាយុក៏ស្របាលគ្នា ថ្នាក់រៀនក៏ប៉ុនគ្នា ខួរក្បាលចេះត្រិះរិះក៏ប្រហែល១គ្នា ដូច្នេះមិនចាំបាច់មកទូន្មានខ្ញុំទេ ! ខ្ញុំសូមអរគុណជាពន្លឹកដែលសំណាងឯងចេះជួយឈឺឆ្អាលនឹងខ្ញុំ ។

ណាស៊ីនិយាយធ្វើព្រងើយ រួចគេក៏លើកកែវស្រាផឹកតទៅទៀត ខណៈពេលដែលខ្ញុំបានទៅជួបគេក្នុងបារ ។ ខ្ញុំអត់ខឹងនឹងពាក្យអសុរសរបស់ណាស៊ីទេ ផ្ទុយទៅវិញ ខ្ញុំកាន់តែអាណិតគេខ្លាំងណាស់ទៅទៀត ព្រោះខ្ញុំយល់ច្បាស់ហើយថា ណាស៊ីកំពុងខូចចិត្តរឿងវិបត្តិស្នេហា ។

-ណាស៊ី (ខ្ញុំហៅឈ្មោះគេព្រមទាំងលើកដៃទះស្មាតិច១) ខ្ញុំមិនមែនចង់អួតអាងថា ខ្ញុំចេះដឹងជាងណាស៊ីឯងទេ តែថា ... ពេលវេលាប្រឡងរបស់យើងនៅសល់តែបីខែទៀតប៉ុណ្ណោះ បើមិត្តរវល់តែខូចចិត្ត ដើរលេងរាំរែកផឹកស្រាទើស១ភ្លឺដូច្នេះ សុខភាពរបស់មិត្តនឹងត្រូវទ្រុឌទ្រោម ជួនកាលក៏អាចបណ្ដាលឱ្យទៅជាធ្លាក់ខ្លួនឈឺធ្ងន់ក៏សឹងថាបាន អ្នកមីងនៅផ្ទះឯណោះគាត់អង្គុយយំចាំមើលផ្លូវមិត្តរាល់យប់ ... គាត់ព្រួយចិត្តណាស់ដោយឃើញកូនលះបង់ការសិក្សាដែលជាពន្លកសង្ឃឹមរបស់គាត់តែមួយក្នុងជីវិត ។

ណាស៊ីដូចជាស្ដាប់ពាក្យខ្ញុំបានមួយខណៈ កែវស្រាដែរហៀបនឹងលើកក្រេបទៅក្នុងមាត់ ក៏កាន់ទ្រឹងឈប់ស្ងៀម ។ ដោយសារពន្លឺភ្លើងអំពូលពណ៌ចាំងភ្លឹបភ្លែត១ ខ្ញុំមើលឃើញណាស៊ីធ្វើមុខក្រៀម ហើយមាន ទឹកថ្លា១ហូរ

ចេញពីរង្វង់ភ្នែកគេ ។ ខ្ញុំដឹងថាណាស៊ីយំ ប្រហែលជាគេភ្ញាក់ខ្លួនឡើងវិញហើយ មើលទៅ ខ្ញុំក៏និយាយដាស់តឿនគេថែមទៀត :

-ស្ត្រីក្នុងលោកមិនមែនមានតែសោភិនីមួយឯណា ចំពោះស្ត្រីរូបល្អ ចិត្តក្បត់ដូច្នេះ តើមិត្តនៅអាឡោះអាល័យធ្វើអ្វី ? បើគេស្រឡាញ់យើង គេមិនមែនទៅរៀបការជាមួយប្រុសដទៃទេ ... ខំរៀនទៅមិត្ត យើងជាយុវជនត្រូវមានចិត្តក្លាហាន អនាគតយើងជាសសរទ្រទ្រង់នៃប្រទេសជាតិ យើងខូចចិត្តព្រោះរឿងស្នេហាវាអាម៉ាស់មុខណាស់ កុំឱ្យយុវជនជាន់ក្រោយគេយកតម្រាប់តាម ! កុំឱ្យស្លាប់ទៅមានឈ្មោះថាយើងជាអ្នកនាំឱ្យយុវជនទាំងប្រទេសត្រូវខូចកិត្តិយសដោយសារតែរូបយើងម្នាក់ ... !

ណាស៊ីដាក់កែវស្រាចុះ បែរមើលមុខខ្ញុំដោយខ្សែភ្នែកទ្រង់អង្វរ សារភាពទទួលខុស គេទាញកូនកន្សែងពីក្នុងហោប៉ៅមកជូតទឹកភ្នែក ហើយនិយាយសំឡេងអួល១រកខ្ញុំ :

-ខ្ញុំខុសហួសហើយសំណាង ... ! ខ្ញុំជាមនុស្សចាញ់ធម្មជាតិ ! ជាយុវជនកម្សាក ... យុវជនទូទៅគួរកុំយកតម្រាប់តាមខ្ញុំ ... គួរស្អប់ខ្ពើមខ្ញុំឱ្យច្រើនជាទីបំផុត ពីព្រោះចិត្តខ្ញុំជាកញ្ចះនៃសេចក្តីស្នេហា ខ្ញុំធ្វើឱ្យម្តាយត្រូវកើតទុក្ខរីងរៃ ស្គាល់តែទឹកភ្នែកគ្រប់ពេលវេលា ...

ណាស៊ីទាញដៃខ្ញុំយកទៅច្របាច់យ៉ាងណែន ចក្ខុគេទាំងទ្វេដិតដាមទៅដោយទឹកភ្នែក គេសម្លឹងមើលមុខខ្ញុំ ហាក់ដូចជាចង់រកការពិតអ្វីម៉្យាងបន្តិចមកគេក៏និយាយឡើង :

-សំណាងមិត្តល្អនឹងខ្ញុំណាស់ ... ! ក្នុងចំណោមមិត្តភក្តិទាំងអស់ មានតែសំណាងឯងទេចិត្តស្មោះត្រង់នឹងខ្ញុំ ... ស្រឡាញ់ខ្ញុំ ... ! ហើយចេះជួយប្រលោមលួងលោមចិត្តខ្ញុំក្នុងគ្រាកំពុងមានទុក្ខ ។ ចាប់ពីព្រឹកស្អែកទៅខ្ញុំត្រូវតែខំរៀនតាមមិត្តហើយ សោភិនី ... នាងមានប្តីថ្មី ខ្ញុំមិនជាសោកស្តាយ ឬអាឡោះអាល័យអ្វីទេ តែ ... ខ្ញុំនឹកតូចចិត្ត ! ស្មានមិនត្រូវ នូវជម្រៅចិត្តស្រី ដែលប៉ុនភូតភរបោកប្រាស់ឱ្យខ្ញុំលង់ទៅក្នុងភពថ្មីមួយ គឺពិភពស្នេហា ឱ ! ... ពាក្យសម្បថរបស់ស្ត្រី តើវាមានន័យអ្វីខ្លះសម្រាប់បុរស ? គ្មានទាល់តែសោះ ! ពាក្យសម្បថរបស់ស្ត្រីក៏គឺការបោកប្រាស់ ប្រុស១មួយគ្រាប៉ុណ្ណោះឯង រួចហើយនាងក៏បំភ្លេចវាទៅវិញអស់រលីង ... ទឹកហូរមិនចេះហត់ប្រុសស្បថកុំឱ្យជឿ ខ្ញុំមិនចង់ឱ្យគេនិយាយពាក្យនេះទៀតទេ សំណាង ខ្ញុំចង់លុបពាក្យបូរាណកាលចាស់គំរិលនេះចោលហើយដាក់ពាក្យថ្មីជំនួសវិញថា ទឹកហូរមិនចេះហត់ ពាក្យស្រីស្បថ គឺក្បត់ប្រុសហើយ !

-ណាស៊ីនិយាយចប់ ក៏ឱនមុខយកដៃគងថ្ងាសជ្រប់លើតុ ពិសពុលនៃសុរាកំពុងបញ្ចេញថាមពលពាសពេញខ្លួនគេ ។ ខ្ញុំដឹងថាណាស៊ីស្រវឹងស្រាខ្លាំង ខ្ញុំក៏ចេញទៅក្រៅហៅរ៉ឺម៉កហើយជួយគ្រាហ៍ជូនត្រឡប់ទៅផ្ទះវិញ ។

បីខែក្រោយមកទៀត ការប្រឡងមធ្យមសិក្សប័ត្រក៏មកដល់ ។

សិស្សគ្រប់រូបប្រុងប្រៀបរៀបចំខ្លួនធ្វើដំណើរមកភ្នំពេញមុនថ្ងៃប្រឡងចំនួនមួយអាទិត្យ ។ ខ្ញុំ និងណាស៊ី ក៏បានធ្វើដំណើរមកជាមួយនឹងគេឯងដែរ ។

មកដល់ភ្នំពេញ ខ្ញុំ និងណាស៊ីបបួលគ្នាទៅសំណាក់នៅផ្ទះវង្សរិទ្ធិឯង ។ ព្រឹកថ្ងៃមួយក្រោយដែលវង្សរិទ្ធិឯងទៅធ្វើការបាត់ទៅ ខ្ញុំ និង ណាស៊ី នឹកអផ្សុក យើងទាំងពីរនាក់នាំគ្នាដើរលេងផ្សារ ដើម្បីឱ្យបានលំហែកាយ និងប្រយោជន៍រកទិញប្រដាប់ប្រដាសិក្សាខ្លះៗ ។

ណាស៊ី គេសប្បាយចិត្តណាស់ គេឆ្លងកាត់ពីវិថីមួយទៅវិថីមួយ ភ្នែករំពៃគយគន់មើលទេសភាពទីក្រុង ដែលរីកចម្រើនយ៉ាងឆាប់រហ័ស ។ គេនឹកកោតសរសើរដល់ថ្វីដៃរាជការក្រុងក្នុងសម័យសង្គមរាស្ត្រនិយម ដែលប៉ិនប្រសប់រៀបចំលំអទីក្រុងភ្នំពេញ ឱ្យក្លាយទៅជាឋានសួគ៌មួយសម្រាប់ប្រជាជនខ្មែរ និងជាទីត្រេកត្រអាលនៃជនទេសចរគ្រប់សញ្ជាតិ ។

ណាស៊ី ដើរបណ្តែតអារម្មណ៍ដល់កាច់ជ្រុងរោងភាពយន្តកាពីតូល ពេលនោះស្រាប់តែគេទុចដំណើរ ហើយភ្ញាក់ព្រើតបូរិន និងសោភិនីដែលគេខំបំភ្លេច នឹងមិននឹកស្មានថាបានជួបទៀត ក៏ស្រាប់តែឃើញអ្នកទាំងពីរដើរចេញពីភោជនីយដ្ឋាន ថៃសានមក ។

ណាស៊ី ចាប់ដៃខ្ញុំជាប់ដើរទៅមុខលែងរួច គេបែមុខងាកចេញទៅម្ខាង ដើម្បីកុំឱ្យសោភិនី និងបូរិនឃើញ តែបូរិន និងសោភិនី បានឃើញមុននេះទៅហើយ ។ យុវស្វាមីភរិយាដើរកាន់ដៃគ្នាសម្លឹងមើលទៅណាស៊ីដែលឈរទ្រឹងនៅមួយកន្លែង ហើយសោភិនីក៏សើចពេមជ្រាយសម្លឹតសម្លក់ទ្រង់ចំអកឱ្យ ។

បូរិន និងសោភិនី ឡើងរថយន្តបើកចេញទៅហើយ ណាស៊ីលែងមានសេចក្តីសុខ មុខដែលស្រស់ញញឹមប្រិមប្រិយអម្បាញ់មិញ ប្រែជាក្រៀមស្រពោន ភ្នក់ភ្លើងស្នេហ៍ដែលរលត់បាត់ និងសម្រែកអតីតកាលដ៏ឈឺចាប់ ! ក៏ឆាបឆេះពុះកញ្ច្រោលក្នុងអារម្មណ៍គេម្តងទៀត :

-មានរឿងអីកើតឡើងអូននី ? ហើយអាគាត់នេះវាជាអ្នកណា?

-ខ្ញុំមិនដែលស្គាល់ទេបង មិនដឹងមកពីណាផង ។ ស្រាប់តែមកឡូឡាដាក់ខ្ញុំ !

-យីអាក្របីព្រៃ ! ឯងមកពីណាក៏ហ៊ានសម្តីខែងម្ល៉េះនេះជា ប្រពន្ធរបស់អញណា បើឯងចង់និយាយសម្តីរបៀបនេះ ត្រូវឯងទៅរកកន្លែងនិយាយជាមួយស្រីផ្សេងទៀតទៅ ឬមួយក៏អាឯងឆ្កួត ? បើថា វាឆ្កួតអញនឹងដាក់ឡានបញ្ជូនទៅព្រៃកន្ទោត ... ឆ្លើយ !

ឈឺចាប់ណាស់ ! ណាស៊ីយកដៃអង្អែលថ្ពាមស្ទាបឆ្អឹងជំនី សម្តីទ្រគោះបោះបោក កាយវិការព្រៃផ្សៃរបស់លោកភូឈួយខេត្តប៉ូរិន រំលោភលើរាងកាយគេពីថ្ងៃមុនរៀបការសោភិនី ហាក់ដូចជានៅថ្មីៗ ។ មុខលែងស្រស់ ! ដើរលេងលែងសប្បាយ ទីបំផុតណាស៊ីក៏បបួលខ្ញុំត្រឡប់មកផ្ទះវិញ ។

ការប្រឡងប្រជែង យកមធ្យមសិក្សាប័ត្រ បានប្រព្រឹត្តទៅយ៉ាងក្រៀមក្រំសម្រាប់រូបណាស៊ី ។

ក្រោយពីដឹងដំណឹងប្រឡងជាប់ធ្លាក់ហើយ យើងទាំងពីរនាក់ក៏ធ្វើដំណើរត្រឡប់ទៅសៀមរាបវិញ ។ មីងមឿននៅផ្ទះឯណោះ គាត់ខំដុតចូលបន់ស្រន់ សែនមាន់សែនទាដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយ ឱ្យជួយឃុំគ្រង ថែរក្សា ណាស៊ីសូមឱ្យបានប្រឡងជាប់ដូចសេចក្តីប្រាថ្នា ។

នៅពេលដែលណាស៊ីឡើងទៅដល់លើផ្ទះ មីងមឿនស្ទុះត្រហេបត្រហបចេញពីផ្ទះបាយមកទទួលកូន ជាបឋមគាត់ក៏សួរទៅណាស៊ីទាំងភ័យអរថា :

-ម៉េចទៅណាស៊ី ! កូនប្រឡប់ជាប់ទេ ... !

ណាស៊ី មិនឆ្លើយតបនឹងសំណួរម្តាយ គេគ្រាន់តែគ្រវីក្បាល ដោយទឹកមុខក្រៀមក្រោះ រួចហើយក៏បោះវ៉ាលិសដាក់ខោអាវទៅលើគ្រែ មីងមឿនកាត់យល់ភ្លាម ថាកូនគាត់ច្បាស់ជាប្រឡងធ្លាក់ ។

-ណាស៊ីកូនប្រឡងធ្លាក់ឬ ?

-បាទម៉ែ ... (ណាស៊ីឆ្លើយព្រមជាមួយគ្នាទឹកភ្នែកក៏ហូរហៀរមក) ខ្ញុំប្រឡងធ្លាក់ ... ។

ដូចកាំរន្ទះទាំងប្រាំពីរបាញ់ចំកណ្តាលដើមទ្រូង ។ មីងមឿនរសេះរសោះដៃជើង, ត្រចៀកឡើងហ៊ឹង, ភ្នែកស្រវាំងបែកអំពិលអំពែក, សេចក្តីសង្ឃឹមរបស់គាត់បានត្រូវរលាយអស់ហើយ ។ អ្នកមីងមេម៉ាយ យំហ៊ូចេញមកដូចកូនក្មេង គាត់ស្ទុះទៅឱបកូនសម្លាញ់ យកមុខទៅនទាក់នទាលលើស្មាទួញង៉ក់ ! ង៉ក់ ! យ៉ាងគួរឱ្យវេទនាភ្នែក ។ ណាស៊ីកូនគាត់ ប្រឡងធ្លាក់ គាត់យល់ច្បាស់ណាស់ ថាគ្មានអ្វីក្រៅពីរឿងស្នេហាចាស់នោះទេ ។

-ណាស៊ីកូន ... ! សេចក្តីសង្ឃឹមរបស់យើងបានត្រូវផុតតែត្រឹមណេះហើយ ... ពីថ្ងៃនេះទៅ កូនត្រូវបំភ្លេចរឿងចាស់ចោលចេញ កូនត្រូវខំរៀន

សូត្រឱ្យអស់ពីដួងចិត្ត ម្ដាយសង្ឃឹមថាកូននឹងប្រឡងជាប់នៅឆ្នាំក្រោយជាពុំខាន ... ។

-ជាតិនេះហួសហើយ ការរៀនសូត្រសម្រាប់ខ្ញុំម៉ែ ... ខ្ញុំធ្វើឱ្យម៉ែពិបាកចិត្តគ្រប់ពេលវេលា ខ្ញុំជាកូនអកតញ្ញូ ! ឱ្យខ្ញុំរៀនតទៅទៀតម្ដេចនឹងកើតម៉ែ ... ខ្ញុំខ្មាសគេណាស់ ពីថ្ងៃនេះទៅខ្ញុំសូមលាម៉ែទៅជ្រកក្រោមសំពត់កាសាវពស្ត្រហើយ មានតែម្លប់សាសនាទេ អាចរម្ងាប់ដួងចិត្តខ្ញុំឱ្យស្ថិតនៅក្នុងសភាពស្ងប់ស្ងាត់ លែងរវីរវៃវាយ កាត់ដាច់ពីកាមកិលេសទាំង ពួង សូមម៉ែអនុញ្ញាតបំពេញនូវគោលបំណងរបស់ខ្ញុំម្ដងទៀតចុះ ខ្ញុំតាំងចិត្តរួចជាស្រេច ថានឹងចូលបួសរហូតអស់មួយជីវិត ។

មីងមឿន ស្ដាប់វាចាកូនសម្លាញ់ គាត់រិតតែក្ដុកក្ដួលអួលណែនដូចគេយកដុំដែកកំពុងក្ដៅ មកចាក់រោលដើមទ្រូងគាត់ឱ្យក្ដៅផ្សាយ៉ាងសែនសាហ័ស ។ ត្រួយពន្លកសង្ឃឹមជាក្ដើមតិកសំណល់ពីខ្មោចប្ដីចែកទុកឱ្យគាត់ ក៏មានតែរូបណាស៊ីនេះឯង ចុះបើណាស៊ីបួសទៅទៀត តើឱ្យគាត់សង្ឃឹមទៅលើអ្នកណា ។

-ណាស៊ីកូនមាសម្ដាយ ... ! ខ្មោចព្រាយបិសាចអ្វីមកចូលសណ្ឋិតក្នុងខ្លួនកូន បានជាកូនប្រែចិត្តវិបល្លាសយ៉ាងដូច្នេះ ! ... ម្ដាយសព្វថ្ងៃរស់នៅបានដោយសារតែសង្ឃឹមលើកូនមួយទេ ចុះបើកូនរត់ចោលម៉ែទៅបួសទៀត តើឱ្យម្ដាយរស់នៅជាមួយអ្នកណា ... !

និយាយរួច មីងមឿនក៏តាំងអង្គុយយំហ៊ូ ! ហ៊ូ ! នឹកតូចចិត្តនឹងវាសនារបស់គាត់ ។

-ឈប់យំទៅម៉ែ ... ជាតិនេះសេចក្ដីសង្ឃឹមរបស់ខ្ញុំទាំងប៉ុន្មានវារលាយអស់ទៅហើយ ចូរម៉ែឈប់យំសោកហើយគិតថា ណាស៊ីកូនរបស់ម៉ែ វាបានស្លាប់បាត់ពីលោកនេះទៅហើយ ... តែម៉ែនឹងមានកូនមួយទៀតប្រកបទៅដោយគុណសម្បត្តិ និងវិជ្ជាសម្បត្តិ គឺសំណាងមិត្តរបស់ខ្ញុំ សំណាងគេប្រឡងជាប់ គេជាកូនកំព្រាគ្មានម្ដាយឪពុកឯណាទេ សព្វថ្ងៃគេយកអារាមធ្វើជាទីជម្រក ខ្ញុំបាននិយាយរឿងរ៉ាវប្រាប់គេអស់ហើយ គេថានឹងមកសុំម៉ែធ្វើជាម៉ែរបស់គេ ហើយនឹងមកនៅថែរក្សាម៉ែកាលបើអត់ពីខ្ញុំទៅ ... ។

-ណាស៊ីកូន តើមានម្ដាយក្នុងលោកណាអាចស្រឡាញ់កូនគេអ្នកក្រៅផ្ទឹមស្មើនឹងកូនរបស់ខ្លួនទេ ? ទោះបីអាក្រក់ល្អ គ , ខ្វាក់ ,ខ្វិន ,ថ្លង់, ឆ្កួតលីលាក៏ជាកូនចេញពីឧទររបស់ម្ដាយដែរ ... ម្ដាយសូមអង្វរចិត្តកូន សូមកូមកុំទៅបួសចោលម្ដាយអី ... ។

-កុំឃាត់ខ្ញុំម៉ែ បើម៉ែមិនឱ្យខ្ញុំទៅបួសទេ ខ្ញុំប្រាកដជាប្រេះទ្រូងស្លាប់ចោលម៉ែនៅពេលឆាប់ៗនេះជាពុំខាន ... ។

-និយាយហើយ ណាស៊ីក៏ដើរទៅប្រាសខ្លួនដេកលើគ្រែសន្ធឹងសន្ធៃ ទាំងសម្បៀកបំពាក់ ។ មីងមឿនឆ្អែកចិត្ត ទាល់ប្រាជ្ញាមិនដឹងជារកកលវិធីណា នឹងពន្យល់កូនឱ្យបោះបង់គំនិតនេះចោលចេញ ។

មួយខែកន្លងមកទៀត ដោយការសម្រេចចិត្តដ៏មុតមាំរបស់ ណាស៊ី មីងមឿនក៏យល់ព្រមឱ្យបួស ។ អ្នកមីងមេម៉ាយបានទិញសំពត់ ស្បង់ ត្រៃចិវរ និងប្រដាប់ប្រដាសម្រាប់សមណសង្ឃទៀតជាច្រើន ។ គាត់តាំងចិត្តនឹងធ្វើពិធីបំបួសខ្វាន់នាគណាស៊ី ឱ្យអធឹកអធម្មជាឧឡារិក ឱ្យសមនឹងកូនគាត់មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ ដូច្នេះហើយ ព្រឹកថ្ងៃស្អែកឡើងគេឃើញមានលោកអាចារ្យ និងភ្ញៀវចាស់ទុំជិតខាងជាច្រើន ចូលមកជួយរួបរួមក្នុងពិធីបំបួសខ្វាន់នាគនៅផ្ទះមីងមឿនយ៉ាងកុះករ ។

កូននាគ ពោលគឺណាស៊ី អង្គុយឱ្យលោកអាចារ្យកោរសក់កោររោមចិញ្ចើម ដោយទឹកមុខញញឹមស្ងួត ។ បន្ទាប់ពីកោររួចហើយ គេក៏ឱ្យកូននាគទៅងូតទឹកជំរះរាងកាយឱ្យស្អាតបាត ។ តាមប្រពៃណីខ្មែរយើង មុននឹងបំបួសកូនចៅឱ្យទៅជាព្រះភិក្ខុសាមណេរ គេត្រូវឱ្យកូននាគដើរទៅសុំខមាទោសពីបងប្អូនញាតិសន្តានជិតឆ្ងាយ ចំពោះអំពើខ្លួនដែលបានប្រព្រឹត្តខុសពីថ្ងៃមុន ដោយចេតនាក្តីអចេតនាក្តី សូមឱ្យរួចរាល់គ្នាតែត្រឹមណោះ ។

ម៉ោងបីរសៀល ពិធីដង្ហែខ្វាន់នាគទៅកាន់វត្តព្រះព្រហ្មរតន៏ក៏ចាប់ផ្តើមធ្វើឡើង គេឱ្យកូននាគឡើងជិះសេះ ដោយមានចាស់ៗពីរនាក់ ជាអ្នកនាំមុខពាជី ។ ខណៈដែលក្បួនដង្ហែរៀបនឹងចេញដំណើរទៅហើយ ព្រឹត្តិការណ៍ចម្លែកដែលគ្មានអ្នកណា នឹកស្មានថានឹងកើតមានឡើង ក៏ស្រាប់តែ ...

អូយ ! ខ្ញុំវិលមុខណាស់ម៉ែ ... !

ថាបានប៉ុណ្ណោះ ណាស៊ី ឬ កូននាគក៏រមៀលធ្លាក់ពីលើខ្នងពាជីសន្លប់បាត់ស្មារតីមួយរំពេច ។ ការចលាចលផ្អើលឆោឡោក៏មានឡើង មីងមឿនស្រែកភ្ញាត់សំឡេងតក់ស្លុតនឹងកូន :

-លោកអើយ ! កូនខ្ញុំយ៉ាងម៉េចទៅហើយ ជួយមើលខ្ញុំផង !

ខ្ញុំ និងចាស់ៗបីបួននាក់ នាំគ្នាគ្រាហ៍ណាស៊ីឡើងទៅលើផ្ទះជាបន្ទាន់ ដោយយល់ថាណាស៊ីខ្យល់គ ខ្លះក៏ខាំកែងជើង ខ្លះកោសរូតខ្នង ខ្លះរត់ទៅអញ្ជើញពេទ្យហ្មឱ្យមកព្យាបាលច្រវាត់ច្រវែង ។

មួយសន្ទុះធំមក ណាស៊ីក៏ដឹងខ្លួនតិចៗឡើងវិញ ហើយចេះតែស្រែកទាររកទឹក ។ ពិធីបំបួសខ្វាន់នាគក៏ត្រូវឈប់ផ្អាកត្រឹមណោះសិន ទំរាំ ថ្ងៃណា ណាស៊ីបានស្រួលបួលនឹងគិតផ្តើមធ្វើតទៅទៀត ។

# ជំងឺរ៉ាំរ៉ៃ

កូតឈាមក្រៀមស្ងួតក្ស័យជីវា ព្រោះតូសង្សារចិត្តមិនត្រង់
បានថ្មីក្រឡះចាស់បោះបង់ នេះកែវទួនល្អងឃើញបងក្រ ។
មិនថ្វីទេអូនរូបបងស្លាប់ ជាតិក្រោយសុំចាប់ភពបវរ
ស្វាលាចិត្តខ្មៅមាត់លាបស្ករ ខ្លាចហើយស្រីល្អសតែសាច់ ។

តាំងពីថ្ងៃណាស៊ីធ្លាក់ពីលើខ្នងសេះមក គេក៏ទៅជាមានជំងឺមួយប្រចាំកាយ គឺជំងឺរ៉ាំរ៉ៃ ។ មីងមឿនភ័យខ្លាចកូនស្លាប់ណាស់ គាត់បានទៅអញ្ជើញគ្រូពេទ្យ និងគ្រូខ្មែរ ដែលធ្លាប់ល្បីឈ្មោះក្នុងការមើលជំងឺមកព្យាបាលឱ្យកូនគាត់ជារៀងរាល់ថ្ងៃ ។ តែ ... ទោះជាគ្រូហ្មទាំងនោះខំពិនិត្យរោគ ព្យាបាលជំងឺដោយអស់សមត្ថភាពខ្លួនក៏ដោយ ក៏ជំងឺរបស់ណាស៊ី មិនបានជា ឬធូរស្រាលសូម្បីបន្តិចបន្តួចឡើយ កាន់តែយូរថ្ងៃ ក៏កាន់តែធ្ងន់ឡើងជាលំដាប់ដែរ ។

ឃើញទេវង្សរិទ្ធិ គ្រោះកំណាចនៃព្រហ្មលិខិតដាក់ទុក្ខទោសលើគ្រួសារមីងមឿនគ្រប់ពេលវេលា ប្ដីស្លាប់, ធ្លាក់ខ្លួនក្រ, កូនប្រឡងមិនជាប់,ហើយឥឡូវមកទទួលមានជំងឺទៀត ។ ជីវិតសត្វលោកដែលកើតមានរូបរាងឡើងនៅលើវាលវដ្ដសង្សារ សុទ្ធតែជារបស់អនត្តាទាំងអស់ ។ រកកំណត់ រកជឿឱ្យទៀងទាត់មិនបានឡើយ ... កើត, រស់, ស្លាប់, ទុក្ខ, សប្បាយ, គឺជាសំណែននៃព្រះព្រហ្មលិខិតតែម្យ៉ាង ។

មួយខែបានកន្លងផុតទៅ ជំងឺណាស៊ីក៏កាន់តែដុនដាបប្រៀបដូចទូកធ្លាយទឹកចូល ចេះតែស្រិម១ទៅរង់ចាំតែពេលវេលានឹងលិចបាត់កប់ទៅក្នុងបាតទន្លេ ។ ប្រាក់ក៏អស់ ស្រែពីរបីលក់បញ្ចាំគ្មានសល់ កូននៅតែឈឺដដែល មីងមឿនអស់បើគិត យំលែងចេញ ទឹកភ្នែករីងខះ គាត់បែរជាសើច ហើយជួនកាលក៏ស្រាប់តែក្រោកឈរច្រៀងផ្ដេលផ្ដាសដូចវិកលចរិត នេះហើយទឹកចិត្តមាតាស្នេហារវាងបុត្រ ។

ល្ងាចថ្ងៃមួយ ពូឈីនញាតិជិតខាងផ្ទះ ដែលមកកំដរជំងឺដែរ ហៅខ្ញុំទៅពិគ្រោះជាមួយគាត់ស្ងាត់១ កំបាំងពីភ្នែកគេឯង តែពីរនាក់ថា :

-ក្មួយសំណាង ... ! ជំងឺក្មួយណាស៊ីនេះពូគ្មានសង្ឃឹមថានឹងជាទេ មនុស្សកើតទុក្ខក្រៀមក្រំឈាមកកក្នុងទ្រូង ពេលក្អួតធ្លាក់ឈាមទាំងដុំ១ ក្នុង

ដប់ភាគសង្ឃឹមរស់តែពីរភាគប៉ុណ្ណោះ បើតាមយោបល់ពូ ថាយើងគួរតែជួល ឡានតូចដឹកក្មួយណាស៊ី ទៅព្យាបាលខ្លួននៅពេទ្យមិត្តភាពខ្មែរសូវៀតឯភ្នំពេញ ប្រហែលជាមានសង្ឃឹមរស់ខ្លះ ។

ខ្ញុំអង្គុយគិតបន្តិចមក ក៏ឆ្លើយទៅវិញ :

-មែនហើយពូ បើយើងនៅតែបណ្ដែតបណ្ដោយតទៅទៀតមិនកើត ទេ ថ្ងៃនេះគ្រាន់តែក្អួតឈាមបីបួនដង តែថាមុននឹងយើងដឹកទៅ ត្រូវទៅសួរ ណាស៊ីសិន តើគ្នាអាចមានកម្លាំងទៅបានទេ ពីព្រោះស្គមសល់តែស្បែកដណ្ដប់ ឆ្អឹងតចឹង ដឹកឡានទៅផ្លូវឆ្ងាយវាមានគ្រោះថ្នាក់ច្រើន ណាស់ ។

ក្រោយពីអង្គុយគិតយ៉ាងយូរមូលមតិគ្នា ខ្ញុំនិងពូឈឺនក៏មកកន្លែងគ្រែ ណាស៊ីដេកឈឺ ហើយខ្ញុំបានសួរទៅគេដោយសំឡេងតិចៗ :

-ណាស៊ី ... ខ្ញុំគិតគ្នារួចទៅហើយថា នឹងជូនឡានតូចដឹកមិត្តទៅព្យា បាលខ្លួនឯភ្នំពេញ តើក្នុងខ្លួនមិត្តមានកម្លាំងអាចធន់ទៅរួចទេ ...

ណាស៊ីចាប់ដៃខ្ញុំជាប់ គេគ្រវីក្បាលមួយៗដោយបន្លឺវាចាខ្សាវៗថា :

-អត់អំពើទេសំណាង ... កុំដឹកខ្ញុំយកទៅណាទៀត ... បណ្ដោយឱ្យ ខ្ញុំស្លាប់ក្រោមដំបូលផ្ទះនេះចុះ បើមិត្តដឹកខ្ញុំទៅមុខជាស្លាប់តាមផ្លូវមិន ខាន ខ្ញុំ មិន ...

ណាស៊ីចង់និយាយតទៅទៀត តែគេហត់ណាស់ ដកដង្ហើមលាន់ឃូ ! ឃូ ! ហើយក៏ក្អួតចេញឈាម ខ្ញុំបែរយកកន្ថោរមិនទាន់ ក៏យកដៃទាំងពីរទៅ ត្រង ។ លោហិតស្រស់ៗ ធ្លាក់ពេញដៃខ្ញុំ ហើយខ្ទាតមក ប្រឡាក់អាវក្រហម ច្រាល ។

កាលបើណាស៊ីបាត់ហត់ លែងក្អួត គេក៏ខំប្រឹងបែរមុខមកនិយាយជា មួយខ្ញុំម្ដងទៀត :

សំណាង ... ! ដៃមិត្តប្រឡាក់អស់ហើយ អាវក៏ប្រឡាក់សុទ្ធតែឈាម ទៅរកទឹកលាងទៅ ...

-មិនអីទេណាស៊ី ចាំបន្តិចខ្ញុំទៅលាងក៏បានដែរ ឥឡូវមិត្តញ៉ាំបបរ បន្តិចទៅណា ខ្ញុំនឹងទៅដួសមកបញ្ចុក ...

ណាស៊ីប្រញាប់រាដៃមកខ្ញុំវិញ :

-កុំអីសំណាង ... ខ្ញុំនៅមិនទាន់ឃ្លានទេ ម៉ែខ្ញុំគាត់ទៅណាហើយ ... ម៉េចមិនឃើញ ...

-អ្នកមីងគាត់អញ្ជើញទៅរកគ្រូព្យាបាលមិត្តណា ... បន្តិចទៀតគាត់ នឹងមកវិញហើយ ។

-ទៅរកគ្រូមកមើលខ្ញុំ ? ហ៊ឺ ... ! អត់ប្រយោជន៍ទេ ខ្ញុំដឹងខ្លួនឯងច្បាស់ ... ថាខ្ញុំប្រាកដជាស្លាប់ ! បើអត់ពីខ្ញុំទៅ ចូរសំណាងឯងមកនៅផ្ទះខ្ញុំ ធ្វើជាកូនគាត់ ហើយជួយថែរក្សាគាត់ផង ...

ឮសម្ដីដ៏សែនអាណោចអាធម្មរបស់ណាស៊ី ធ្វើឱ្យខ្ញុំរកទប់ទឹកភ្នែកមិនបាន តែខ្ញុំខំនិយាយលួងលោមគេទៅវិញ :

-ជំងឺរបស់មិត្តមិនដល់ស្លាប់ទេ ចូរមិត្តតាំងចិត្តឱ្យក្លាហានឡើង បីបួនថ្ងៃទៀតមិត្តមុខជាជាមិនខាន ។

ណាស៊ី ប្រឹងសើចទាំងបបូរមាត់ស្ងួតក្រៀម :

-កុំបាច់មកនិយាយលើកទឹកចិត្តខ្ញុំសំណាង ខ្ញុំដឹងខ្លួនឯងអស់ទៅហើយ ...

ណាស៊ីនិយាយរួច ក៏ឈប់ស្ងៀមដោយហត់ខ្លាំងពេក បន្ទាប់មកភ្នែកគេបិទជិត ហើយក៏សម្ងំលក់ទៅ ។

មួយខែ ... ពីរខែ ... បីខែ ... ជំងឺណាស៊ីកាន់តែដុនដាបខ្លាំងឡើងៗ សេចក្ដីសង្ឃឹមរបស់ញាតិជិតខាង និងមីងមឿន, ខ្ញុំថា ណាស៊ីនឹងបានជាក៏ត្រូវរលាយអស់រលីង យើងរាល់គ្នាដឹងជាក់ក្នុងចិត្តថា ណាស៊ីមុខជានឹងលាចាកយើងរាល់គ្នាទៅកាន់បរលោកនាយនៅពេលឆាប់ៗខាងមុខនេះជាពិតប្រាកដ ។

ថ្ងៃនេះ អាការរោគរបស់ណាស៊ី មានសភាពធ្ងន់ធ្ងរប្លែកជាងសព្វដងហត់កាន់តែខ្លាំង ភ្នែកឡើងខៀវល្អក់ហើយចេះតែរវើរវាយស្រែកហៅរកឈ្មោះ សោភិនីមិនដាច់ពីមាត់ :

-សោភិនី ... ! សោភិនី ... ! អូននៅឯណា សោភិនីបងដាច់ខ្យល់ស្លាប់ឥឡូវហើយ អូនចូលមកជិតបងបន្តិចមក ... សោភិនី ...

មីងមឿន អាណិតកូន គាត់ស្រែកទ្រហោយំខ្លែងៗពេញផ្ទះ ញាតិជិតខាងឃើញដូច្នោះក៏នាំគ្នាទៅនៅផ្ទះពូឈីន ដើម្បីកុំឱ្យសំឡេងយំសោកនេះ ឮទៅដល់ត្រចៀកអ្នកជំងឺ ។ ពេលនោះណាស៊ីកាន់តែដង្ហក់ ស្លឈាមខ្លាំងឡើង ខ្ញុំប្រញាប់ស្ទុះទៅត្រកងខ្លួនណាស៊ីដាក់លើភ្លៅខ្ញុំ អ្នកជំងឺដឹងខ្លួនក៏ស្រែករកសោភិនីទៀត :

-អូនសោភិនី ... ! អូននៅឯណា មកជិតបងបន្តិចមកអូន ... ឱប្រហែលជាអូនខ្លាចប្ដីអូនទេដឹង ហ៊ឺ ! ហ៊ឺ ... ! អូន ... សោ ... ភិ ... នី ...

-ឱ្យគេទៅតាមសោភិនីមកហើយ ចូរឯងខំសម្ងំទៅណាស៊ី

-អ្នកណាហ្នឹង ... សំណាងឬ ម៉ែខ្ញុំទៅណាហើយសំណាង ឯណាម៉ែខ្ញុំ ...

-អ្នកមីងគាត់ទៅរកថ្នាំឱ្យឯងផឹក បីបួនថ្ងៃទៀតឯងមុខជាជាហើយ ខំប្រឹងតាំងចិត្តឱ្យល្អណាមិត្តណា ...

-ទៅតាមគាត់មក កុំឱ្យរកថ្នាំឱ្យខ្ញុំអី ខ្ញុំក្តៅទ្រូងណាស់បន្តិចទៀត ខ្ញុំនឹងស្លាប់ហើយ បើមុននឹងស្លាប់ឱ្យខ្ញុំបានឃើញមុខម្តាយខ្ញុំផង ... ម៉ែ ... នៅឯណាម៉ែ ...

ពូឈើនដឹងថាណាស៊ីនឹងផុតខ្យល់នៅពេលខាងមុខនេះហើយ គាត់ក៏រត់ទៅតាមយកមីងមឿនមកវិញ ។

មកដល់ជិតកូន មីងមឿនខំជូតទឹកភ្នែកឱ្យស្អាត រួចប្រឹងនិយាយទៅកូនថា :

-ម៉ែមកជិតឯងហើយកូន ...

-ឱ ... ម៉ែមកហើយឬ (ណាស៊ីយកដៃម្តាយមកដាក់លើទ្រូង) ម៉ែ ... ! ជាតិនេះខ្ញុំធ្វើបាបម៉ែច្រើនណាស់ សូមម៉ែលើកទោសឱ្យខ្ញុំផង កូនដាច់ខ្យល់ស្លាប់ចោលម៉ែឥឡូវហើយ ... ។

មីងមឿងស្រក់ទឹកភ្នែកច្រោក គាត់ខំប្រឹងនិយាយអួល១ដើមកទៅកាន់កូន :

-ម្តាយលើកទោសឱ្យកូនទាំងអស់ សូមកូនកុំព្រួយអី ។

ណាស៊ីញញឹម ទឹកភ្នែកក៏ហូរហៀរចេញមក ។

-ម៉ែលើកទោសឱ្យកូនហើយឬ សំណាង ... ចូរមិត្តអត់ពីខ្ញុំទៅ ជួយថែរក្សាម្តាយខ្ញុំផងណា ... ខ្ញុំគ្មានសង្ឃឹមមិត្តភក្តិឯណាក្រៅពីសំណាងឯងទេ ។

-ឈប់ព្រួយបារម្ភទៅណាស៊ី ខ្ញុំនឹងប្រតិបត្តិតាមបណ្តាំមិត្តគ្រប់យ៉ាង ... ។

-សោភិនី ... ជាតិនេះខ្ញុំសូមលាហើយពិភពស្នេហា សំណាង ! ចូរឯងប្រាប់មិត្តយើងគ្រប់១គ្នា កុំឱ្យយកតម្រាប់អាក្រក់តាមខ្ញុំ ... ខ្ញុំស្លាប់ខ្លួនព្រោះស្នេហា ព្រោះចិត្តស្រីក្បត់ កុំឱ្យយុវជន យុវនារីជាន់ក្រោយយកគំរូតាមខ្ញុំ និងសោភិនីឱ្យសោះ ចាំឱ្យច្បាស់ថាស្ត្រីជាសត្រូវក្នុងការសិក្សា ... ដល់ខ្ញុំស្លាប់ទៅសូមមិត្តយកឆ្អឹងខ្ញុំទៅដាក់ទុកក្នុងចេតិយវត្ត អង្គរណា ...

ណាស៊ីឈប់និយាយ ផ្តើមហត់ខ្លាំងម្តងទៀត គេដកចង្កាមាន់ បញ្ឈរភ្នែក ស្លេស្មឡើងកញ្ចូសូរគ្រូក១ ខ្ញុំដឹងថា ណាស៊ីមុខជាផុតដង្ហើមលើដៃខ្ញុំ១ ក៏ឱនខ្សិបដាក់ត្រចៀកគេឱ្យទន្ទេញធម៌ :

-ណាស៊ីតាំងស្មារតីឱ្យរឹងប៉ុងណា ឯងកុំគិតរវើរវាយទៅណាឱ្យសោះ ទន្ទេញធម៌តាមខ្ញុំភ្លាមទៅ ពុទ្ធោអរហំ ! ពុទ្ធោអរហំ !

-ពុទ្ធោអរហំ ... ! ពុទ្ធោ ... អ ... រ ... ហំ ...

ថាបានតែពីរចប់ ណាស៊ីក៏ទន់ក្បាលរងៀក ភ្នែកគេសន្សឹមបិទបន្តិចម្តង១ រហូតជិតស្និទ្ធ វិញ្ញាណក្ខន្ធហោះហើរចេញពីរាងកាយទៅកាន់សុគតិភព

ហើយ ។ គួរឱ្យអាសូរមីងមឿងណាស់ គាត់ស្មានថាកូនសម្ងំដេកលក់ពុំបានដឹងថា ណាស៊ីផុតខ្យល់ឡើយ អ្នកមីងរៀបក្រោកដើរចេញគាត់ និយាយមកខ្ញុំថា :

-ដាក់ណាស៊ីចុះឱ្យដេកស្រួលបួលទៅក្មួយសំណាង កូនខ្ញុំវាអស់កម្លាំងសម្ងំដេកហើយ ។ សែនរំជួលក្នុងចិត្តក្រៃលែង ទ្រាំពុំបានខ្ញុំក៏ជំរាបការពិតដល់គាត់ :

-ណាស៊ីផុតខ្យល់អម្បាញ់មិញ ... ទៅហើយអ្នកមីង

-អូ ! កូនខ្ញុំស្លាប់ទៅហើយ ! មីងមឿនស្ទុះមកឱបសព យំទនាក់ទនាល គក់ទ្រូងខ្លួនឯងលាន់សូរ ភឹប ! ភឹប ! ហើយនិយាយរៀបរាប់តាមតែចិត្តគាត់នឹកឃើញ "ណាស៊ី ! ម្ដេចក៏អាយុខ្លីម្ល៉េះ មិញកូននិយាយរកម្ដាយ ឥឡូវម្ដេចក៏បែរជាស្លាប់ទៅវិញ ពុទ្ធោ ! ពុទ្ធោ ! មច្ចុរាជ ... អ្នកក៏មានចិត្តកាចសាហាវខ្លាំងម្ល៉េះ បើអ្នកយកជីវិតកូនខ្ញុំទៅហើយ ទុកឱ្យខ្ញុំរស់ធ្វើអ្វីទៀត មកផ្ដាច់ជីវិតខ្ញុំទៅ ! ខ្ញុំមិនចង់រស់នៅព្រាត់ប្រាស់កូនចៅដូច្នេះទេ ... !"

ចាស់ៗ បីបួននាក់ ដែលអង្គុយនៅទីនោះអត់ទ្រាំមើលទិដ្ឋភាពដ៏សែនខ្លោចផ្សានេះពុំបាន គេក៏ចូលមកនិយាយលួងលោមមីងមឿន ហើយគ្រាហ៍គាត់ចេញពីទីនោះទៅ ។ បន្ទាប់មក ខ្ញុំក៏លើកសពទៅដាក់លើគ្រែ រួចយកភួយថ្មីមួយមកគ្របខ្លួន សពតាំងពីចុងជើងរហូតដល់ក្បាល ។

លុះធ្វើក្ដារម្ឈូសរួចហើយ គេក៏បញ្ចូលសពទៅក្នុងក្ដារម្ឈូស មូលមតិគ្នាថានឹងដំកល់ទុកពីរថ្ងៃ រង់ចាំញាតិមិត្តដែលនៅទីឆ្ងាយៗ ។

-នេះហើយជារឿងពិត របស់ណាស៊ីមិត្តខ្ញុំណាវង្សរិទ្ធិ ណាស៊ីស្លាប់ ក៏ព្រោះតែសោភិនីនេះឯង ... !

សំណាងនិយាយរឿងប្រាប់វង្សរិទ្ធិចប់ ដំណក់ទឹកថ្លាដូចគ្រាប់ពេជ្រពីរដំណក់ ក៏រមៀលចេញពីរង្វង់ភ្នែកគេស្រក់ទៅលើដៃវង្សរិទ្ធិក្ដៅ ឧណ្ហៗ ។

-រឿងរបស់ណាស៊ីនេះកម្សត់ណាស់ ចាំទៅដល់ភ្នំពេញវិញ ខ្ញុំនឹងឱ្យមិត្តម្នាក់ឈ្មោះ ហាក់ នៃហុក គេនិពន្ធជាសៀវភៅប្រលោមលោកមួយដើម្បីទុកជាអនុស្សាវរីយ៍ ឧទ្ទិសដល់វិញ្ញាណក្ខន្ធរបស់អ្នកស្លាប់ នឹងទុកជាក្បួនទូន្មានដល់យុវជន យុវនារីទូទៅ កុំឱ្យប្រព្រឹត្តដូចជារូបណាស៊ី និងនាងសោភិនីទៀត ។

ក្រោយពីសន្ទនាគ្នា ពីនេះពីនោះបន្តិចទៀតមក សំណាង និងវង្សរិទ្ធិក៏នាំគ្នាដើរចេញពីផ្ទះបាយ ទៅកាន់កន្លែងដំកល់ក្ដារម្ឈូសវិញ ។

## ផ្សែងមរណៈ

ខ្ញុំត្រូវគេយកទៅបូជា ក្រោយព្យុះមរណាបក់កញ្ជ្រោក
វិញ្ញាណហើរទៅឋានបរលោក សល់ក្តីទាបថោកសោកសោកា ។
ភ្លើងឆេះសន្ធោរពុះក្តៅ ផ្សែងហោះខ្មួលខ្មៅលើវេហាស៍
នេះហើយគេហៅផ្សែងមរណៈ ឆាបឆេះកាយាសង្ខារខ្ញុំ ។

ម៉ោងមួយសែសិបប្រាំនាទីហើយ នៅខ្វះដប់ប្រាំនាទីទៀត នឹងត្រូវដង្ហែក្បួនសពទៅធ្វើឈាបនកិច្ចឯព្រៃប៉ាឆា ។

មីងមឿន ស្លៀកសពាត់សកាន់ទុក្ខមរណសញ្ញាឱ្យកូន ចំណែកញាតិសាច់សាលោហិតជិតឆ្ងាយ និងមិត្តភក្តិរបស់សព ក៏មានខ្ទាស់ផ្ទាំងសំពត់ខ្មៅជាប់នឹងអាវស ជាសញ្ញាកាន់ទុក្ខគ្រប់ៗគ្នា ។

ជិតដល់ពេលរង្កិលក្តារម្លួសចេញពីផ្ទះទៅព្រៃប៉ាឆាសមសាន សូរទំនួញដ៏គួរឱ្យសង្វេកក្នុងដួងចិត្តរបស់ម្តាយនៃសព ដែលបាត់ស្ងាត់អស់រយៈពេលយ៉ាងយូរមកហើយ ក៏ឮឡើងកន្ត្រាក់អារម្មណ៍ភ្ញៀវម្តងទៀត :

-ឱព្រះជាម្ចាស់នៃសត្វលោកអើយ ... ! គេរាល់គ្នាបំរុងនឹងយកកូនខ្ញុំទៅដុតឥឡូវហើយឬ ? ណាស៊ីកូន ! ម្ល៉េះសមកូនក្តៅនៅក្នុងភ្នក់ភ្លើងយ៉ាងណាទៅ ពីថ្ងៃនេះម្តាយខានឃើញមុខអ្នកទៀតហើយ រាងកាយកូននឹងក្លាយទៅធ្យូង ផេះ ទេ ! ទេ ! ខ្ញុំមិនឱ្យអ្នកណាយកកូនខ្ញុំទៅដុតទេ ដុតខ្ញុំវិញទៅល្អជាងខ្ញុំចង់ស្លាប់ជំនួសកូនខ្ញុំ ... ! ហ៊ឺ ! ហ៊ឺ ! ... ហ៊ឺ ! ...

មីងមឿនយំស្រែក យករូបថតណាស៊ីមកឱបផ្ទប់នឹងដើមទ្រូង គាត់បុកក្បាលទៅនឹងក្តារម្លួសប៉ុង ! ប៉ុង ! ននាក់ននាល មិនចង់ឱ្យគេយកសពកូនគាត់ចេញពីផ្ទះ ។ អ្នកនៅក្បែរទាំងប៉ុន្មានរំជួលក្នុងចិត្ត ធ្វើភ្នែករលីងរលោងហើយអត់ទ្រាំទប់តទៅទៀតលែងបាន ក៏ស្រក់ទឹកភ្នែកចេញមក យំអណ្តើតអណ្តក់គ្រប់ៗគ្នា ។

បរិយាកាសពេលនេះ ស្ថិតនៅក្នុងសភាពអាប់អួរ គេឮតែសូរស្រែកយំទ្រហឹងពេញផ្ទះ អស់មានអ្នកណាជួយលួងលោមអ្នកណាទៀត ហើយម្នាក់ៗអង្គុយយំស្រណោះស្រណោក អាឡោះអាល័យនឹងសពមិន ចេះស្រាកស្រាន្ត ។ នៅខាងមុខផ្ទះឯណោះ រថយន្តម៉ែរសីដេស (Metcedes 220 S) ពណ៌ត្រួយចេកមួយលូនមកឈប់មុខផ្ទះមីងមឿន នៅក្នុងរថយន្តគេឃើញមានមនុស្សពីរនាក់ គឺប្រុសជាសូហ្វ៊ែរ (chau ffeur) និងម្នាក់ទៀតអង្គុយបាំងខាងក្រោយជាសុភាពស្ត្រីរូបស្អាត ។

គ្រាន់តែស្ត្រីនោះចុះពីលើរថយន្តភ្លាម គេក៏អាចដឹងថានាងមានផ្ទៃពោះ ។ សាច់ពោះដែលខ្វាតចេញពីរាងដ៏ល្វតល្វន់ បញ្ជាក់យ៉ាងច្បាស់ថា យ៉ាងហោចណាស់នាងក៏ទម្ងន់បានបួនប្រាំខែហើយ តើនាងនោះជាអ្នកណាទៅអេះ ? ស្ត្រីផើមឈរសម្លឹងមើលទៅទង់មរណៈដោយដួងចិត្តវិប្បយោគនឹកងឿងឆ្ងល់តែម្នាក់ឯង អ្នកណាស្លាប់ ? ពេលនោះ សំណាងដើរចេញមកក្រៅ ស្ត្រីផើមក្រឡេកឃើញក៏ស្រែកហៅ :

-បងសំណាង !

-អូ ! អ្នកសោភិនីទេឬ ?

សោភិនីដើរតម្រង់ទៅសំណាង ព្រមទាំងសួរគេដោយវិតក្កថា :

-បងសំណាង ... ! អ្នកណាស្លាប់ ?

-ហ៊ឺះ ! (សំណាងសើចចំអកឱ្យសោភិនី) អ្នកណាស្លាប់ ? មិនជាពិបាកយល់ទេអ្នក ស្តាប់សូរស្រែកទួញយំលើផ្ទះឯណោះ វាបញ្ជាក់យ៉ាងច្បាស់ណាស់ថា អ្នកស្លាប់គឺណាស៊ីមិត្តខ្ញុំ !

-បងណាស៊ីស្លាប់ !

-ត្រូវហើយអ្នក ....អ្នកមកធ្វើអ្វីទៀត គ្រប់យ៉ាងវាបានឆ្លងផុតទៅដល់ទីបញ្ចប់ហើយ ....

សោភិនីមុខឡើងស្លាំងអត់ឈាម នាងរត់ឡើងទៅលើផ្ទះ វែកគេវែកឯង ទៅយំបោកខ្លួននឹងក្តារម្ឈូស បណ្តាញាតិមិត្តសព នាំគ្នាស្រឡាំងកាំងដោយមិនដឹងរឿងហេតុ ។

-បងណាស៊ី (សោភិនីនិយាយ) បងស្លាប់ចោលអូនហើយ ? ...... អូនជាស្រីកាកី ! ស្រីក្បោកមាស ! អាក្រក់ជួរជាតិណាស់ ! អូនដឹងខ្លួនហើយថាបងស្លាប់នេះគឺដោយសារតែរូបអូនម្នាក់ អូនជាស្រីឈ្លក់វង្វេងនឹងទ្រព្យសម្បត្តិមាសពេជ្រ អូនក្បត់បង .... អូនភ្លេចពាក្យសម្បថ ....ភ្លេចទាំងកូននៅក្នុងផ្ទៃដែលបងជាអ្នកអោយកំណើតដល់វាទៀត ? សូមវិញ្ញាណក្ខ័ន្ធដ៏ប្រសើររបស់បងទៅកាន់សុខគតិភពចុះ អូនសូមខមាទោសចំពោះវិញ្ញាណក្ខ័ន្ធបង . . . សូមវិញ្ញាណក្ខ័ន្ធបងអហោសិកម្មអោយអូនផង ។

-គ្រប់យ៉ាងវាហួសទៅហើយ (សំណាងនិយាយ) សូមអ្នកឈប់យំស្រែកទៅ កុំឱ្យគេរាល់គ្នារន្ធត់ចិត្តកាន់តែខ្លាំងជាងនេះទៅទៀត បើទោះជាអ្នកខំស្រែកទ្រហោយំទាល់តែបែកក្តារមឈូសនេះជាពីរបីចំណែក ក៏ណាស៊ី មិត្តខ្ញុំមិនអាចរស់ឡើងវិញដែរ . . . អ្នកជាអ្នកកសាង ហើយខ្លួនអ្នកជាអ្នកបំផ្លាញទៅវិញទេតើ . . . ។

សភាពស្ងប់ស្ងាត់កើតឡើងមួយខណៈ សោភិនីបានទៅក្រាបសំពះអង្វរសុំទោសអ្នកមីងមឿន ហើយនាងសុំស្លៀកសពាក់ស ដើម្បីចូលរួមមរណសញ្ញាដង្ហែសពទៅធ្វើឈាបនកិច្ច ។

លុះដល់ម៉ោងពីរ ក្បួនដង្ហែសពក៏ចាប់ផ្ដើមធ្វើឡើង សម្លេងក្លងខែក (ស្គរសំរាប់ហែខ្មោច) លាន់ឮគ្រលួច ស្រឡៃខំដំអួញសំនៀងរបស់ខ្លួនតូចឆ្មារហាក់ដូចជាឆក់យកដួងព្រលឹងអ្នកទាំងអស់គ្នាអោយបាត់បង់ពីរាងកាយទៅតាមបុគ្គលដែលស្លាប់ ។ នៅតាមផ្លូវទៅកាន់ប៉ាឆា សូរសម្រែកស្រែកដង្ហោយយំនៃក្រុមគ្រួសារសព លាយឡំនឹងសង្វាក់ស្គរក្លងខែកដែលក្រុមអ្នកភ្លេងបន្លឺឡើង ទុង ! ទុង ! មិនដាច់រយៈ ?

អនិច្ចា ! សង្ខារមិនទៀងទាត់ កើតហើយរមែងតែស្លាប់ទៅវិញ រៀងរាល់រូប ... អ្វីៗនៅក្នុងលោកសុទ្ធតែជាអនត្តាទាំងអស់ ។ សព ណាស៊ី បុរសកម្សត់បានត្រូវគេសែងក្ដារម្ឈូសទៅដំកល់លើគំនរឧសក្នុងឈាបនដ្ឋាន ហើយបន្ទាប់មកព្រះអគ្គី ក៏ឆាបឆេះបញ្ចេញអណ្ដាតភ្លើងសន្ធោរសន្ធៅហុយផ្សែងទ្រលោមខ្មៅខ្វាញ់ទៅលើឲ្យដ៏អាកាស ឱ ! ... ផ្សែងមរណៈ !

មីងមឿនឈរសម្លឹងមើលអណ្ដាតភ្លើងដែលកំពុងឆេះដង្គោល លេបរូបរាងកាយកូនសម្លាញ់គាត់ឱ្យបាត់ម្ដងបន្តិចៗពីរង្វង់ចក្ខុ ។ មុខគាត់ឡើងខ្មៅដូចមរណ៍ បេះដូងថ្លើមប្រម៉ាត់ ស្ទើរនឹងប្រេះធ្លាយចេញពីទ្រូងគ្មានពេលណាតក់ស្លុតរំជួលចិត្តដូចជាពេលនេះទេ គាត់ចង់ស្ទុះចូលទៅក្នុងភ្នក់ភ្លើង ខ្ញុំស្លាប់បាត់បង់ជីវិតតាមកូន តែធ្វើម្ដេច ... បើខ្លួនប្រាណគាត់ទាំងមូលត្រូវសំណាងឱបជាប់ទៅហើយ ។ សោភិនីពេលនេះនាងក៏មានសភាពមិនខុសពីមីងមឿនដែរ នាងយំស្រែក ដង្ហោយហៅឈ្មោះណាស៊ី ទាល់តែសន្លប់បាត់ស្មារតី ... ។

បីថ្ងៃក្រោយពីរំលាយសពណាស៊ីមក សោភិនីក៏លាមីងមឿន និងសំណាងត្រឡប់ទៅនៅជាមួយប្ដីនាងវិញ ដោយសន្យាថានៅពេលណានាងសំរាលបុត្រ នាងនឹងយកកូនមកលេងសៀមរាបម្ដងទៀត ។

ចំណែក សំណាង ក៏បានជញ្ជូនឥវ៉ាន់ពីវត្តមកនៅជាមួយមីងមឿន ហើយយកអដ្ឋិធាតុណាស៊ីទៅបញ្ចុះ នៅចេតិយវត្តអង្គរតាមបណ្ដាំរបស់គេ។

រឿង ឱ ! ផ្សែងមរណៈ សន្មតថាចប់តែត្រឹមណេះ សូមជោគជ័យសេរីមង្គលមានដល់អស់លោកអ្នកនាងកញ្ញា ដែលបានអានសៀវភៅនេះគ្រប់ៗគ្នាកុំបីឃ្លាងឃ្លាតឡើង ។

~ចប់~